# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ៖

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ ខ្មែរ និងបារាំង

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Oct-2013, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ និងខ្សែបូរស្ម័ន្ទសំខាត់**

ចំណាត់ថ្នាក់ឯកសារដោយ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងខ្សែបូរស្ម័ន្ទសំខាត់

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

គង់ ផល្លៈ

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ែន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**ចម្លងជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

យ៉េត ចរិយា

William SMITH

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Beini YE

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. សេចក្តីផ្តើម

១. នៅក្នុងដំណើរការជំនុំជម្រះ ជាពិសេសក្នុងអំឡុងពេលសវនាការលើខ្លឹមសារជាក់លាក់ជា បឋមស្តីពីសំណងដែលបានប្រព្រឹត្តទៅកាលពីខែ មិថុនា ឆ្នាំ ២០១១ និង សវនាការថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគូសបញ្ជាក់ ជាច្រើនដងអំពីសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានសង្កត់ធ្ងន់ថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺជាសិទ្ធិមួយ មិនមែនជាអំណោយលើកទឹកចិត្តនោះទេ ហើយការចូលរួមនេះដែរ គឺជាវត្តមានដ៏ចាំបាច់ និង មិនមែនជាការអញ្ជើញនោះទេ។ តាមរយៈការការពារឋានៈ និងសិទ្ធិបញ្ចេញមតិរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី មានបំណងការពារតួនាទីរបស់ខ្លួននៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

២. សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងតាមផ្លូវតុលាការ ដែលជាផលវិបាកមួយនៃការចូលរួមនេះ គឺមានចែងនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ។ ប្រសិនបើពុំមានសំណងទេ នោះក៏ពុំមានយុត្តិធម៌ពេញលេញដែរ ហើយនេះគឺជាការតម្រូវ។

៣. ស្របតាមសិទ្ធិនេះ សារណានេះត្រូវបានដាក់ដើម្បីសុំឲ្យមានការផ្តល់ជាសំណងដ៏មានន័យ និងត្រឹមត្រូវ។

៤. សារណានេះនឹងលើកឡើងពីច្បាប់ជាធរមាន មូលដ្ឋាននៃសំណង ពោលគឺការខូចខាតដែលបានទទួលរង និងសំណងផ្ទាល់តែម្តង ក្នុងការឆ្លើយតបទៅនឹងការខូចខាតទាំងអស់នោះ តាមរយៈគម្រោងសំណងនានា។ ប៉ុន្តែ ជាបឋម យើងនឹងរំឭកពីដំណាក់កាលផ្សេងៗដែលបាននាំទៅដល់ការបង្កើតគម្រោងសំណង ដែលនឹងត្រូវអត្ថាធិប្បាយ។

## II. ប្រវត្តិនីតិវិធី

៥. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ សហមេធាវីនាំមុខបានបង្ហាញពីខ្លឹមសារបឋមនៃសំណង[1] ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ អនុលោមតាមវិធាន ៨០ ស្ទួន[2] នៃវិធានផ្ទៃក្នុង។ ក្នុងអំឡុងពេលសវនាការ សហមេធាវីនាំមុខបានបង្ហាញពីមូលដ្ឋានគតិយុត្តិនៃសំណង និងបានផ្តល់ព័ត៌មានស្តីពីគម្រោងសំណងទាំង១៣ ដែលកំពុងត្រូវបានរៀបចំនាពេលនោះ[3]។ ជាមួយគ្នានេះដែរ សហមេធាវីនាំមុខ ក៏បានគូសបញ្ជាក់ពីបន្ទុកយ៉ាងធំចំពោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការកំណត់ ការរៀបចំ និងថវិកាសម្រាប់គម្រោងសំណង ដូចដែលមានចែងនៅក្នុងវិធាន ២៣ ស្ទួនបួន (៣) (ខ)។ ជាមួយគ្នានេះដែរ សហមេធាវីនាំមុខ ក៏បានរក្សាសិទ្ធិក្នុងការស្នើសុំគម្រោង

សំណងបន្ថែម នៅក្នុងសំណើសុំចុងក្រោយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងលក្ខខណ្ឌដែលគម្រោងទាំងអស់នោះ ឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវដែលចែងដោយអង្គជំនុំជម្រះសាលាដំបូង[4]។

៦. នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសេចក្តីសម្រេចរបស់ខ្លួនក្នុងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ដោយបានកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង លែងចូលរួមជាក្ខណៈបុគ្គលទៀតហើយ ប៉ុន្តែ នៅក្នុងក្រុមមួយ និងដោយបានបញ្ជាក់ថា *"(...) ការកម្រិតវិសាលភាពនៃអង្គហេតុ ដែលគ្រោងនឹងយកមកជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះ ពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ"*[5]។ បន្ទាប់មក សហមេធាវីនាំមុខ បានដាក់សំណើជាច្រើន សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ផ្តល់នូវការបំភ្លឺពាក់ព័ន្ធនឹងបញ្ហាច្បាប់ជាក់លាក់នានាទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធី និងការទាមទារសំណង[6]។

៧. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់នូវការបំភ្លឺបន្ថែមលើ "លក្ខណៈជាមូលដ្ឋាន" នៃយន្តការសំណងនៅចំពោះមុខ អ.វ.ត.ក និងបានជូនដំណឹងពីសេចក្តីសង្កេតរបស់ខ្លួនលើគម្រោងដែលបានបង្ហាញនៅក្នុងខ្លឹមសារបឋមស្តីពីសំណង[7]។ ក្នុងចំណោមខ្លឹមសារទាំងអស់នោះ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា អ្នកទទួលខុសត្រូវគម្រោងក្នុងផ្នែកគាំពារជនរងគ្រោះ ត្រូវទទួលបន្ទុកធានារកថវិកាសម្រាប់គម្រោង ដើម្បីឱ្យសំណងអាចអនុវត្តបានភ្លាមៗ។ អង្គជំនុំជម្រះ ក៏បានសុំឱ្យសហមេធាវីនាំមុខ ផ្តល់នូវសេចក្តីលម្អិតបន្ថែម នៅក្នុងសំណើសុំបឋមថ្មីមួយស្តីពីការទាមទារសំណង[8]។

៨. នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ តាមការស្នើសុំរបស់អង្គជំនុំជម្រះ[9] សហមេធាវីនាំមុខ បានបំពេញសំណើបឋមស្តីពីសំណង នៅក្នុងសំណុំរឿង០០២/០១ ដោយបានសុំឱ្យមានការបំភ្លឺពាក់ព័ន្ធនឹងទិដ្ឋភាពជាក់លាក់នៃយន្តការទាមទារសំណង ដោយបានបង្ហាញនូវទទ្បីករណ៍ផ្លូវច្បាប់ និងដោយបានផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងគម្រោងទាំង១៤ ដែលកំពុងត្រូវបានរៀបចំនាពេលនោះ[10]។ ជាមួយគ្នានេះដែរ សហមេធាវីនាំមុខបានរំឭកសារជាថ្មីថា ខ្លួនសូមរក្សាសិទ្ធិក្នុងការស្នើសុំគម្រោងសំណងបន្ថែម នៅក្នុងសំណើសុំចុងក្រោយរបស់ខ្លួន[11]។

៩. នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីណែនាំមួយចំនួនស្តីពីសំណង ជាការបំភ្លឺដល់ការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២ ដោយបានបង្ហាញពីភាពខុសគ្នានៃផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធី ទៅតាមទម្រង់នៃការអនុវត្តសម្រាប់សំណង និងដោយបានបញ្ជាក់ថា សំណងដែលទាមទារ អនុលោមតាមវិធាន ២៣ ស្ទួនបួន

(៣)(ក) ត្រូវកម្រិតត្រឹមតែព្យសនកម្ម ដែលបណ្ដាលមកពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ចំណែកឯសំណងដែលត្រូវបានស្នើសុំ ស្របទៅតាមវិធាន ២៣ ស្ទួនបួន (៣)(ខ) មិនស្ថិតក្នុងករណីនេះទេ[12]។

១០. នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្ដីណែនាំបន្ថែមស្ដីពីការទាមទារសំណង ដោយបានស្នើឲ្យសហមេធាវីនាំមុខ ផ្ដល់អាទិភាពដល់ការរៀបចំគម្រោងសំណងមួយចំនួនតូចដ៏មានន័យ[13]។

១១. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ស្នើឲ្យសហមេធាវីនាំមុខរៀបចំជាបញ្ជីមួយស្ដីពីគម្រោងសំណងដែលត្រូវបានជ្រើសរើសជាអាទិភាព និងដាក់បញ្ជីនោះនៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងផ្ដល់នូវព័ត៌មានស្ដីពីថវិកាសម្រាប់គម្រោង ដោយត្រូវពិគ្រោះជាមួយអង្គភាពគាំពារជនរងគ្រោះ[14]។

១២. នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ សហមេធាវីនាំមុខ បានដាក់ព័ត៌មានស្ដីពីសំណងដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដោយបានរៀបរាប់យ៉ាងលម្អិតពីគម្រោងអាទិភាពទាំងប្រាំពីរដែលកំពុងត្រូវបានរៀបចំក្នុងក្របខណ្ឌនៃការទាមទារសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយបានកត់សម្គាល់ពីស្ថានភាពថវិកាសម្រាប់សំណង និងដោយបានគូសបញ្ជាក់ពីការទទួលខុសត្រូវជាចំបងរបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងការរៀបចំគម្រោង[15]។ ឯកសារក៏បានរំឮកផងដែរពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដាក់ជូននូវគម្រោងបន្ថែម នៅពេលដាក់សំណើសុំចុងក្រោយ[16]។

១៣. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងតាមសេចក្ដីស្នើសុំពីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបំភ្លឺពីផលវិបាកនៃកិច្ចបំបែកដំណើរការនីតិវិធីលើការទាមទារសំណង ដោយបានកត់សម្គាល់ថា *"អង្គជំនុំជម្រះសាលាដំបូងពុំបានជ្រើសរើសចំនួនដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកម្រិតជាក់លាក់ពីបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ ដើម្បីទទួលបានប្រយោជន៍ពីសំណងណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានប្រគល់ ឬអនុម័តនៅទីបំផុតនោះទេ"* ព្រមទាំងបានគូសបញ្ជាក់ពីទំនាក់ទំនងដែលតម្រូវឲ្យមានរវាងឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះ និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[17]។

១៤. នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបទៅនឹងការធ្វើបច្ចុប្បន្នភាពកាលពីខែកុម្ភៈ ឆ្នាំ២០១៣ របស់សហមេធាវីនាំមុខ ដោយបានស្នើសុំព័ត៌មានលម្អិតពាក់ព័ន្ធនឹងការកំណត់ ការរៀបចំថវិកា និងដៃគូរបស់គម្រោងអាទិភាព និងដោយបានកត់សម្គាល់ថា *"ជាគោលការណ៍ វិធានការដែលបានស្នើសុំក្រោមប្រភេទគម្រោងទាំងបីនេះ ទទួលស្គាល់យ៉ាងសមស្រប នូវព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដោយសារតែការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទាំងឡាយ ដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ និងផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនេះជាការឆ្លើយតបទៅនឹងព្យសនកម្មនេះ (វិធាន ២៣ ស្ទួនបួន (១)) ហើយអង្គជំនុំជម្រះ នឹងគាំទ្រដល់គម្រោងដូចផ្តើមទាំងនេះ នៅពេលទទួលបានព័ត៌មានបន្ថែមចាំបាច់នានា"*[18]។

១៥. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ សហមេធាវីនាំមុខ បានឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានផ្តល់នូវការបញ្ជាក់បន្ថែមលើគម្រោងសំណងទាំងប្រាំបីដែលកំពុងរៀបចំ[19]។ ជាថ្មីម្តងទៀត ដើមបណ្តឹងរដ្ឋប្បវេណីបានរក្សាសិទ្ធិក្នុងការស្នើសុំសំណងបន្ថែម នៅពេលដែលខ្លួនដាក់សំណើសុំចុងក្រោយ[20]។

១៦. នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានឆ្លើយតបទៅសហមេធាវីនាំមុខ និងបានរំឭកពីកាតព្វកិច្ចមួយចំនួន ដែលក្នុងនោះ បញ្ហាថវិកាត្រូវតែធានាឲ្យបានទាំងស្រុងនៅមុនពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល[21]។

១៧. នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានសម្រេចផ្តល់រយៈពេលបន្ថែមរហូតដល់ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៣ សម្រាប់ដាក់សារណាចុងក្រោយស្តីពីសំណង[22]។

## III. ច្បាប់ជាធរមានស្តីពីការទាមទារសំណង

### ក. សិទ្ធិក្នុងការទាមទារសំណងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ

១៨. វាគឺជាគោលការណ៍ច្បាប់ទូទៅដែល *"រាល់ការរំលោភសិទ្ធិនាំឲ្យកើតមាននូវកាតព្វកិច្ចក្នុងការជួសជុល"*[23]។ ការជួសជុលការខូចខាត មានគោលបំណងប្រគល់សងមកវិញទាំងស្រុង ឬក៏លុប

បំបាត់នូវផលវិបាកនៃអំពើខុសច្បាប់[24] ហើយដែលនៅក្នុងករណីជនរងគ្រោះមានរបួសស្នាមដោយអំពើឧក្រិដ្ឋរបស់អ្នកដទៃ មានន័យថា ជាការប្រគល់សងមកវិញក្នុងលក្ខខណ្ឌដើម។

១៩. សិទ្ធិក្នុងការទាមទារសំណង គឺជាគោលការណ៍គ្រឹះដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ហើយដែលការអនុវត្តត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះ[25]។ ទាំងច្បាប់កម្ពុជា ទាំងច្បាប់បារាំង ដែលច្បាប់កម្ពុជាបានទទួលឥទ្ធិពលពីច្បាប់បារាំង បានទទួលស្គាល់ពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជួសជុលការខូចខាតដែលបានទទួលរងដោយសារ អំពើឧក្រិដ្ឋ និងបានរៀបចំជាដំណើរការមួយដែលក្នុងនោះ ជនរងគ្រោះអាចស្នើសុំទាមទារសំណងសម្រាប់រាល់ការខូចខាតផ្នែកសម្ភារៈ ផ្លូវកាយ និង/ឬ ផ្លូវចិត្តដែលបានទទួលរង[26]។

២០. នៅក្នុងច្បាប់អន្តរជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសន្ធិសញ្ញាអន្តរជាតិមួយចំនួនទៀតពាក់ព័ន្ធនឹងសិទ្ធិមនុស្ស បានបញ្ជាក់ពីសិទ្ធិរបស់បុគ្គលក្នុងការរកជំនួយ។ គោលការណ៍គ្រឹះ និងសេចក្តីណែនាំពាក់ព័ន្ធនឹងសិទ្ធិក្នុងការទទួលបានជំនួយ និងសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានជាក់ស្តែងលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ បានបញ្ជាក់ឡើងវិញពីសិទ្ធិក្នុងការទទួលបាន *"សំណងត្រឹមត្រូវ ប្រកបដោយប្រសិទ្ធិភាព និងរហ័សស្របទៅតាមព្យសនកម្មដែលបានទទួលរង"*[27] និងបានបញ្ជាក់ពីបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងការផ្តល់សំណង ដែលក្នុងនោះរួមមាន សិទ្ធិទទួលបានសំណង"ពេញលេញ និងប្រកបដោយប្រសិទ្ធិភាព" ក្រោមទម្រង់ជាការប្រគល់សងមកវិញ ការជួសជុលការខូចខាត ការស្តារនីតិសម្បទា ការពេញចិត្ត និងការធានាមិនឲ្យប្រព្រឹត្តសារជាថ្មី[28]។ ច្បាប់អន្តរជាតិទាំងអស់នេះ គួរតែត្រូវបានអនុវត្តទាំងស្រុងនៅចំពោះមុខ អ.វ.ត.ក។

២១. តុលាការអន្តរជាតិជាច្រើន ក៏បានទទួលស្គាល់ផងដែរនូវសិទ្ធិក្នុងការទាមទារសំណង ហើយតុលាការ
ជាច្រើនក៏បានបញ្ចូលនីតិវិធីដែលអាចអនុញ្ញាតឲ្យជនរងគ្រោះស្នើសុំសំណងផងដែរ។ ច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ច្បាប់តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង និងច្បាប់តុលាការសិទ្ធិមនុស្សអឺរ៉ុប បានទទួលស្គាល់យ៉ាងច្បាស់នូវសិទ្ធិទាមទារសំណង[29]។ ការងារសំខាន់របស់តុលាការថ្នាក់តំបន់នៅក្នុងផ្នែកសំណង បាននាំឲ្យអង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា *"យុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្សនៅកម្រិតតំបន់នានាស្តីអំពីការផ្តល់សំណងដល់ជនរងគ្រោះ អាចធ្វើជាឯកសារមូលដ្ឋានគួរឲ្យជឿជាក់បាន ពាក់ព័ន្ធនឹងខ្លឹមសារនៃសិទ្ធិទទួលបានសំណងចំពោះព្យសនកម្ម*

*ដែលបុគ្គលទាំងឡាយបានទទួលរង រួមទាំងជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំផងដែរ*”[30]។ តុលាការមិនអចិន្ត្រៃយ៍ មានដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ក៏បានទទួលស្គាល់ផងដែរនូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណង បើទោះបីជាតុលាការទាំងអស់នោះផ្អែកទៅលើយន្តការខាងក្រៅក្នុងការអនុវត្តនូវសិទ្ធិមួយនេះយ៉ាងណាក៏ដោយ[31]។

## ខ. វិធានផ្ទៃក្នុង

### ១. ទម្រង់ និងខ្លឹមសារនៃសំណើសុំចុងក្រោយ

២២. វិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវសិទ្ធិស្នើសុំសំណងផ្លូវចិត្ត និងជាសមូហភាព តាមរយៈការដាក់“សំណើសុំចុងក្រោយ”ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[32]។ សំណើសុំចុងក្រោយស្តីពីសំណង ត្រូវរៀបរាប់ពីសំណងដែលចង់បានត្រូវបញ្ចូលនូវរាល់ទឡ្ហីករណ៍ផ្លូវច្បាប់ ដោយត្រូវបញ្ជាក់ថាតើវិធានការទាំងអស់នោះឆ្លើយតបបានយ៉ាងដូចម្តេចទៅនឹងព្យសនកម្មដែលបានទទួលរង និងក្នុងករណីដែលអាចអនុវត្តបាន បញ្ជាក់អំពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមរួមដែលពួកគេជាប់ពាក់ព័ន្ធនឹងវិធានការជាក់លាក់ និងបញ្ជាក់ពីទម្រង់នៃការអនុវត្តដែលចង់បានសម្រាប់សំណងនីមួយៗ[33]។ ដើមបណ្តឹងរដ្ឋប្បវេណី “មានបន្ទុកក្នុងការបង្ហាញភ័ស្តុតាងទាក់ទិននឹងខ្លឹមសារនៃពាក្យបណ្តឹងរបស់ខ្លួន”[34]។

### ២. ទំនាក់ទំនងចាំបាច់រវាងក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង *០០២*

២៣. សំណើសុំវិធានការសំណង ដែលស្នើដោយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវស្ថិតក្នុងលក្ខខណ្ឌតម្រូវមួយដែលចែកជាពីរផ្នែក។ សំណងទាំងនោះត្រូវ ១)ទទួលស្គាល់ព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ថាជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានប្រកាសថាមានពិរុទ្ធភាព និង ២)ធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានទទួលផលប្រយោជន៍ សំដៅឆ្លើយតបទៅនឹងព្យសនកម្មនោះ[35]។ នៅក្នុងដំណាក់កាលជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងដំណើរការនីតិវិធី ក្នុងនាមជាក្រុម[36] ហើយទំនាក់ទំនងរបស់ពួកគាត់ជាមួយឧក្រិដ្ឋកម្ម ត្រូវបានបង្ហាញបន្ទាប់ពីពួកគាត់ត្រូវបានទទួលស្គាល់ជាស្ថាពរនៅក្នុងសំណុំរឿង ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាល

បឋម[37]។ វិធានផ្ទៃក្នុងមិនបានតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ រវាងការខូចខាតផ្ទាល់ខ្លួន និងឧក្រិដ្ឋកម្ម នៅក្នុងអំឡុងពេលនៃការជំនុំជម្រះឡើយ។ ផ្ទុយទៅវិញ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញពីទំនាក់ទំនងរវាងការខូចខាតដែលបានទទួលរង និងឧក្រិដ្ឋកម្ម។

២៤. ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ *"ហេតុដូច្នេះ ការកម្រិតវិសាលភាពនៃអង្គហេតុដែលគ្រោងនឹងយកមកជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះ ពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ។ ចំណែកការទាមទារសំណង ដែលធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏គួរគិតពិចារណាលើវិធាន ២៣ ស្ទួនបួន (១)(ក) នៃវិធានផ្ទៃក្នុងផងដែរ"*[38]។ សំណងដែលត្រូវបានទាមទារស្របតាមខ្លឹមសារនៃវាក្យខណ្ឌនេះ អាចត្រូវរៀបចំឡើងសម្រាប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនស្ថិតនៅក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គល ឬឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ឡើយ[39]។ ប៉ុន្តែ សំណងដែលត្រូវបានស្នើសុំ ស្របទៅតាមវិធាន ២៣ ស្ទួនបួន (៣)(ក) ត្រូវឆ្លើយតបទៅនឹងព្យសនកម្មដែលបានទទួលរងដែលកើតចេញមកពីការប្រព្រឹត្ត និងការចោទប្រកាន់ ដែលជាមូលដ្ឋាននៃសំណុំរឿង ០០២/០១[40]។ វាគឺជាលក្ខខណ្ឌតម្រូវអប្បបរមា ហើយសំណងត្រូវតែឆ្លើយតបផងដែរទៅនឹងព្យសនកម្មដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី បណ្តាលមកពីអង្គហេតុទាំងអស់។

## ៣. លក្ខណៈសមូហភាព និងផ្លូវចិត្ត នៃសំណង

២៥. វិធានផ្ទៃក្នុងបានចែងថា សំណងត្រូវតែជាសំណង "ផ្លូវចិត្ត និងសមូហភាព" ហើយដែលសំណងប្រភេទនេះ ត្រូវបានពណ៌នាថាជាសំណងដែលអាចឆ្លើយតបទៅនឹងការតម្រូវឲ្យមានជាទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងព្យសនកម្ម ហើយដែល *"ផលប្រយោជន៍ទាំងនេះ មិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ"*[41]។ ធាតុផ្សំ "*ផ្លូវចិត្ត*" នៃសំណង ផ្តោតទៅលើសំណងដែលស្វែងរកការជួសជុលព្យសនកម្មផ្លូវចិត្ត ជាជាងព្យសនកម្មសម្ភារៈ។ វាគឺជាវិធានការសម្រាប់ស្តារភាពថ្លៃថ្នូររបស់ជនរងគ្រោះ រក្សាទុកនូវការចងចាំរួម ទទួលស្គាល់ជាសាធារណៈនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងព្យសនកម្មដែលបានទទួលរង និងមានតួនាទីជានិមិត្តរូប[42]។

២៦. តុលាការបានបញ្ជាក់ថា ធាតុផ្សំ "*សមូហភាព*" សំដៅឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលបានកើតមានឡើងនៅប្រទេសកម្ពុជា[43] ដែលក្នុងនោះមានទាំងការរំលោភជាលក្ខណៈបុគ្គល

និងការរំលោភដែលសំដៅចំពោះក្រុម។ ទោះបីជាសំណងត្រូវបានប្រគល់ជូនជនរងគ្រោះ ក្នុងឋានៈជាក្រុមដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ *"ក៏សំណងផ្លូវចិត្តអាចផ្តល់នូវផលប្រយោជន៍សម្រាប់សមាជិកនៃក្រុមសមូហភាពផងដែរ"*[44]។

**៤. ទម្រង់នៃការអនុវត្តសំណង**

២៧. វិធានផ្ទៃក្នុងបានចែងអំពីទម្រង់ពីរខុសគ្នា និងមិនអាស្រ័យគ្នាសម្រាប់ការទាមទារសំណងតាមផ្លូវតុលាការ។ ពាក់ព័ន្ធនឹងវិធានការសំណងនីមួយៗដែលត្រូវបានរៀបរាប់នៅក្នុងសំណើសុំចុងក្រោយរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញថាខ្លួនស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់នូវវិធានការណាមួយប្រឆាំងនឹងជនជាប់ចោទ ដែលអាចជាអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុក្នុងករណីដែលមានការផ្តន្ទាទោស ឬ"ទទួលស្គាល់"គម្រោងណាមួយថាបានទទួលថវិកាពីខាងក្រៅ[45]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ទម្រង់សំណងទីមួយ ថាជាទម្រង់ដែល"ធ្លាប់អនុវត្ត"ជាងគេសម្រាប់សំណងតាមផ្លូវតុលាការក៏ដោយ[46] ក៏វិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់តុលាការ មិនបានអនុញ្ញាតឱ្យមានការបង្គាប់ក្នុងពេលតែមួយឱ្យផ្តល់ជាសំណងប្រឆាំងនឹងជនជាប់ចោទ និងសំណងទទួលមូលនិធិពីខាងក្រៅនោះទេ[47]។ ដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមជាច្រើនដងក្នុងការដោះស្រាយស្ថានភាពបែបនេះ តាមរយៈការស្នើសុំឱ្យមានការស៊ើបអង្កេតលើស្ថានភាពសម្ភារៈរបស់ជនជាប់ចោទ[48] ឬស្នើសុំឱ្យធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដើម្បីមានលទ្ធភាពអាចអនុវត្តបាននូវទម្រង់សំណងទាំងពីរក្នុងពេលតែមួយ[49]។ សំណើសុំទាំងពីរត្រូវបានបដិសេធចោល ដែលក្នុងនោះសំណើទីពីរមិនបានទទួលចម្លើយអ្វីទាល់តែសោះ[50]។

**៥. ទំហំនៃផលប្រយោជន៍នៃសំណង**

២៨. វិធានផ្ទៃក្នុងដែលតម្រូវថា*"សំណងត្រូវតែផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី"* បានចែងពីលក្ខខណ្ឌតម្រូវអប្បរមា ប៉ុន្តែពុំបានបដិសេធថា សំណងទាំងអស់នោះអាចផ្តល់ផលប្រយោជន៍ដល់អ្នកផ្សេងទៀតក្រៅតែពីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ វិធានការ និងគម្រោងសំណង មិនត្រឹមតែអាចផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០២ ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចផ្តល់ផលប្រយោន៍ដល់មនុស្ស ឬក្រុមនានា ដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី[51]នោះទៀតផង។ លក្ខណៈសមូហភាព និងផ្លូវចិត្ត នៃគម្រោងសំណងអាចនាំមកនូវផលប្រយោជន៍ដល់សង្គមទាំងមូល ជាពិសេសសម្រាប់ជនរងគ្រោះផ្ទាល់ និងជនរងគ្រោះមិនផ្ទាល់ ដល់យុវជន និងប្រជាជនជាទូទៅ។ តុលាការបានចាត់ទុកលក្ខណៈបែបនេះថាដូចជា"មុខងាររបស់សំណងក្នុងការផ្សះផ្សា"[52]។

## គ. ការពិចារណាផ្សេងទៀតពាក់ព័ន្ធនឹងយុត្តិសាស្ត្ររបស់អវតក

### ១. ការអនុវត្ត និងពេលវេលារបស់វា

២៩. តុលាការបានគូសបញ្ជាក់ពីរបបនៃសំណងរបស់ អ.វ.ត.ក ថាជាយន្តការមួយផ្អែកលើដំណើរការរបស់អ្នកស្នើសុំ ដែលក្នុងនោះដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញពីសំណើសុំសំណងដែលត្រូវបានរៀបចំឡើងឲ្យបានត្រឹមត្រូវដើម្បីឲ្យសំណើសុំទាំងអស់នោះអាចត្រូវបានសម្រេច និងទទួលស្គាល់[53]។ វិធានការសំណងត្រូវមានរាល់ធាតុផ្សំនៃការអនុវត្តទាំងអស់ ព្រោះថាតុលាការ *"មិនអាចចេញសេចក្តីបង្គាប់ណាមួយបានឡើយ នៅពេលដែលកម្មវត្ថុនៃការទាមទារមានលក្ខណៈស្រពិចស្រពិល ឬមិនពិតប្រាកដនិងដែលមិនអាចអនុវត្តបាន"*[54]។ ការអនុវត្តគម្រោងដែលនឹងត្រូវស្នើសុំ ស្របតាមវិធាន២៣ ស្ទួនបួន (៣)(ខ) អាចត្រូវចាប់ផ្តើមមុនពេលប្រកាសសាលក្រមស្តីពីសំណង[55]។

### ២. *កម្រិតនៃភាពលម្អិតសមរម្យ*

៣០. *"(...) ការពុំមានភាពច្បាស់លាស់ គឺពុំមែនជាវិការៈធ្ងន់ធ្ងរឡើយនៅក្នុងសំណើទាមទារសំណង ប្រសិនបើសំណើបង្ហាញថាការផ្តល់សំណងដែលបានទាមទារនោះមានលក្ខណៈសមស្រប និង [អាចអនុវត្តបាន]"*[56]។ ប៉ុន្តែ *"សំណើទាមទារសំណងត្រូវតែផ្តល់នូវកម្រិតមួយដ៏សមហេតុផលនៃសេចក្តីលម្អិតដោយផ្អែកទៅលើលក្ខណៈនៃសំណើ"*[57]។ កម្រិតនៃភាពលម្អិតសមរម្យ គឺជាកម្រិតដែលអាចអនុញ្ញាតឲ្យតុលាការ *"ផ្តល់ទៅតាមសំណើ តាមរយៈផ្នែកសម្រេចសេចក្តីដែលអាចអនុវត្តបាន"*[58]។ ភាពលម្អិតដែលអាចមានប្រយោជន៍សម្រាប់តុលាការក្នុងការសម្រេចថា តើសំណើសុំសំណងមួយ អាចត្រូវបាន ឬ មិនត្រូវបានទទួលស្គាល់ មានដូចជា លក្ខណៈច្បាស់លាស់នៃសំណើ ខ្លឹមសារ រយៈពេល ការរៀបរាប់ពីធាតុផ្សំនៃសំណង ទីតាំងអនុវត្ត តម្លៃ បញ្ហាកម្មសិទ្ធិម្ចាស់ទីតាំងពាក់ព័ន្ធនឹងការអនុវត្ត[59]។

### ៣. ការសន្យារបស់រាជរដ្ឋាភិបាល និងកិច្ចសហប្រតិបត្តិការជាមួយតតិយជន

៣១. យោងតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក នៅពេលដែលសំណងមួយដែលត្រូវបានស្នើឡើង តម្រូវឲ្យមានការសន្យា និងកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ឬ របស់តតិយជន ហើយក្នុងករណីដែលអាចបង្ហាញថា ការសន្យា និងកិច្ចសហប្រតិបត្តិការនោះត្រូវបានធានា វានឹងពុំមានបញ្ហាក្នុងការទទួលស្គាល់គម្រោងនោះថាជាសំណងឡើយ[60]។ ប៉ុន្តែប្រសិនបើពុំបានឈានដល់ការព្រមព្រៀងនេះទេ ការទាមទារសំណងណាមួយដែល *"ទាំបាច់ឲ្យមានអន្តរាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកម្រិតដែលសំណើសុំនេះស្វែងរកទាំងស្រុងនូវវិធានការមួយដែលស្ថិតនៅក្នុងបុព្វសិទ្ធិរបស់រាជរ*

*ដ្ឋាភិបាល[នឹងត្រូវបដិសេធចោល]'*[61]។ សំណើសុំទាំងអស់នោះត្រូវបានបដិសេធដោយមូលហេតុថា"អាណត្តិរបស់ អ.វ.ត.ក មិនបានផ្តល់អំណាចឲ្យអង្គជំនុំជម្រះមានយុត្តាធិការលើរដ្ឋ ឬរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្គាប់ឲ្យគ្រប់គ្រងផែនការសំណងនោះទេ"[62]។ វិធាននេះក៏អនុវត្តផងដែរចំពោះតតិយជន ដែលការចូលរួមរបស់ពួកគេពិតជាចាំបាច់សម្រាប់អនុវត្តវិធានការសំណង[63]។

## IV. មូលដ្ឋាននៃសំណង៖ ការខូចខាតដែលបានទទួលរង

៣២. យោងតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក និងយុត្តិសាស្ត្រ វាតម្រូវឲ្យមានការបង្ហាញពីមូលដ្ឋានអង្គហេតុ និងកាលៈទេសៈនៃសំណង ស្របទៅតាមក្របខណ្ឌគតិយុត្តិដែលបានកំណត់។ ការទទួលស្គាល់ការខូចខាតដែលបណ្តាលមកពីការអនុវត្តឧក្រិដ្ឋកម្ម នឹងត្រូវពិនិត្យតាមរយៈការវិភាគលើផលវិបាកនៃឧក្រិដ្ឋកម្មទាំងអស់នោះមកលើដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ វានឹងឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវផ្លូវច្បាប់ដែលមានចែងក្នុងមាត្រា ២៣ ស្ទួនបួន (១)(ក) ។ ផលវិបាកនេះនឹងត្រូវពិនិត្យតាមរយៈសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់មកទៀត តាមរយៈការកត់សម្គាល់របស់អ្នកជំនាញ។

### ក. ផលវិបាកនៃឧក្រិដ្ឋកម្មមកលើដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៣៣. ក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីបានមានឱកាសថ្លែងអំពីផលវិបាក ព្យសនកម្ម ដែលពួកគាត់បានទទួលរងដោយសារការអនុវត្តអំពើឧក្រិដ្ឋ។ បន្ទាប់មកសវនាការចំនួនបួនថ្ងៃ បានទុកលទ្ធភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសផ្តល់សក្ខីកម្ម ជាពិសេសពាក់ព័ន្ធនឹងផលវិបាកដែលពួកគាត់បានទទួលរង។ តាមរយៈសក្ខីកម្មទាំងអស់នោះ ព្យសនកម្មប្លែកៗគ្នាជាច្រើន ត្រូវបានបង្កឡើងដោយអង្គហេតុដែលនឹងត្រូវធ្វើការបង្ហាញនាពេលនេះ។ ព្យសនកម្មទាំងអស់នោះ អាចជាព្យសនកម្មផ្លូវចិត្ត ផ្លូវកាយ និង/ឬ សម្ភារៈ។ ភាគច្រើន ព្យសនកម្មមានលក្ខណៈផ្សេងៗគ្នាក្នុងពេលតែមួយ ហើយការចាត់ថ្នាក់ព្យសនកម្មទាំងអស់នោះទៅតាមប្រភេទទាំងបីនោះ ទំនងជាមិនត្រឹមត្រូវ ឬ មានភាពរិតត្បិត ខណៈដែលព្យសនកម្មអាចគ្រប់ដណ្តប់ទិដ្ឋភាពផ្សេងៗគ្នាក្នុងពេលតែមួយ។ ព្យសនកម្មទាំងអស់នោះ ពាក់ព័ន្ធជាអប្បរមានឹងដំណាក់កាលទាំងពីរនៃការជម្លៀសប្រជាជនដោយបង្ខំ ដោយរាប់បញ្ចូលទាំងរយៈពេលអន្តរកាលនៃការជម្លៀសទាំងពីរលើក។ ទាំងនេះមិនមែនមានន័យថា ព្យសនកម្មទាំងអស់នោះមិនអាចមិនបណ្តាលមកពីអង្គហេតុទាំងអស់នោះទេ ប៉ុន្តែការឈឺចាប់ និងព្យសនកម្ម ពិតជាមិនអាចផ្តាច់ចេញពីគ្នាបានទេ[64]។

៣៤. ព្យសនកម្មទាំងអស់នោះនឹងត្រូវបង្ហាញជូន ដូចដែលត្រូវបានលើកឡើងជាច្រើនដងដោយដើមបណ្តឹងរដ្ឋប្បវេណី។

**១. ការក្បត់ទំនុកចិត្ត**

៣៥. ចាប់តាំងពីពេលជម្លៀសមក ទំនុកចិត្តរបស់ប្រជាជនកម្ពុជាត្រូវបានក្បត់ដោយពាក្យកុហករបស់ពួកខ្មែរក្រហម៖

៣៦. នៅពេលដែលខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ប្រជាជនមួយចំនួនបានទទួលពួកគេដោយក្តីរីករាយ និងពេលខ្លះប្រកបដោយសេចក្តីត្រេកអរ ដោយគិតថាពួកខ្មែរក្រហមនឹងនាំមកនូវសន្តិភាព និងឈានទៅបញ្ចប់នូវការរំលោភបំពាននានារបស់សង្គមចាស់៖

> *“ខ្ញុំចាំគឺនៅថ្ងៃទី ១៧ មេសា នៅពេលខ្មែរក្រហមចូលមកដល់ទីក្រុង យើងទាំងអស់គ្នាមានភាពសប្បាយរីករាយណាស់នៅពេលដែលឃើញមានការផ្លាស់ប្តូររបបបែបនេះ ព្រោះថាយើងនិយាយប្រាប់គ្នាថា យើងទទួលបានសន្តិភាពហើយ។ ខ្ញុំឃើញម្តាយខ្ញុំកាន់ទង់ជ័យសគ្រវី ហើយគាត់យើងទាំងអស់គ្នាស្រែកថាយើងលែងមានសង្គ្រាមហើយ យើងទទួលបានសន្តិភាពទាំងអស់គ្នាហើយ (...)។”*[65]

៣៧. ប៉ុន្តែ សំដីរបស់ពួកខ្មែរក្រហមបានប្រែក្លាយភ្លាមៗជាការគំរាមកំហែង ដោយបង្ខំឲ្យប្រជាជនចាកចេញពីផ្ទះជាប្រញាប់ ហើយភាគច្រើនជាការគំរាមដោយប្រើអាវុធ។ ប្រជាជនមានការភ័យរន្ធត់ជាខ្លាំង[66]៖

> *“ (...) ហើយប្រើកាំភ្លើងមកភ្ជង់លើក្បាលពួកខ្ញុំទាំងមើលងាយ មើលថោក ហើយមិនឲ្យពួកយើងខ្ញុំរៀបចំអីវ៉ាន់បានស្រួលបួលចេញដំណើរទេ។ ពេលនោះពួកវាមកដល់បន្ទប់របស់ខ្ញុំហើយ បានបាញ់រះ (...)”*[67]
>
> *“ (...) បានដេញឲ្យនាងខ្ញុំចាកចេញពីទីលំនៅដ្ឋាន ក្រុមគ្រួសារទាំងប៉ុន្មានប្រមូលចេញឲ្យអស់ ព្រោះគេរៀបចំក្រុង។ នាងខ្ញុំសូមអង្វរថាកុំអាលអី ខ្ញុំចាំក្តីចាំខ្ញុំធ្វើដំណើរទៅ ឥឡូវនេះយប់ហើយ សូមអង្វរសូមអាណិតមេត្តា កុំធ្វើបាបខ្ញុំ ខ្ញុំយកអីវ៉ាន់ទាន់ទេ ស្រវាអីក៏អត់បានដែរ។”*[68]

៣៨. ដោយចាញ់បោកពាក្យកុហកថានឹងអាចត្រលប់មកផ្ទះវិញនៅរយៈពេលបីថ្ងៃខាងមុខ ប្រជាជនមិនបានយកសម្ភារៈឲ្យបានគ្រប់គ្រាន់សម្រាប់ការដើរជាច្រើនថ្ងៃ និងដោយមិនមានជំនួយឡើយ[69]៖

*"មនុស្សច្រើនកុះករត្រូវធ្វើដំណើរនៅក្នុងរដូវក្តៅ ខែមេសា ក្តៅណាស់ លោកប្រធាន។ កាលណាថ្ងៃត្រង់ គឺកៅស៊ូហៀរចេញមក ហើយបងប្អូនដែលជម្លៀសចេញភ័យតក់ស្លុត អត់បានយកស្បែកជើង អត់បានយកអីតាម។ ដូច្នេះមានសភាពមួយថ្មីមិនដែលជួបប្រទះ គឺត្រូវពងជើង ខ្លះយកស្រទបចេកទៅចងទៅនឹងបាតជើង (...)"*[70]

*"ពេលនោះ ខ្ញុំគ្មានបានយកអ្វីឲ្យបានគ្រប់គ្រាន់ច្រើនទេ ពីព្រោះខ្ញុំមានតែបីនាក់នឹងកូន។ ដូច្នេះខ្ញុំយកបានតែខោអាវមួយសម្រាប់ម្នាក់សម្រាប់កូន ហើយនិងប្រដាប់ប្រដាសម្រាប់កូនខ្ចី មានទឹកដោះគោ មានដបទឹកដោះគោ ដបទឹកដាក់នៅក្នុងកាតាបខ្មៅមួយដែលខ្ញុំច្រើនតែយួរទៅសាលារៀនដាក់សម្ភារៈទៅសាលារៀន។ ហើយពេលនោះ ខ្ញុំត្រូវតែចេញជាប្រញាប់ ពីព្រោះយោធាខ្មែរក្រហមបានបណ្តេញរន្ទាន់ៗថា ឲ្យចេញឲ្យយ៉ាងឆាប់ ហើយថាសហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះ។"*[71]

៣៩. ការចាកចេញដោយប្រញាប់ប្រញាល់ និងស្ថិតក្នុងស្ថានភាពភ័យខ្លាចបែបនេះ បាននាំឲ្យសមាជិកគ្រួសារមួយចំនួនបែកខ្ញែកគ្នា ឬវង្វេងបាត់គ្នាតែម្តង ដូចដែលជនរងគ្រោះមួយចំនួនបានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន[72]។ កុមារគឺជាជនរងគ្រោះទីមួយ និងបានស្ថិតក្នុងស្ថានភាពប្រញាប់ប្រញាល់ក្នុងសភាពភ័យខ្លាច។

**ខ.** ប្រជាជនបានបោះបង់ចោលផ្ទះសម្បែង និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងរបស់របរជាទីស្រឡាញ់មួយចំនួនទៀត ដែលធ្វើឲ្យពួកគេបាត់អស់នូវ**អតីតកាល ព្រឹត្តិការណ៍ផ្សេងៗ និងអនុស្សាវរីយ៍របស់ពួកគេ**[73]៖

*"យើងគ្មានបានយកស្អីមកច្រើន យើងយកតែបន្តិចៗ ព្រោះគេប្រាប់យើងថាតែបីថ្ងៃ ឲ្យយើងចូលទៅវិញ។ អ៊ីចឹងយើងយកបានស្អីបានដែលយួរបាន កាន់បាន យើងយកមក។ យើងអត់បានយកស្អីដែលជាច្រើនធ្ងន់ធ្ងរសម្រាប់ទុកមុខថ្ងៃក្រោយច្រើនថ្ងៃអី អត់មានទេ។"*[74]

ទ្រព្យសម្បត្តិខ្លះត្រូវបានរឹបអូស៖

*"គេហូតឡានចេញ គេយកឡាន ឲ្យឡានទៅ ខ្មែរក្រហមម្នាក់ហ្នឹង គេសម្តែងថាគេអ្នកចេះបើកឡានហ្នឹង យកកូនសោចុចភ្លាម ឡានហ្នឹងស្ទើរទៅបុកដើមឈើកំពិតមុខឡានហ្នឹងខូចអស់រលីងចាស។"*[75]

៤០. ពេលខ្លះ ដើមបណ្តឹងរដ្ឋប្បវេណីរក្សាទុកបានត្រឹមតែរូបថតមួយសន្លឹក ឬមួយចំនួនប៉ុណ្ណោះ សម្រាប់ទុកគ្រាន់ធ្វើជាអនុស្សាវរីយ៍នូវអតីតកាលរបស់ខ្លួន ឬសាច់ញាតិដែលបានបាត់បង់ជីវិត។

*"តើរូបថតទាំងអស់នេះ ជាទ្រព្យសម្បត្តិដែលសល់តែមួយគាត់ ដែលសល់ពីរបបខ្មែរក្រហមហ្នឹង ឬក៏យ៉ាងម៉េចចំពោះអ្នកស្រី ? ឆ្លើយ៖ ខ្ញុំខំរក្សារូបថតនេះណាស់ ព្រោះថាខ្ញុំគ្មានអ្វីផ្សេងទៀតទេ។ ខ្ញុំបានដាក់ចូលក្នុងថង់ផ្លាស់ស្ទិក ដាក់លាក់កប់ទៅក្នុងដី (...)។"*[76]

*"តើលោកស្រីមានរូបថតកូនលោកស្រីដទៃទៀតទេ នៅថ្ងៃនេះ ? ឆ្លើយ៖ ចាស ខ្ញុំអត់មានទេ ខ្ញុំមានតែរូបថតមួយនេះហើយ ដែលខ្ញុំបានផ្ញើមកប្តីខ្ញុំមុនខ្មែរក្រហមចូលទីក្រុងភ្នំពេញចំនួនមួយអាទិត្យ។ ខ្ញុំផ្ញើរូបថតនៅពេលដែលកូនស្រីខ្ញុំចេះក្រឡាប់ ខ្ញុំផ្ញើមកប្តីខ្ញុំនៅសហរដ្ឋអាមេរិក។ ដូច្នេះហើយបានសល់តែរូបថតមួយនេះ រីឯរូបថតកូនពីរនាក់ទៀត គឺគ្មានទេ។ ពួកខ្មែរក្រហមបានកម្ទេចគ្មានសល់អ្វីឡើយ។"*[77]

៤១. ពេលខ្លះ អ្វីៗទាំងអស់ត្រូវបានបំផ្លាញនៅពេលដែលពួកខ្មែរក្រហមចូលមកដល់ ជាពិសេស ឯកសារបញ្ជាក់អត្តសញ្ញាណ ឬ រូបថតផ្សេងៗ ដែលនាំឲ្យជនរងគ្រោះបាត់បង់នូវអត្តសញ្ញាណរបស់ខ្លួន[78]។

**៣. ភាពស្រេកឃ្លាន**

៤២. ក្នុងចំណោមភាពរងទុក្ខវេទនាផ្លូវកាយដែលបណ្តាលមកពីការជម្លៀស និងការដើរផ្លូវឆ្ងាយដ៏សែនលំបាក ដែលតម្រូវសម្រាប់អ្នកទីក្រុងទាំងអស់គ្នា ភាពស្រេកឃ្លានបានកើតមានមកលើប្រជាជនជម្លៀសភាគច្រើន ហើយការជម្លៀសនោះទៀតត្រូវបានធ្វើឡើងក្នុងរដូវប្រាំង[79]៖

> *" (...) ហើយមានសភាពក្តៅណាស់ក្នុងរយៈខែនោះ គឺខែក្តៅណាស់។ ខ្ញុំក៏ធ្វើដំណើរទៅតាមការដេញរបស់យោធាខ្មែរក្រហមដែលដេញ ដែលបាញ់កាំភ្លើងទៅឡើងលើឲ្យទៅៗ។ ខ្ញុំធ្វើដំណើរបន្តិចមួយជំហានៗយ៉ាងៗពិបាក ហើយយ៉ាងក្តៅស្ទុះស្លាប់ជាមួយកូនខ្ញុំទាំងបី។"*
> *« (…) On était en pleine saison chaude et nous devions marcher en plein soleil. … Nous avons continué à avancer très lentement en pleine chaleur. (…) »*[80]
> *"នៅជិតភូមិខ្វារហ្នឹង ក៏ឡើងទៅចង្កៀតពេញទាំងអស់ឡាននោះ។ កូនខ្ញុំស្រេកយ៉ាងណាក៏មិនបាន ហើយហូបតែទឹកក៏អត់មាន ហើយប្រដាប់ប្រដា មុង កន្ទេល ឆ្នាំងចានអី ក៏អត់ដែរឡើងទៅតែខ្លួន។'*[81]
>
> *"ឆ្លើយ៖ រូបកាយខ្ញុំទ្រុឌទ្រោមយ៉ាងខ្លាំង អត់បាយអត់ទឹក គ្មានពេលសម្រាក មានជំងឺគ្រុនរងា គ្មានថ្នាំលេប ធ្វើដំណើរទាំងយប់ទាំងថ្ងៃ (...)'*[82]

## ៤. ព្រឹត្តិការណ៍ភ័យរន្ធត់

៤៣. ប្រជាជនជម្លៀសបានឃើញនូវ**ព្រឹត្តិការណ៍រន្ធត់ជាច្រើន**៖ សាកសពត្រូវបានគេបោះបង់ចោលនៅតាមសងខាងផ្លូវ មនុស្សចាស់ៗកំពុងដេកស្លាប់ដោយគ្មានជំនួយ[83]៖

> *"ឆ្លើយ៖ ចាស ការដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្ញុំបានជួបប្រទះនូវរឿងហេតុយ៉ាងច្រើន។ ត្បិតអីថ្ងៃនោះពេលចេញហ្នឹង ព្រលឹមឡើងគឺធ្វើដំណើរចេញតែម្តង។ ពេលដែលចេញហ្នឹងឃើញមានអ្នកស្លាប់តាមផ្លូវថ្នល់ហ្នឹង គឺអ្នកស្លាប់ច្រើន ហើយកណ្តាលថ្នល់ក៏មានអ្នកស្លាប់ កៀនតាមចិញ្ចើមថ្នល់ហ្នឹងក៏មានអ្នកស្លាប់ ហើយក៏មានអ្នកដេកដែលមិនទាន់ស្លាប់ ដូចជាចាស់ជរា មានយាយ មានតា មានជនពិការ មានអ្នកស្វិតជើង ស្វិតដៃអ៊ីចឹង។ មិនដឹងជាអ្នកណាគេដាក់ចោលទេ ប៉ុន្តែឃើញតែដេកតាមចិញ្ចើមថ្នល់អ៊ីចឹងទៅ ខ្លះក៏ជិតស្លាប់ ខ្លះក៏ស្លាប់បាត់បង់ជីវិតហើយ អ្នកខ្លះក៏នៅអង្គុយដោយអត់អាហារ ហើយគ្មានដូចថា ថ្ងៃក្តៅខ្លាំង ហើយទឹកភ្នែកហូរហៅកូន ហៅអីអ៊ីចឹង ប៉ុន្តែមិនដឹងថា ក្រុមគ្រួសារគេនៅឯណាទេ គ្រាន់តែឃើញសភាពបែបហ្នឹង ហើយមានតាចាស់ម្នាក់ ខ្ញុំសង្វេគក្នុងចិត្តដល់សព្វថ្ងៃ ឃើញគាត់ដេក ហើយគាត់បើកភ្នែកសម្លឹងមើលខ្ញុំ ហើយមានបាយមួយចាន ទឹកមួយកំប៉ុងវីហ្គោនៅក្បែរក្បាលដេកគាត់។ ហើយស្រមោចចូលខាំត្រចៀកគាត់ពេលហ្នឹង ខ្ញុំអែអង់ទាញសម្រែកម៉ាក់យាយខ្ញុំបែរមើលគាត់ហ្នឹង ឃើញមានស្រមោចចូលខាំគាត់ ខាំភ្នែក ខាំត្រចៀកគាត់ហ្នឹង ហើយក្នុងចិត្តរបស់ខ្ញុំ ក្នុងអារម្មណ៍របស់ខ្ញុំហ្នឹងដូចថា ឃើញបែបហ្នឹង ខ្ញុំដើរបណ្តើរខ្ញុំយំបណ្តើរ។ ហើយពេលដើរទៅទៀត ក៏ឃើញមានអ្នកស្លាប់ និយាយទៅឃើញអ្នកស្លាប់បន្តបន្ទាប់តាមផ្លូវតែរហូត អត់មានថាអត់ឃើញទេ។ ហើយបើមិនអ៊ីចឹងបានថា ឲ្យខ្ញុំដើរទៅជាន់ខ្មោច ពារខ្មោច ជំពប់ខ្មោចដួលហ្នឹងដោយក្តីសង្វេគណាស់ ខ្ញុំពេលនោះ។"[84]*

*"ពេលនោះ ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំងដោយសារឃើញមិត្តភក្តិខ្ញុំឈាមពេញខ្លួនៗ ខ្ញុំក៏សួរទៅគេរំលោភ ហើយប្រើអំពើហិង្សា យកផ្លែគ្រាប់ទៅញាត់ចូលក្នុងរន្ធគូថទៀត ។ ពេលនោះ ខ្ញុំរន្ធត់ខ្លាំងពេក ខ្ញុំក៏បានដើរចេញទៅ។"*[85]

a. ស្ត្រីមានផ្ទៃពោះកំពុងសម្រាលកូន កុមារតូចៗស្រែកយំ ឬ ត្រូវបែកពីឪពុកម្តាយ អ្នកជំងឺមិនអាចធ្វើដំណើរបាន[86]៖

*"អ្នកខ្លះមានផ្ទៃពោះគ្រប់ខែ ឆ្លងទន្លេតាមផ្លូវ ពេលឆ្លងទន្លេហើយ ត្រូវពួកវាបង្ខំឱ្យបន្តដំណើរទៅមុខទៀត ដោយមិនអាចទ្រាំបាន អ្នកឆ្លងទន្លេក៏ដាច់ខ្យល់ស្លាប់តាមផ្លូវទាំងម្តាយ និងកូន អ្នកខ្លះទៀតឆ្លងទន្លេហើយ ទុកកូនចោល ស្រមោចរោមឡើងខ្មៅ។"*[87]

*"ពេលដែលចេញពីផ្ទះហ្នឹង នៅខាងស្តាំដៃហ្នឹង ត្រើយខាងស្តាំហ្នឹង មានឃើញស្ត្រីម្នាក់ រលូតកូន មិនមែនកើតកូនទេ។ គឺបែបគាត់ដើរហ្នឹង វាយ៉ាប់ពេកទៅ វាអាររលូតកូនតាម ផ្លូវ។ រួចខ្ញុំមិនបានធ្វើឃើញផងទេ កូនអីវាថា "អូ! អាណិតណាស់" ខ្ញុំប្រាប់កូន "កូន អើយ! កុំមើល កុំអី។ មកយើងប្រុងតែដើរទៅ"។ ហើយទាំងអស់គ្នាហ្នឹង អត់បាននៅ មើលអីទេ អ្នកដែលដើរតាមផ្លូវហ្នឹង អត់ៗមានអ្នកណាបានជួយអីទេ មិនដឹងជាមនុស្ស រលូតកូនហ្នឹង វាវាសនាយ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរ។"*[88]

*"ស្ត្រីទើបកើតកូនថ្មីៗ កូនក្រហមរងាលត្រូវគេឱ្យចេញដើរហាលភ្លៀងផូរ។"*[89]

*"(...) ច្របូកច្របល់ មិនដឹងជាកូន មិនដឹងជាចៅ ម៉ែឪឯណាទេ ពេលយប់ងងឹតមិនអាចមើលអ្វីឃើញទេចាសពេលនោះ។ ក៏ឡើងឡានបែកគ្នា ខ្លះក៏បែកកូន ខ្លះក៏បែកចៅទៅពេលនោះ។"*[90]

*"មានក្មេងខ្លះយំស្រែករង្វេងបាត់ម្តាយឪពុក គួរឱ្យអាសូរ។"*[91]

៤៤. ប្រជាជនជម្លៀស បានឃើញព្រឹត្តិការណ៍ហិង្សា និងការកាប់សម្លាប់មនុស្ស[92] ដែលស្ថិតក្នុងក្រុមមួយចំនួន៖

*"ឆ្លើយ៖ ចាស សាកសពនោះមានសព្វគ្រប់ ទាំងប្រជាជន ទាំងទាហាន លន់ នល់ ទាំងព្រះសង្ឃ។ ប្រជាជនពោះធំរុញរទេះចេញពីភ្នំពេញមក រុញឈើរទេះ អ្នកខ្លះរបួស អ្នកខ្លះអី មានស្លាប់តាមផ្លូវជាហូរហែ។"*[93]

*"ហើយខ្ញុំបានចេញហួសព្រែកព្នៅ ទៅដល់ឆ្ងាយហើយ អាហ្នឹងខ្ញុំភ្លេចកន្លែងហើយ ឃើញ ទាហាន លន់ នល់ និងមនុស្សជនស៊ីវិលហ្នឹងស្លាប់ទាំងខោទាំងអាវដេកនៅក្នុងបន្លាលួស ក្នុងក្បែរផ្លូវផ្ទល់ជាច្រើន ហើយមនុស្សឈឺជាច្រើនដែរ មានចាស់ មានក្មេង ហូរហែដល់ ព្រែកក្តាមហ្នឹង។ (...) បាទ ពេលពួកខ្មែរក្រហមសួរពីប្រវត្តិរូបខ្ញុំហ្នឹង ខ្ញុំនឹកឃើញ សាកសព ឃើញស្លាប់តាមផ្លូវច្រើន ខ្ញុំភ័យណាស់។ ភ័យខ្លាំង ញ័រដៃ ញ័រជើង ហើយនឹក ក្នុងចិត្តថា មិនដឹងដល់កន្លែងណាស្លាប់ទៀតទេ ។ ហើយចេះតែដើរៗ ស៊ូទ្រាំទាំងភ័យ ទាំងខ្លាចហ្នឹងទៅ។"*[94]

## ៥. ការព្រាត់ប្រាសគ្នា និងការបាត់ខ្លួន

៤៥. ក្នុងអំឡុងពេលធ្វើដំណើរ ឬនៅពេលទៅដល់គោលដៅហើយនោះ ស្ថានភាពសម្ភារៈ និងគ្រួសាររបស់ជនរងគ្រោះត្រូវបានបំផ្លាញទាំងស្រុង។ អ្នកខ្លះបានបែកខ្ញែកគ្នា ហើយរហូតមកដល់សព្វថ្ងៃនេះ ពួកគេនៅតែមិនទាន់បានដំណឹងអ្វីពីសាច់ញាតិរបស់ខ្លួននៅឡើយ[95]៖

*"ឆ្លើយ៖ ចាស ការដែលខ្ញុំបាត់បង់ជីដូនជីតា សាច់ញាតិយ៉ាងច្រើន ក្រុមគ្រួសារ បាត់បង់ នោះខ្ញុំអត់បានដឹងថា គាត់បាត់បង់របៀបគេយកទៅសម្លាប់ ឬមួយក៏គេបង្អត់អាហារ ស្លាប់ទេ។"*[96]

*"ពេលដែលនោះ គឺជម្លៀសចេញហ្នឹង គឺដេញយកមែនទែន។ មុនដំបូងថា ឲ្យចេញទៅ មួយរយៈទេ ចាំគេរៀបចំភ្នំពេញឲ្យវាស្រួលបួលសិន បានគេឲ្យចូលវិញ។ ក៏ខ្ញុំក៏ចេញដើរទៅហ្នឹង ទៅស្វែងរក ព្រោះឪខ្ញុំ ម្តាយខ្ញុំហ្នឹងចេញទៅមុននោះ។ គាត់មុននឹងចេញទៅហ្នឹង គាត់ថាឲ្យរកតាមផ្លូវមាត់ទន្លេទៅឃើញហើយ។ ក៏ខ្ញុំចេញទៅហ្នឹង ទៅអត់ឃើញគាត់ទេ ដើររកទៅតាមមាត់ស្ទឹងហ្នឹងឃើញតែខ្មោច។ ជួបខ្មោច ជួបអីហ្នឹងតាមផ្លូវ។"*[97]

៤៦. អ្នកខ្លះបានបាត់បង់សាច់ញាតិដោយមិនដឹងមូលហេតុ ដូចដែលមានរៀបរាប់ខាងក្រោម ដោយដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលគាត់ទើបតែមានអាយុ ១០ឆ្នាំ នៅពេលដែលអង្គហេតុបានកើតឡើង។ គាត់បាននិយាយពីឪពុកគាត់ ដូច្នេះថា៖

*"ទៅដល់ប្រហែលដប់ថ្ងៃ មានកម្មាភិបាលខ្មែរក្រហមម្នាក់បានមកហៅគាត់ឲ្យទៅនោះមួយភ្លែត។ រួចហើយក៏បាត់ដំណឹងឈឹងរហូត។ នៅពេលនោះប្រហែលជាម៉ោងប្រាំមួយល្ងាច មិនឃើញគាត់មក ទៅតាំងពីព្រឹក ម្តាយខ្ញុំយំ ខ្ញុំក៏យំតាមគាត់។ ក្រោយមកប្រហែលជាបួនប្រាំថ្ងៃ*

*ឮដំណឹងថាយកទៅរៀនសូត្រ។ (...) ក្រោយមកឮដំណឹងថា គេយកម្ដាយ និងបងប្អូនខ្ញុំទៅសម្លាប់អស់ទៀត។ ខ្ញុំគ្រាន់តែឮដំណឹងនេះភ្លាម ខ្ញុំសឹងតែរត់ទៅដល់ទីនោះភ្លាមដោយរន្ធត់ចិត្តយ៉ាងខ្លាំង។ ពេលនោះជីដូនខ្ញុំឃាត់ ខ្ញុំបានត្រឹមតែសម្លឹងមើលពីចម្ងាយដោយស្រក់ទឹកភ្នែកយ៉ាងក្ដុកក្ដួល។ ចាប់ពីថ្ងៃនោះមក ទោះជីដូនខ្ញុំខំលួងលោម អង្វរកចិត្តខ្ញុំ ក៏ខ្ញុំនៅតែដេកយំ។”*[98]

លើសពីនេះ៖

*“រហូតតាំងពីពេលនោះមក លោក ចៅ សៅ បាត់ខ្លួនរហូតដល់ពេលនេះ។ ខ្ញុំចង់សួរលោកអ៊ី ខៀវ សំផន ថា តើគាត់ស្លាប់នៅទីណា? នៅពេលនេះ គាត់ស្លាប់នៅទីណា? ខ្ញុំចង់សួរដឹងតែប៉ុណ្ណឹង ដើម្បីខ្ញុំទៅរកសាកសពគាត់យកមកធ្វើបុណ្យតាមប្រពៃណីជាតិរបស់ខ្មែរទេ។”*[99]

## ៦. អំពើអមនុស្សធម៌ និងប្រមាថមើលងាយ និងអារម្មណ៍របស់អ្នកនៅរស់ ថាបានប្រព្រឹត្តកំហុស

៤៧. ការជម្លៀសអ្នកទីក្រុងដោយបង្ខំ គឺជាជំហានទីមួយនៃនយោបាយរើសអើង។ អ្នកទីក្រុងបានក្លាយជាកម្មវត្ថុនៃអំពើអមនុស្សធម៌ ចាប់តាំងពីពេលដែលពួកគេត្រូវបានជម្លៀសមកម្ល៉េះ[100]។ កុមារតូចៗបានឃើញពីអំពើថោកទាប និងប្រមាថមើលងាយ ប្រព្រឹត្តមកលើឪពុកម្ដាយរបស់ពួកគេ ដូចដែលជនរងគ្រោះជាច្រើនបានរៀបរាប់។ យើងអាចលើកឡើងដូចជា៖

> *“(...) ហើយខ្ញុំឃើញឪពុកខ្ញុំ គេឱ្យគាត់ទាញអូសនង្គ័លជំនួសឱ្យគោក្របី។ ហើយឃើញឪពុកខ្ញុំហ្នឹងដូចជាចាស់ជាងអាយុដល់ទៅដប់ឆ្នាំ -- ចាស់ជាងអាយុដប់ឆ្នាំទៅទៀត គ្រាន់តែធ្វើការបានប៉ុន្មានថ្ងៃហ្នឹងទៅ។ ថាការងារហ្នឹងគឺថាមិនអាចទ្រាំទ្របានទេ (...) នេះជារូបភាពមួយដែលគួរឱ្យរន្ធត់ ហើយខ្ញុំក៏មិនចង់ស្រមៃឃើញរូបភាពហ្នឹងឡើងវិញទៀតដែរ។”*[101]

៤៨. ការគោរពឪពុកម្ដាយ និងជីដូនជីតា គឺជាគោលការណ៍គ្រឹះមួយនៅក្នុងគ្រួសារខ្មែរ ហើយការប៉ះទង្គិច ដែលបង្កឡើងដោយការឃើញឪពុកម្ដាយរបស់ខ្លួនត្រូវគេប្រមាថមើលងាយ និងធ្វើឱ្យទន់ខ្សោយ ផ្ទុយពីភាពថ្លៃថ្នូរជាមនុស្ស គឺពិតជាមានច្បាស់ណាស់។

អ្នកខ្លះបានឃើញឪពុកម្ដាយរបស់ខ្លួនស្លាប់ដោយសារអត់បាយ ជំងឺ និងការធ្វើបាបផ្សេងៗ៖

> *“(...) ការឈឺចាប់របស់ខ្ញុំដែលបំភ្លេចមិនបានសោះ គឺអាណិតឪពុកដែលជាអ្នករកស៊ីចិញ្ចឹមខ្ញុំតាំងពីខ្ញុំវ័យក្មេងរហូតដល់ធំ គេចាក់ថ្នាំសម្លាប់ប្រកាច់នៅលើគ្រែ ហើយចេញឈាមពេញគ្រែហ្នឹងទាំងអស់ (...)”*[102]

*“ឆ្លើយ៖ នៅក្នុងតុលាការនេះ គឺថាអ្វីដែលខ្ញុំនឹកឃើញដំបូងហ្នឹង គឺថាម្ដាយខ្ញុំតែម្ដង ។ ខ្ញុំ មិនអាចទទួលស្គាល់ថាគាត់កំពុងស្លាប់នោះទេ។ ខ្ញុំរូបថា -- រូបគាត់នេះកំពុងតាមខ្ញុំរហូត។ កាលនុងគាត់ឃ្លានខ្លាំង ហើយយើងកាលណោះ យើងទៅសហករណ៍ហ្នឹង ទៅ -- ហើយគាត់កាន់ចានមួយដើម្បីសុំម្ហូប បបរអីហ្នឹង ដល់គាត់ស្គមពេកអស់កម្លាំង ចានហ្នឹងក៏ធ្លាក់ហ្នឹងទៅ គាត់ក៏ប្រវេប្រវាដើម្បីរកអង្ករបាយហ្នឹងឡើងវិញនេះ ។”*[103]

៤៩. ផលវិបាកមួយនៃព្រឹត្តិការណ៍នេះ គឺថាមនុស្សមួយចំនួនមានអារម្មណ៍ថាខ្លួនមានកំហុស[104] ហើយសព្វថ្ងៃ ពួកគេបានស្ដីបន្ទោសខ្លួនឯងថាមិនបានធ្វើអ្វីមួយនៅពេលនោះដើម្បីសង្គ្រោះឪពុកម្ដាយរបស់ពួកគេ៖

*“នៅក្នុង គាត់ស្លាប់នៅក្នុងលក្ខខណ្ឌ ដូចយើងមិន -- ថាវាហួសពីៗសត្វធាតុនោះទៀត គឺថាវាក្នុងលក្ខខណ្ឌមួយដែលថាខ្ញុំមិនអាចរកពាក្យណាមកពិពណ៌នាពីលក្ខខណ្ឌនេះបានទេ។ ខ្ញុំ -- គាត់ គេទម្លាក់គាត់ចូលក្នុងរណ្ដៅដោយគ្មានអ្វីទាំងអស់ ហើយខ្ញុំមិនដឹងថាគេទម្លាក់គាត់នៅក្នុងរណ្ដៅកន្លែងណានោះទេ។ យើង -- អ៊ីចឹងខ្ញុំមាន -- រាល់ថ្ងៃនេះ ខ្ញុំស្ដីបន្ទោសខ្លួនឯងដែលមិនអាចដឹងថាគាត់នៅកន្លែងណា។ ដែលមិនអាចជួយសង្គ្រោះជីវិតរបស់គាត់បាន។ បើកាលនោះ បើខ្ញុំក្លាហានជាងនេះវិញនោះ ខ្ញុំមុខប្រហែលជាអាចលួចស្រូវ លួចស្អីៗសព្វបែបយ៉ាងដើម្បីឲ្យគាត់មានអាហារហូបចុក ប្រហែលជាដល់ពេលនេះ ប្រហែលជាគាត់អាចនៅរស់ក៏ថាបានដែរ ។”*[105]

៥០. នៅពេលអ្នកដែលប្រជាជនជម្លៀស ត្រូវបានបង្ខំឲ្យគេត្រួតពិនិត្យ និងបន្ទាប់មកត្រូវធ្វើប្រវត្តិរូបទៀតនោះ ពួកគាត់ត្រូវបង្ខំចិត្តកុហកដើម្បីរួចផុតពីទណ្ឌកម្ម ឬការស្លាប់។

*“តាមផ្លូវហ្នឹង វាចេះតែតាមដានគ្រួសារខ្ញុំហ្នឹង វាសួរប្ដីខ្ញុំធ្វើអី ស្អី វា -- ហើយវាសួរថា “មឹងឯងធ្វើការអីដែរ?” ហើយខ្ញុំហ្នឹងភរវា ខ្ញុំថា “ខ្ញុំអត់ធ្វើអីទេ”។ “និយាយឲ្យត្រង់ណា? ធ្វើអីៗប្រាប់មក? ហើយប្ដីហ្នឹងធ្វើអី ធ្វើការអីៗស្អី” នាំគ្នាហ្នឹងលាក់ មិននិយាយប្រាប់ត្រង់ទេ។ វាថា “អើយ! ចាំមើលទៅ បដិវត្តន៍គេរកឃើញហ្នឹង មឹងឯងហ្នឹងមិនរួចខ្លួនទេ។””*[106]

*"(...) ទាហានខ្មែរក្រហមបានឱ្យខ្ញុំធ្វើប្រវត្តិរូបដូចគ្នា ប៉ុន្តែដោយខ្ញុំឃើញមានប៉ូលីស ទាហានស្លាប់ច្រើន ឬក៏ចាប់យកទៅបាត់ច្រើន។ ខ្ញុំក៏កុហកគេថា ជាភ្នាក់ងារបម្រុងវដ្តការ។"*[107]

## ៧. ការបាត់បង់សាច់ញាតិជាច្រើន

៥១. នៅក្នុងការជម្លៀសដោយបង្ខំទាំងពីរដំណាក់កាល និងរយៈពេលអន្តរកាលដែលមិនអាចកាត់ផ្តាច់បាន ជនរងគ្រោះភាគច្រើនបានមើលឃើញសាច់ញាតិរបស់ខ្លួនស្លាប់ ពីព្រោះពួកគេមិនអាចទ្រាំទ្រនឹងលក្ខខណ្ឌជីវិត និងការងារបាន[108]៖

*"(...) ការទុក្ខសោកដែលខ្ញុំឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ បើរៀបរាប់ទៅវាមិនអស់មិនហើយទេ។ ក៏ប៉ុន្តែការទុក្ខសោកដែលខ្ញុំបាត់បង់បងប្អូន គ្រួសារនៅក្នុងរបបនោះ គឺការឈឺចាប់រហូតមកដល់សព្វថ្ងៃនេះ គឺនៅតែការឈឺចាប់នឹកឃើញ។ កាលពីមុនខ្ញុំខំបំភ្លេចដែរតាំងពីឆ្នាំ៧៩ រហូតមកដល់ឆ្នាំ៨៥, ៨០ក៏ខ្ញុំបំភ្លេច ខំបំភ្លេច ដើម្បីកុំឱ្យនឹកឃើញរឿងដែលអតីតកាល រហូតមកដល់មានតុលាការ រដ្ឋាភិបាលបង្កើតតុលាការកូនកាត់មានអង្គការសហប្រជាជាតិនិងជាតិ បង្កើតតុលាការនេះឡើង ធ្វើឱ្យខ្ញុំនឹកឃើញដែលការឈឺចាប់របស់ខ្ញុំជាមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះហើយ បងប្អូនខ្ញុំពីជំនាន់មុន ឪពុកធំ ឪពុកមា បងប្អូនអីហ្នឹង គាត់សុទ្ធតែអ្នកមានមុខមាត់នៅក្នុងការងាររដ្ឋាភិបាលកម្ពុជា។ ក្រោយពីថ្ងៃ១៧ មេសា មករហូតមកដល់ឆ្នាំ៧៩ កងទ័ពរដ្ឋាភិបាលបានរំដោះមក។ ខ្ញុំបាត់អស់បងប្អូនក្រុមគ្រួសារអស់រលីង។ ហេតុដូច្នេះហើយ ការឈឺចាប់របស់ខ្ញុំនៅតែឈឺចាប់ គ្មានពេលណាស្រាក។"*[109]

ពួកគាត់បានរៀបរាប់ពីការបាត់បង់ប្អូនស្រីម្នាក់៖

*"ឆ្លើយ៖ ចាសបាទ។ ប្អូនស្រីរបស់ខ្ញុំត្រូវមានជំងឺគ្រុនក្តៅ ហើយពងបែករលាកពេញខ្លួន។ តែអត់មានអ្នកណាមើលថែ ហើយក៏គ្មានថ្នាំព្យាបាល។ ពេលនោះក៏ប្អូនខ្ញុំនៅឈឺរ៉ាំរ៉ៃ ឈឺរហូតស្គម មានតែស្បែកដណ្តប់ឆ្អឹង ហើយត្រូវដាក់ក្នុងអង្រឹងចោល ដោយគ្មានអ្នកមើលថែ។ ពេលនោះក៏អាហារ ក៏គ្មាន សូម្បីតែបបរយកទៅបញ្ចុកប្អូនក៏អត់មាន។ អ៊ីចឹងធ្វើឱ្យប្អូនឈឺធ្ងន់ទៅៗ រហូតដល់អ្នកម៉ែយកប្អូនស្រីទៅពេទ្យ។ គិតថាទៅពេទ្យហ្នឹងប្រហែលជាមានថ្នាំអត់ព្យាបាលបាន ប៉ុន្តែអត់មានថ្នាំព្យាបាលទេពេលនោះ ធ្វើឱ្យប្អូនស្រីខ្ញុំស្លាប់តែម្តង។"*[110]

ការបាត់បង់ប្អូនប្រុសម្នាក់៖

*"តែទីកទីបញ្ចប់ ប្អូនប្រុសពៅខ្ញុំមួយហ្នឹង ខ្ញុំមានប្រុសពៅមួយអាយុប្រាំបីឆ្នាំ។ ពេលហ្នឹង គេប្តូរសមរភូមិ ខ្ញុំត្រូវដើរកាត់ភូមិ ខ្ញុំក៏សុំគេចូលទៅមើលប្អូនបន្តិច។ ពេលទៅដល់ហ្នឹង ខ្ញុំឃើញប្អូនខ្ញុំ គេឈឺដេកនៅនឹងកន្ទេលហ្នឹង។ វាគ្រាន់តែឃើញខ្ញុំ ខ្ញុំស្រែកថា "បងអើយៗ បងឯងមកហើយអី បងឯងមកវិញ បងឯងមានបាយទេ? ឲ្យខ្ញុំសុំបាយញ៉ាំតែមួយម៉ាត់ទេ បង ខ្ញុំងាប់ទៅខ្ញុំបិទភ្នែកជិតហើយ"។ អស់លោក ខ្ញុំគ្មានទេ ខ្ញុំគ្មានស្អីទេ។ ឲ្យខ្ញុំធ្វើម៉េច បើខ្ញុំគ្មាន សូម្បីតែខ្លួនខ្ញុំគ្មានផង តើខ្ញុំមានស្អីដែលខ្ញុំយកទៅឲ្យប្អូនខ្ញុំ។ រួចហើយប្អូនខ្ញុំក៏ ស្លាប់ទៅ"*[111]

និងការបាត់បង់បងប្អូនទាំងអស់របស់គាត់៖

*"បងប្អូនខ្ញុំហូបបាយអត់ឆ្អែត យប់ឡើងដេកអង្គុយត្រមោង ហើយគាត់និយាយថា ខ្ញុំខ្លោច ចិត្តអាណិតប្អូនខ្ញុំណាស់។ គាត់ឃ្លានបាយណាស់ បើសិនជាបានបាយហូបជាមួយអំបិល មិនដឹងជាឆ្ងាញ់យ៉ាងណាទេ។ ឪពុកម្តាយខ្ញុំ រួមរូបខ្ញុំអង្គុយសម្រក់ទឹកភ្នែក ដោយគ្មាន លទ្ធភាពទៅរកបាយឲ្យកូន និងប្អូនហូប។ ភ្លឺឡើងប្អូនខ្ញុំស្លាប់អស់ពីរនាក់។ អត់ដឹងថាគាត់ ដាច់ខ្យល់ស្លាប់តាំងពីថ្មើរម៉ោន ហើយបន្តស្លាប់រហូតដល់អស់។ ប្អូនស្រីចុងក្រោយគេ ស្លាប់ពេលថ្ងៃម៉ោងបាយ ពេលដែលគេឲ្យបបរកន្ទក់មក ហូបអត់កើត។ ស្រែកសុំបាយ មួយម៉ាត់មក ឲ្យបាយខ្ញុំហូបមួយម៉ាត់មក ស្រែករហូតដល់ដាច់ខ្យល់ស្លាប់។ នេះជា សោកនាដកម្មមួយដ៏ព្រៃផ្សៃនៃរបប ប៉ុល ពត ដែលខ្ញុំមិនអាចបំភ្លេចបាន។ ហើយគេយក ក្រុមគ្រួសារខ្ញុំទៅអត់បាយ ឲ្យហូបដូចជាសត្វធាតុ។"*[112]

ពួកគាត់បានរៀបរាប់ពីការប៉ះទង្គិចដែលបណ្តាលមកពីការបាត់បង់បងប្អូនទាំងអស់ ខណៈដែលពួក គាត់នៅតូចៗនៅឡើយ។

៥២. អ្នកខ្លះបានរៀបរាប់ពីការស្លាប់ និងការណ៍ដែលពួកគាត់មិនអាចជួយសង្គ្រោះកូនរបស់ខ្លួនបាន ដូចជា ករណីរបស់លោកស្រី ប៉ូ ឌីណា ជាដើម៖

*"ឆ្លើយ៖ ក្រោយពីដឹងថាស្វាមីខ្ញុំស្លាប់ហើយ បានដឹងថាកូនខ្ញុំបានធ្លាក់ខ្លួនឈឺ។ ឈឺដោយសារអត់ ឃ្លាន អត់អាហារ។ ឈឺខ្លាំងណាស់មិនដឹងជាមានថ្នាំសង្កូវណាព្យាបាលទេ អត់មានទាល់តែសោះ មានតែថ្នាំអាចម៍ទន្សាយយកមកលេបអត់ជា កូនខ្ញុំបានកើតជំងឺហើម រាកខ្លាំង។ ហៀបដាច់ខ្យល់ ហ្នឹង ខ្ញុំអាណិតកូនខ្ញុំណាស់ អាសូរពាក្យសម្តីកូន កូនសម្លាញ់មាសម្តាយអើយ។ កូន -- ម៉ាក់ស្តាយ ណាស់កូនណាស់ អាសូរណាស់ពាក្យសម្តីរបស់កូន "អ្នកម៉ាក់កូនឃ្លានបាយណាស់ កូនសុំបាយ*

*មួយម៉ាត់មក កូនឃ្លានណាស់"។ កូនមាសម្ដាយ កូនឃ្លានបាយ ស្លាប់ទាំងវេទនា។ ទើបញ្ចប់កូន ខ្ញុំស្លាប់អត់បាយ ឃ្លានបាយ ស្រែកដង្ហោយរកបាយ។ ទឹកចិត្តម្ដាយសែនឈឺចាប់បែបណា ឮសម្ដីកូន។ កូនសម្លាញ់អើយ!!! ម្ដាយនឹកកូនណាស់ អាណិតអាសូរកូនណាស់ ដែលពេលស្រែកឃ្លាន ម្ដាយមិនដឹងរកអ្វីឱ្យកូនហូបបាន (...)"*[113]

ករណីដូចគ្នាសម្រាប់លោកស្រី ធុច ចាន់ដារា-ស៖

*"កូនខ្ញុំ សួរខ្ញុំថា ពេលនោះ វាមុននឹងស្លាប់ហ្នឹង ញញឹមដាក់ខ្ញុំហើយ ឱ្យវាឱ្យខ្ញុំញញឹមដាក់វាវិញ។ ហើយខ្ញុំគួរឱ្យចំពោះខ្ញុំ ក្ដុកក្ដួលណាស់ ព្រោះថាអស់លោកទាំងអស់គ្នាយល់ហើយ ថាពេលកូនជិតស្លាប់ហើយញញឹមដាក់ម្ដាយ ហើយសុំឱ្យម្ដាយញញឹមដាក់វិញនេះ។"*[114]

លោកស្រី បេ សុផានី រៀបរាប់ពីការស្លាប់បន្តបន្ទាប់គ្នារបស់កូនតូចៗទាំងបីនាក់របស់គាត់៖

*"(...) កូនខ្ញុំប្រកាច់ស្លាប់មួយរំពេច។"*[115]

*"នៅពេលនោះ យប់នោះគឺយប់ដែលយើងអត់អ្វីហូបសោះ យើងហូបស្លឹកឈើ។ ខ្ញុំដេកឱបកូនៗឈឺ និងកូនមួយទៀត ខ្ញុំមិនបានដឹងថាកូនប្រុសខ្ញុំស្លាប់នៅពេលថ្មើរម៉ានសោះ។ ព្រោះដេកយប់ទៅមិនដឹងថាកូនស្លាប់ថ្មើរម៉ានផង។ ព្រលឹមឡើងខ្ញុំមើលទៅ កូនធ្មេចភ្នែក ខ្ញុំយកដៃទៅបើកមាត់បើកភ្នែក តែកូនធ្មេចភ្នែកជិត ហើយសាច់ត្រជាក់ស្រងទាំងអស់ ខ្ញុំដឹងថា កូនខ្ញុំស្លាប់ហើយ។ (...) គេនិយាយរកខ្ញុំរហូតដល់គេបិទភ្នែកជិត។"*[116]

### ៨. អលទ្ធភាពក្នុងការសម្ដែងពីអារម្មណ៍របស់ខ្លួន

៥៣. ចាប់តាំងពីពេលជម្លៀសប្រជាជនដោយបង្ខំ ការសម្ដែងពីការឈឺចាប់ត្រូវបានហាមឃាត់ ហើយមនុស្សគ្រប់គ្នាត្រូវរៀនលាក់ពីអារម្មណ៍ជាមនុស្សរបស់ខ្លួន ដូចដែល លោកស្រី សាំង រ៉ាត់ បានពិពណ៌នា បន្ទាប់ពីលោកស្រីបានឃើញសមាជិកគ្រួសាររបស់ខ្លួនបានស្លាប់ ដោយក្នុងនោះមានប្ដី និងកូនរបស់លោកស្រី ខណៈដែលលោកស្រីទើបតែមានអាយុ ៣៤ ឆ្នាំ[117]៖

*"ឆ្លើយ៖ ចំពោះកូនខ្ញុំ គេទៅដល់ពេលនោះទៅក៏កូនខ្ញុំចូលចុងឆ្នាំ៧៦ ក៏កូនខ្ញុំបានឈឺស្លាប់ព្រោះដោយសារអត់មានអាហារហូប។ សួរ៖ ចុះក្រោយពេលកូនប្រុសច្បងរបស់អ៊ំស្លាប់ ថាតើមានហេតុការណ៍អីទៀតទេចំពោះក្រុមគ្រួសារអ៊ំបាទ? ឆ្លើយ៖ មានផែនការ ព្រោះប្ដីខ្ញុំក៏ទៅធ្វើការ*

*ហើយ ដល់ត្រឡប់មកដល់ផ្ទះវិញ ក៏ពេលព្រលប់នោះ គាត់បានសម្រាន្តទៅក៏បានដេកស្លាប់តែម្តង ព្រោះស្រេកឃ្លានអត់អាហារខ្លាំងពេក។ សួរ៖ ចុះក្រោយមកទៀតអ៊ំ ក្រោយពេលកូនច្បងអ៊ំស្លាប់ ហើយប្តីរបស់អ៊ំបានស្លាប់ទៀត ថាតើមានហេតុការណ៍អីកើតឡើងដល់កូនៗអ៊ំជាបន្តបន្ទាប់ទៀតទេបាទ? ឆ្លើយ៖ ហើយក៏កូនខ្ញុំបានស្លាប់ កូនទី១ ទី២ ទី៣ ហ្នឹងក៏បានស្លាប់បន្តបន្ទាប់គ្នាក្នុងរយៈពេលពីរយប់ហ្នឹងអស់តែម្តង។ កូនទាំងអស់បួននាក់។ សួរ៖ សុំអ៊ំបញ្ជាក់បានទេថាតើការស្លាប់កូនអ៊ំទាំងបួន និងប្តីរបស់អ៊ំនេះ គឺអ៊ំបានឃើញនៅហ្នឹងផ្ទាល់ភ្នែក ឬយ៉ាងណាដែរ? សូមអ៊ំបញ្ជាក់ឱ្យច្បាស់ពីបញ្ហានេះបាទ។ ខ្ញុំឃើញនៅផ្ទាល់នឹងភ្នែកស្លាប់ ប៉ុន្តែខ្ញុំយំស្រែកប៉ោយ៉ាងណា ក៏មានគេប្រាប់ថាមិនឱ្យយំទេ ព្រោះអីតែយំទៀតគេសម្លាប់ចោល គេថាខ្ញុំជាខ្មាំង គេអត់ឱ្យយំទេ។”*[118]

ករណីដូចគ្នាបានកើតឡើងផងដែរចំពោះ លោកស្រី ឆេង អេងលី ដែលពេលនោះលោកស្រីមានអាយុ ២២ ឆ្នាំ នៅពេលដែលលោកស្រីនិយាយពីការស្លាប់របស់មិត្តភ័ក្តិម្នាក់ដោយសារការកប់ទាំងរស់ ហើយដែលអ្នកស្រីបានឃើញផ្ទាល់ភ្នែក៖

*“ខ្ញុំយំក៏មិនប៉ានយំ ស្អីក៏មិនប៉ានទាំងអស់ ខំលេប ព្រោះនឹកឃើញថាយំ វាច្បាស់ជាសម្លាប់ទៀត ខ្ញុំមានតែម្តាយចាស់ ខ្ញុំត្រូវអត់ធ្មត់ វាហៅខ្ញុំមកធ្វើការស្ទូងស្រូវវិញ។”*[119]

## ៩. ការបាត់បង់លក្ខណៈជាមនុស្ស

៥៤. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានគូសបញ្ជាក់ពីភាពសាហាវឃោរឃៅ និងអមនុស្សធម៌ ដែលពួកគាត់បានទទួលរង រហូតធ្វើឱ្យពួកគាត់លែងមានអារម្មណ៍ជាមនុស្ស ប៉ុន្តែគឺជាសត្វធាតុទៅវិញ៖

> *“(...) ក្រៅពីហ្នឹង យើងរើសចាប់អីបាន យកហ្នឹងទៅ ដូចជា សូម្បីតែកន្ទាតមិនសល់ ចាប់ទាំងអស់ កណ្តូបអីៗ ចាប់។ អ៊ីចឹង យើងឈ្លោះគ្នាជាមួយឆ្កែប្រជាជនចាស់ទៀតផង ព្រះអាឆ្កែហ្នឹង មានម្ហូបអាហារគ្រាន់បើជាងយើង។*
>
> *“ក្រៅពីនេះ យើងដើរចាប់គីង្គក់ កណ្តូប ខ្យាដំរី អ្វីដែលយើងអាចចាប់បាន យើងញ៉ាំទាំងអស់។ សូម្បីតែជីងចក់ ក៏ខ្ញុំញ៉ាំដែរ នេះគឺដើម្បីជម្រាបអស់លោកថា យើងពិតជាឃ្លានខ្លាំងណាស់។ យើងបានក្លាយជាសត្វធាតុ។ យើងដណ្តើមចំណីអាហារជាមួយឆ្កែរបស់ពួកគេ ពីព្រោះឆ្កែទាំងអស់នោះត្រូវបានគេចិញ្ចឹមប្រសើរជាងយើង។ ឆ្កែរបស់ពួកគេមានចំណីស៊ីគ្រាន់បើជាងយើង។”*[120]

*"យើងមិនមែនជាមនុស្សទេ គេចាត់ទុកដូចជាសត្វធាតុ គឺគេលែងគិតយើងជាមនុស្សហើយ គេគិតថាយើងជាសត្វតែប៉ុណ្ណោះ។ ខ្ញុំអាចនិយាយ -- ខ្ញុំនៅតែនិយាយម្តងហើយម្តងទៀតថា នៅពេលនោះគឺថាគ្រោះអត់ឃ្លាននេះ គឺថាត្រូវបានរៀបចំត្រឹមត្រូវ គេគ្រោងផែនការដើម្បីធ្វើម៉េចឲ្យប្រជាជនអត់ឃ្លានស្លាប់ ឲ្យមានតែដែរទេ (...)"*[121]

លោកស្រី សេង ស៊ីវត្ថា ដែលពេលនោះលោកស្រីមានអាយុ ១០ ឆ្នាំ បានរៀបរាប់ពីលក្ខខណ្ឌការងារដែលលោកស្រីបានទទួលរង៖

*"ហើយបើយើងទៅកើបអាចម៍ជ្រូកក្រោល អាហ្នឹងបានគេតាមយើង។ ប្រធានគេតាមយើង។ ហើយគេនាំយើងទៅចុះរណ្តៅកើបអាចម៍ជ្រូកបញ្ចូលឃ្លាំង។ ពេលដែលខ្ញុំទៅចុះក្នុងរណ្តៅខ្ញុំមានអារម្មណ៍ថា លំបាកមែនទែន។ ត្បិតអីចុះរណ្តៅវាជ្រៅ ហើយខ្ញុំនៅតូចពេក ចុះទៅរណ្តៅនោះតែងតែលិចខ្ញុំត្រឹមចង្កេះ។ ធ្វើឲ្យខ្លួនប្រាណរបស់ខ្ញុំកើតរមាស់ យប់ឡើងរមាស់អត់បានដេក ថ្ងៃក៏ខ្ញុំដើរអេះ អង្គុយអេះ រមាស់ដំបៅពេញខ្លួនទាំងអស់។ ហើយពេល ដែលគេចែករបបអាហារ ដូចជាដំឡូងមួយដុំប៉ុនកដៃអ៊ីចឹង ក៏គេមិនអាចឲ្យខ្ញុំងើបឡើងនៅលើគោកហូបដែរ គេឲ្យខ្ញុំឈរហូបនៅក្នុងរណ្តៅអាចម៍ជ្រូកតែម្តង។ ពេលនោះខ្ញុំមានអារម្មណ៍ថាវេទនាជាទីបំផុត ត្បិតអីដៃខ្ញុំទាំងសងខាងត្រូវប្រឡាក់សុទ្ធតែអាចម៍ជ្រូក ហើយកាន់ដំឡូងហូប ហើយត្រូវខ្លួនប្រាណរមាស់។ ដល់ពេលគេទម្លាក់បង្គីឲ្យខ្ញុំកើបហ្នឹង គេសុទ្ធតែទម្លាក់ពីលើចុះមកខ្ទាតប្រលាក់ពេញមុខ ពេញក្បាល ធ្វើឲ្យខ្ញុំជួបទុក្ខលំបាកវេទនាមែនទែន ប៉ុន្តែខ្ញុំមិនអាចប្រកែកបាន ខ្ញុំនឹងតស៊ូធ្វើ តស៊ូកើបឲ្យគេដើម្បីបានរួចផុតពីការគេជេរស្តី និងការគេវ៉ៃ។"*[122]

៩៥. ការជម្លៀសប្រជាជនថ្មីលើកទីពីរ ក៏បានបង្កឲ្យមានព្យសនកម្ម[123]ជាច្រើនផងដែរ ដែលជាពិសេសបណ្តាលមកពីលក្ខខណ្ឌអមនុស្សធម៌ក្នុងការធ្វើដំណើរនៅតាមឡាន ឬ តាមរថភ្លើងដឹកទំនិញ ឬនៅក្នុងទូរថភ្លើងដែលមានសត្វល្អិត គ្មានទឹក គ្មានការព្យាបាល គ្មានអនាម័យ៖

*"ឆ្នាំ ១៩៧៦ ខ្ញុំរួមទាំងប្រជាជនជាច្រើនទៀត ត្រូវពួកខ្មែរក្រហមជម្លៀសឲ្យមកនៅ ខេត្តពោធិ៍សាត់ ដោយធ្វើដំណើរតាមរថភ្លើង ពួកវាដឹកជញ្ជូនប្រជាជនច្រើនណាស់ ឲ្យមកនៅខេត្តពោធិ៍សាត់ ចំណែកឪពុក (ឈ្មោះ វ៉ាយ ឃុត ម្តាយ ឌី យ៉ែម) ពួកវាបានជម្លៀសពួកគាត់ពីស្អាង ខេត្តកណ្តាល ទៅស្រុកបាទី ខេត្តតាកែវ ខ្ញុំមិនដឹងពីសុខទុក្ខពួកគាត់ទាំងពីរយ៉ាងណានោះទេ ចំណែកបង និងប្អូនៗរបស់ខ្ញុំ (ឈ្មោះ ឌី ខេន ឈ្មោះ ឌី យឿន ឈ្មោះ ឌី*

*រុំ) ក៏ទៅខេត្តតាកែវ ជាមួយឪពុកម្តាយខ្ញុំដែរ។ ខ្ញុំធ្វើដំណើរតាមរថភ្លើងមកខេត្តពោធិ៍សាត់ ជាមួយកូនរបស់ខ្ញុំទាំងពីរ នៅលើរថភ្លើងមានប្រជាជនជាច្រើន មិនដឹងថា ពួកគាត់ទាំងអស់មកពីណានោះទេ មានក្មេងខ្លះវង្វេងម្តាយ យំរហូត ខណៈមេកងឃើញ គ្រវែងចេញតាមបង្អួចរថភ្លើងបាត់ ខ្ញុំចាប់អោបកូននឹងដើមទ្រូង នៅពេលឃើញសភាពគួរឲ្យតក់ស្លុតបែបនេះ។ ពួកយើងមកកន្លែងរថភ្លើងឈប់នៅពេលយប់ មិនមានអ្វីហូបនោះទេ ពួកយើងដេកនៅទីនោះមួយយប់ គ្មានមុង ឬអ្វីនោះទេ សត្វមូស និងសត្វល្អិតមកខាំស្មើរស៊ុសសាច់ ។ នៅព្រឹកឡើង ទើបពួកវាឲ្យដើរទៅសហករណ៍ ដោយមានមេកងម្នាក់កាន់កាំភ្លើងអាកាដើរពីក្រោយផង ពួកវាដាក់ប្រជាជនគ្រប់សហករណ៍ក្នុងខេត្ត (...)"*[124]

*"ឆ្នាំ ១៩៧៦ មិនចាំខែ អង្គការចាប់ផ្តើមជម្លៀសចេញពីខេត្តតាកែវ ទៅកាន់ខេត្តបាត់ដំបង ដៃម្ខាងបីកូនខ្ចី ដៃម្ខាងដឹកដៃកូនតូច ស្នាស្លាយបង្វិចគួរជាទីសង្វេគពន់ពេក ដោយសារអត់អាហារគ្មានអីហូប មកដល់ផ្សារសំរោងយ៉ោង កូនខ្ញុំទីប្រាំម្នាក់ ឈ្មោះ ឈឿន ត្រូវដាច់ខ្យល់ស្លាប់តាមផ្លូវយ៉ាងវេទនា បន្ទាប់មកគេដេញឲ្យយើងទាំងអស់គ្នាឡើងឡាន នៅពេលឡានបើកចេញមិនទាន់ផុតសំរោងយ៉ោងផង កូនស្រីពៅដែលទើបតែកើតបានប៉ុន្មានខែនោះក៏ដាច់ខ្យល់ស្លាប់ទៀត ដោយសារតែគ្មានទឹកដោះបៅ (...)"*[125]

៥៦. ការជម្លៀសប្រជាជនដោយបង្ខំលើកទីពីរនេះ បាននាំជនរងគ្រោះទៅដល់កន្លែងដែលលក្ខខណ្ឌជីវភាពត្រូវបានគេពិពណ៌នាថា មានភាពអាក្រក់ជាងមុន និងបានបង្កឲ្យមានការឈឺចាប់ផ្លូវកាយដែលមិនអាចទ្រាំទ្របាន ហើយលើសពីនេះទៅទៀត មានមនុស្សជាច្រើនបានស្លាប់បាត់បង់ជីវិត។ លោកស្រី ប៉ូ ឌីណា បានរៀបរាប់នៅក្នុងសក្ខីកម្មរបស់ខ្លួនដូច្នេះថា៖

*"(...) គ្មានដំបូល គ្មានផ្ទះ គ្មានសម្លៀងជ្រកកោនទេ ខ្ញុំសម្រាកនៅទីដីផ្ទាល់តែម្តងចាស ពេលនោះមិនទាន់មានការរៀបចំឲ្យមានជម្រកជ្រកកោនទេ។ មានការលំបាកកាន់តែខ្លាំងឡើងៗ ណាស្បៀងអាហារមិនបានឆ្អែតគ្រប់គ្រាន់ ណាគ្មានទីជម្រក គ្មានទីកន្លែងឲ្យពិតប្រាកដ ថានៅទីកន្លែងណាឲ្យបានសុខស្រួលគឺគ្មាន។ ជ្រកនៅក្រោមម្លប់ដើមឈើ ចាសកាលនោះ ។"*[126]

លោក អ៊ូន ផល្លី៖

*"ឆ្លើយ៖ បាទ ខ្ញុំបានជួបប្រទះហ្នឹងវាហួស វាឈឺចាប់ពេលដែលឃើញអ្នកធ្វើដំណើរតាមផ្លូវស្លាប់ជាហូរហែ ទទួលកំណាត់ស មិនដឹងថាក្មេងចាស់ ប្រុសឬស្រី ឃើញតែទទួលកំណាត់សតាមផ្លូវហូរហែរហូត។"*[127]

## ១០. ភាពអស់សង្ឃឹម

៩៧. ប្រឈមនឹងអំពើឧក្រិដ្ឋទាំងអស់នេះ ដែលរួមមាន ការសម្លាប់រង្គាល ការសម្លាប់ និងការរំលោភបំពានលើសេចក្តីថ្លៃថ្នូរជាមនុស្ស ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីការវិលវល់របស់ពួកគាត់៖

*"ឆ្លើយ៖ ខ្ញុំជម្រាបលោកថា បើសិនជាការជម្លៀសហ្នឹងទៅ មានម្ហូបអាហារហូបចុកគ្រប់គ្រាន់ ឪពុកម្តាយ បងប្អូនខ្ញុំមិនស្លាប់ទេលោក មិនស្លាប់ទេ។ គ្មានម្ហូបអាហារ ហើយគ្មានអង្ករ ហើយគ្មានថ្នាំសង្កូវ គ្មានអ្វីៗទាំងអស់លោក។"*[128]

ដើមបណ្តឹងរដ្ឋប្បវេណីក៏បានរៀបរាប់ពីទុក្ខព្រួយរបស់ខ្លួន និងពេលខ្លះទៀត ពួកគាត់ចង់ស្លាប់[129]៖

*"ខ្ញុំមានអារម្មណ៍ថា ខ្ញុំលែងចង់រស់ ខ្ញុំសម្រេចចិត្តទិញថ្នាំកណ្តុរ ទិញថ្នាំដង្កូវយកមកសម្លាប់ខ្លួន។ ប៉ុន្តែ ខ្ញុំបានបងស្រី និងម្តាយ គាត់បានណែនាំថាមិនឲ្យធ្វើបែបនេះ រស់ដើម្បីមើលថែកូន"*[130]

*"តើខ្ញុំសង្ឃឹមអ្វីទៀត សព្វថ្ងៃនេះ ខ្ញុំអស់ហើយសេចក្តីសង្ឃឹមជីវិតខ្ញុំក្នុងជាតិនេះ របស់ជាទីស្រឡាញ់របស់ខ្ញុំបាត់ពីខ្លួនខ្ញុំអស់។"*[131]

## ១១. ការបង្ខំមិនឲ្យគោរពជំនឿ និងប្រតិបត្តិសាសនា

៩៨. ចាប់តាំងពីថ្ងៃដំបូងៗ និងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ឃើញថា វត្តអារាមត្រូវបានកម្ទេច ឬត្រូវបានប្រើប្រាស់ក្នុងកម្មវត្ថុផ្សេងៗ។ ព្រះសង្ឃត្រូវបានបង្ខំឲ្យលាចាកសិក្ខាបទ[132] ការប្រារព្ធពិធី ឬការប្រតិបត្តិសាសនា ទោះជាតាមទម្រង់ណាក៏ដោយ ត្រូវបានហាមឃាត់[133]ចាប់តាំងពីពេលជម្លៀសទីក្រុងនាដំណាក់កាលដំបូងៗមកម្លេះ[134]។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានកត់សម្គាល់ពីការកាប់សម្លាប់ព្រះសង្ឃ និងពុទ្ធសាសនិក អ៊ីស្លាមសាសនិក[135] និងអ្នកកាន់សាសនាផ្សេងៗទៀត។ នៅក្នុងសង្គមមួយដែលការប្រតិបត្តិ និងការយកសាសនាជាមូលដ្ឋានដ៏សំខាន់នោះ ព្យសនកម្មដែលទទួលរង ពិតជាមានទំហំធំធេងណាស់ជាពិសេស ការដែលគ្មានលទ្ធភាពក្នុងការផ្តល់ឲ្យអ្នកស្លាប់នូវទីបញ្ចុះសពមួយប្រកបដោយភាពថ្លៃថ្នូរ[136]។ ជាមួយគ្នានេះដែរ ការសូត្រធម៌បួងសួង ការគោរពប្រតិបត្តិ និងការរៀបចំជាពិធី

ផ្សេងៗឱ្យបានត្រឹមត្រូវ ជាពិសេសពិធីរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបានហាមឃាត់។ ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន មានអារម្មណ៍ថាបានបាត់បង់ព្រលឹងរបស់ខ្លួន។

*"នៅពេលយើងមកដល់វត្តព្រែកហូរ ខ្ញុំបានឃើញសាកសពជាច្រើន ដែលក្នុងចំណោមនោះមានព្រះសង្ឃផងដែរ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចខ្លាំងណាស់។ យើងបានចំណាយពេលប្រហែលដប់យប់នៅវត្តព្រែកហូរនេះ។ យើងស្នាក់នៅក្នុងវត្តជាមួយសាកសព។ (...) គ្រប់វត្តអារាមទាំងអស់ដែលខ្ញុំបានទៅក្នុងអំឡុងពេលធ្វើដំណើរ មិនមានព្រះសង្ឃទេ។ មានតែវត្តព្រែកហូរទេ ដែលខ្ញុំបានឃើញសាកសពព្រះសង្ឃ។"*[137]

*"នៅពេលនោះ ខ្ញុំនៅជាសង្ឃនៅឡើយ។ ក្រោយមក ខ្ញុំត្រូវបានគេជម្លៀសទៅភូមិទួលត្រាច ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅពេលនោះ គេបង្ខំឱ្យខ្ញុំសឹកនៅវត្តភូមិវិហារ។ បន្ទាប់មក ខ្ញុំត្រូវបានជម្លៀសទៅភូមិមហា ជាមួយឪពុកម្ដាយរបស់ខ្ញុំ។ នៅទីនោះ ខ្ញុំត្រូវបានគេបង្ខំឱ្យវែកដី ប្រព័ន្ធភ្លឺស្រែ។"*[138]

## ១២. ព្យសនកម្មសម្រាប់ពេលយូរ

៥៩. ក្រៅពីព្យសនកម្មផ្ទាល់ដែលទទួលរងដោយជនរងគ្រោះ បណ្ដាលមកពីអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តនោះ គឺនៅមានព្យសនកម្មរយៈពេលយូរបន្ថែមទៀត[139]៖

*"ឆ្លើយ៖ បាទ លោកស្រី អំពើទាំងអស់ហ្នឹង វាជះឥទ្ធិពលមកលើខ្ញុំ។ សព្វថ្ងៃហ្នឹងវាធ្វើឱ្យខ្ញុំតែនឹកឃើញរឿងហ្នឹង នៅតែភ័យរន្ធត់ខ្លាច បាទ។ វាធ្វើឱ្យខ្ញុំហ្នឹង គិតអ្វីពុំយល់ទេ (...) ឆ្លើយ៖ បញ្ហាអំពីផ្លូវចិត្តរបស់ខ្ញុំ សូមជ្រាបជូនលោកស្រីថា ខ្ញុំនៅតែពិបាកក្នុងចិត្ត ព្រួយបារម្ភ ការបន្សល់ពីអំពើដែលខ្ញុំរស់ដោយវេទនាហ្នឹង ខ្ញុំនៅសព្វថ្ងៃនេះ ខ្ញុំនៅនឹកឃើញរឿងហ្នឹង ចេះតែភ័យញ័រ ឈឺក្បាល វិលមុខ ញ័រដៃញ័រជើង ចុកទ្រូង បាទ ហើយតាមខឹង ខឹងរករឿង ចង់ររករឿង ប៉ុន្តែមិនដឹងរករឿងអីទេបើប្រទេសយើងមានច្បាប់ យើងចេះតែនៅស្ងៀមទៅ។"*[140]

៦០. អនុស្សាវរីយ៍ និង**របួសផ្លូវចិត្ត** នៅតែបន្តមាន ទោះជារយៈពេលជាង ៣០ ឆ្នាំ បានកន្លងផុតទៅក៏ដោយ៖

*"ឆ្លើយ៖ ពីព្រោះអ្វី? ពីព្រោះថាគាត់មានជំងឺផ្លូវចិត្តនោះរុំារ៉ៃជាយូរឆ្នាំមកហើយ។ ដូច លោកប្រធាន បងប្អូនរួមខ្មែរយើងទាំងអស់ អស់លោកទាំងអស់ជ្រាបហើយ របបខ្មែរក្រហម ប៉ុល ពត បានកន្លងផុតទៅ ៣៨ ឆ្នាំ កន្លងមកហើយ ក៏ប៉ុន្តែជំងឺផ្លូវចិត្ត ជំងឺរ៉ាំរ៉ៃ នៅតែមានរហូតចំពោះបងប្អូនជនភៀសខ្លួនខ្មែរ ដែលធ្លាប់រស់នៅក្នុងរបប ប៉ុលពត ទាំងរូបគេ ទាំងរូបខ្ញុំ។"*[141]

៦១. លោក អួន ផល្លី ដែលពេលនោះ លោកទើបមានអាយុ ១០ ឆ្នាំ ហើយដែលលោកបានបាត់បង់សាច់ញាតិដោយសារការជម្លៀសដោយបង្ខំ បានរៀបរាប់ពីទិដ្ឋភាពនានានៃព្យសនកម្មផ្លូវចិត្ត ដែលលោកបាន ហើយនិងនៅតែបន្តទទួលរង ជាពិសេសអារម្មណ៍ និង**ស្ថានភាពឯការកទីបំផុតគ្មាន**របស់លោក៖

*"ឆ្លើយ៖ អារម្មណ៍របស់ខ្ញុំគឺឈឺចាប់ណាស់ រហូតធ្វើឲ្យខ្ញុំមិនចង់រស់ ដូចថាមានអារម្មណ៍ថាខុសគេ។ ឈឺចាប់រហូតដល់ចង់ឲ្យពិភពលោកហ្នឹងរលាយទៀតនោះ។"*[142]

*"(...) ហើយកាលនោះ ខ្ញុំរស់នៅតែក្នុងបន្ទាយទេ យកបន្ទាយធ្វើដូចជាភូមិកំណើត រហូតដល់មានមិត្តភក្តិរួមអារុធក្នុងអង្គភាពជាមួយគ្នា គេបានយកមកនិយាយលេង ក៏ដូចជាចំអកមើលងាយដល់រូបខ្ញុំថា ខ្ញុំមិនដឹងឪពុក ម្តាយឈ្មោះអី ស្រុកកំណើតនៅឯណា ដោយសារតែខ្ញុំមិនដែលទៅផ្ទះនឹងគេម្តងសោះក្នុងមួយឆ្នាំៗ។ (...) ខ្ញុំលាក់លៀមបៀមទុក្ខរហូត ខ្ញុំមិនប្រកាន់នឹងគេទេ។ (...) ស្រមោលអតីតកាលនៅតែតាមលងខ្ញុំ ទើបខ្ញុំលាក់លៀម។ នេះជាលើកទីមួយហើយដែលជាទំព័រជីវិតជាប្រវត្តិសាស្ត្រដែលខ្ញុំត្រូវបានលាតត្រដាងទៅកាន់ពិភពលោក។"*[143]

*"ព្រោះតែខ្ញុំអស់រលីង បានខ្ញុំចង់ឲ្យពិភពលោកពិភពលោកនេះខ្ទេចរលាយ កុំឲ្យការឈឺចាប់នេះរីកធំធាត់ដុះដាលរហូតដល់សង្គ្រាមលោក (...) ទោះជាយើងមានការហូបចុក ស៊ីចាយយ៉ាងណាក្តី ក៏យើងនៅតែមានអារម្មណ៍ឈឺចាប់ក្នុងចិត្តរហូត ព្រោះដោយសារតែយើងគ្មានអ្វីពឹងផ្អែក(...) រីឯមើលមកខ្លួនឯង ប្រឹងត្រដររស់ទៅតាមយថាកម្មរបស់ខ្លួន។ គ្មានអ្នកណាដឹង ដោយសារតែខ្ញុំចង់លាក់លៀមនូវប្រវត្តិជីវិតរបស់ខ្ញុំអស់រយៈពេលជាង ៣០ ឆ្នាំ។"*[144]

៦២. អ្នកខ្លះ បានសម្តែងពី**ការលំបាកដែលពួកគាត់ជួបប្រទះក្នុងការនិយាយ**អំពីអ្វីដែលខ្លួនបានទទួលរង ដោយបានសង្កត់ធ្ងន់ថា ពួកគាត់មិនអាចរៀបរាប់ពីព្រឹត្តិការណ៍ទាំងនោះតាមរយៈការនិយាយផ្ទាល់មាត់បានទេ។

*"(...) ខ្ញុំឆ្ងល់ណាស់ថា ហេតុអ្វីបានជារបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ នេះមានភាពសាហាវឃោរឃៅម្ល៉េះ? ហើយគេធ្វើដើម្បីអ្វី? (...) ពេលនេះ ខ្ញុំគឺជាសាក្សីម្នាក់ដែលមានរស់រានមានជីវិតពីរបបយង់ឃ្នងនេះ ហើយបានឃើញ និងឆ្លងកាត់នូវសោកនាដកម្មជាហូរហែដូចប្រជាពលរដ្ឋដទៃទៀត។"*[145]

*"(... ) ខ្ញុំសូមទោសអង្គសវនាការទាំងមូល។ ខ្ញុំសូមបញ្ចេញនូវទស្សនៈ នូវភាពចុកចាប់របស់ខ្ញុំ (...)"*[146]

អំពីភាពភ័យខ្លាចដែលពួកគាត់បានឆ្លងកាត់៖

*"(...) ហើយទឹកស្មានថា មិនអាចច្បាស់ជាមានស្ត្រីមួយដែលមិនអាចវិលត្រឡប់ទៅរកភាពដើម។"*[147]

*"ដូច្នេះស្ត្រីដែលបៀមទុកនៅក្នុងខ្លួន ហើយនិយាយមិនចេញ គ្មានសិទ្ធិនឹងនិយាយ និងគ្មានសិទ្ធិនឹងរ៉ាយរ៉ាប់ តើលោកគិតមើល តើវាពិបាកយ៉ាងណា? មនុស្សម្នាក់ៗដែលមានទុក្ខបើបាននិយាយបន្តិចទៅ ក៏វាស្រួលក្នុងចិត្ត ហើយបើបាននិយាយពីការពិត រឹតតែល្អទៅទៀត។ តែនេះគ្មាននិយាយបានទៀត បើសិនជាខ្ញុំប៉ិាននិយាយ ខ្ញុំនឹងស្លាប់ខ្លួន (...)"*[148]

អំពី**ការមិនយល់**របស់ពួកគាត់[149]៖

*"(...) ហើយពេលដេកអ៊ីចឹងដែរ ពេលដេកអត់មានកន្លែងដេកស្រួលបួលទេចាស នាងខ្ញុំសម្រាកអ៊ីចឹងទៅ ចេះតែសម្រាកឲ្យបានទៅ ហើយដល់ពេលទឹកវាចេះតែឡើងមក ជន្លេនពួន ពំនូកប៉ុនៗនេះ ពួនលើជើង។ មែនទែនទៅលែងខ្លាចហើយជន្លេន ក៏អត់ខ្លាច ឈ្លើងក៏អត់ខ្លាច ស្ត្រីក៏អត់ខ្លាចដែរ ក្រៅតែជីវិតរស់មួយចាស។ អ៊ីចឹងបានថា ជីវិតនេះគឺថាវាអាក្រក់បំផុត មិនដឹងថាអ្នកដឹកនាំហ្នឹងគេជាមនុស្សសតិសម្បជញ្ញៈ គេហ្នឹងជាមនុស្សដែរឬអត់? ដែលគេយកមនុស្សដូចគ្នាទៅធ្វើបាបរបៀបនេះចាស។"*[150]

អំពី**ភាពអៀនខ្មាស**ដែលរារាំងពួកគាត់មិនឲ្យនិយាយពីរឿងនេះជាមួយក្រុមគ្រួសារ៖

*"ឆ្លើយ៖ ខ្ញុំនិយាយម្តងម្កាលទេ និយាយតិចណាស់ ខ្ញុំនិយាយតែទៅកាន់កូនពៅរបស់ខ្ញុំនោះ តិចណាស់ ហើយកូនប្រុសខ្ញុំអាធំជាងគេហ្នឹង ខ្ញុំមិនដែលនិយាយពីសម័យ ប៉ុល ពត នោះទេ។ កូនពៅ និយាយបន្តិចបន្តួច (...)"*[151]

អ្នកខ្លះបានលើកឡើងពីភាពអត់ឃ្លានយ៉ាងវេទនា និងដែលជាមូលហេតុនៃការស្លាប់របស់មនុស្សជាច្រើននាក់នាសម័យនោះ បានបង្កើតឲ្យមាននូវ**គំនិតអាស្រ័យលើចំណីអាហារ** ដូចជារោគស្រេកឃ្លានជាដើម៖

*"ឆ្លើយ៖ ផលប៉ះពាល់នៃការបង្អត់អាហារដែលមានមកលើខ្ញុំនោះ ខ្ញុំគិតថា នៅពេលដែលចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ៧៩ នោះ ខ្ញុំគិតតែពីញុំាអាហារដើម្បីឲ្យមានកម្លាំងឡើងវិញ ហើយពេលនោះ ខ្ញុំ សុខភាពមាំមួនជាងមុន ក៏ប៉ុន្តែ ខ្ញុំកាលណោះ គឺថាគិតតែពីញុំាទេ មិនគិតផាសុខភាព ពីអ្វី ពីផ្ទះសម្បែងអីទេ។ កាលនោះ អ្វីដែលខ្ញុំត្រូវការគឺចំណីអាហារតែប៉ុណ្ណោះឯង។"*[152]

៦៣. ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានលើកឡើងពីការយល់សប្តិអាក្រក់ រូបភាព ទុក្ខព្រួយ និងការភ័យខ្លាច ដែលនៅតែបន្តតាមលងពួកគាត់[153]។

*"ហើយរន្ធត់ចិត្តមួយទៀត ជម្លៀសចេញពីភ្នំពេញហ្នឹង គឺឃើញមនុស្សស្លាប់ស្តូក ដើរប្អូនដប់ជំហានទៅ ឃើញស្លាប់មួយទៀត។ ក្បាលហ្នឹងរីក ដែលវាបាញ់ វានឹកឃើញរឿងហ្នឹងចេះតែនឹកឃើញៗទៅ ម្តោះហើយគេងមិនលក់សោះ។"*[154]

ជាមួយគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយពីការលំបាករបស់ខ្លួនក្នុងការមិនបានរកទីបញ្ចុះសពមួយដ៏សមរម្យ សម្រាប់បងប្អូនសាច់ញាតិរបស់ពួកគាត់៖

*"លោកឪពុកត្រូវបានគេបំបែកឲ្យចេញពីរូបខ្ញុំផ្ទាល់ ក៏ដូចជាម្តាយ និងបងប្អូនប្រុសរបស់ខ្ញុំដែរ ហើយយើងទទួលរងការឈឺចាប់យ៉ាងខ្លាំងចាប់តាំងពីឆ្នាំ១៩៧៥ មក។ ខ្ញុំដឹងថាមនុស្សជាច្រើនបានបាត់បង់ឪពុករបស់ខ្លួនដោយសារជំងឺ ឬដោយមូលហេតុគ្រោះថ្នាក់ ប៉ុន្តែឪពុករបស់ខ្ញុំត្រូវបានគេធ្វើទារុណកម្ម បន្ទាប់មក ត្រូវគេសម្លាប់ ហើយសាកសពរបស់គាត់ត្រូវបានបាត់ក្នុងរណ្តៅសាកសពរួម ដោយមិនមានពិធីបញ្ចុះសពឡើយ។ ខ្ញុំមិនអាចបំភ្លេច ហើយក៏មិនអាចអត់ ឱនទោសចំពោះរឿងនេះដែរ។"*[155]

*"សែន៖ មានដែលជួបដែរ ដូចខ្ញុំរាល់ថ្ងៃ អ្នាស ដូចថាកាលពីមុនៗមក កាលពីជំនាន់គេសម្លាប់ហ្នឹងណា អារម្មណ៍នឹកឃើញក្នុងចិត្តថា មិនដឹងស្លាប់ថ្ងៃណា ជួនកាលដេកយល់សប្តិពេលយប់អ៊ីចឹងទៅ យល់សប្តិថាគេយកទៅវ៉ៃចោល ពេលយប់អ៊ីចឹង ភ័យស្ទុះឡើងក្រោក រហូតមកដល់រាល់ថ្ងៃហ្នឹង នឹកឃើញដល់ជំនាន់នៅឆ្នាំនៅជាប់គុកក្រាំងតាចាន់ ស្ទុះឡើងក្រោកអ៊ីចឹងទៅ ឡើងមកអង្គុយឱ្យបាត់ភ័យព្រួយ បានឡើងទៅដេកទៀត រាល់ថ្ងៃហ្នឹង។ សុភារិទ្ធិ៖ ថ្មីៗហ្នឹង នៅមានយល់សប្តិ...? សែន៖ ថ្មីៗហ្នឹងក៏មានយល់សប្តិឃើញនឹកឃើញអាដិតដាមជំនាន់បីឆ្នាំដែលយើងនៅកន្លែងហ្នឹងណា នឹកឃើញក្នុងចិត្តអ៊ីចឹងណាបាទ។"*[156]

*"ខ្ញុំត្រូវធំដឹងក្តីតែម្នាក់ឯង ដោយដឹងថាឪពុកម្តាយរបស់ខ្ញុំ និងគ្រួសារទាំងមូលរបស់ខ្ញុំ ត្រូវបានសម្លាប់។ ខ្ញុំជជែកអំពីរឿងរ៉ាវរបស់ខ្ញុំ ពីព្រោះវាធ្វើឱ្យខ្ញុំធូរស្បើយ។ នាពេលបច្ចុប្បន្នខ្ញុំនៅតែមានសុបិនអាក្រក់ឃើញខ្មែរក្រហមយកគ្រួសាររបស់ខ្ញុំចេញទៅ និងអារម្មណ៍នៅពេលដែលខ្មែរក្រហមបំផ្លាញផ្ទះរបស់ខ្ញុំ និងយកគ្រួសាររបស់ខ្ញុំនៅយប់នោះ។ មានពេលខ្លះ ខ្ញុំពុំសូវមានជំនឿលើខ្លួនឯងឡើយ ពីព្រោះវាលំបាកណាស់ក្នុងការធំដឹងក្តីដោយខ្លួនឯង។ ជួនកាល ខ្ញុំប្រាប់ប្រពន្ធរបស់ខ្ញុំថាខ្ញុំត្រូវការពេលវេលាខ្លះដើម្បីនៅម្នាក់ឯងដើម្បីគិតអំពីអតីតកាលរបស់ខ្ញុំ។"*[157]

៦៤. ពួកគាត់បានសម្តែងផងដែរពីអារម្មណ៍ ដែលមិនបានសងគុណចំពោះឪពុកម្តាយ ដែលបានខំចិញ្ចឹមពួកគាត់កាលពីនៅកុមារភាព៖

*"ឆ្លើយ៖ ដូចលោកដឹងស្រាប់ហើយថា ឪពុកម្តាយដូចជាព្រះជាម្ចាស់អ៊ីចឹង។ យើងមិនអាចប៉ះពាល់គាត់បានទេ គាត់ជាទីសក្ការៈ ហើយនៅពេលដែលយើងឃើញឪពុកម្តាយ គឺថាស្លាប់នៅអាយុ ៤៣ ឆ្នាំ ៤៤ ឆ្នាំ នោះ គឺថាស្លាប់មុនអាយុ។ ខ្ញុំដែលថាខ្ញុំមិនអាចបំភ្លេចបានទេ អ្វីដែលខ្ញុំឃើញនេះៗ។"*[158]

ពួកគាត់បាននិយាយផងដែរថា ការដែលមិនបានដឹងពីលក្ខខណ្ឌ និងកាលៈទេសៈនៃការស្លាប់របស់ញាតិមិត្ត នៅតែបន្តតាមលងពួកគាត់ជានិច្ច៖

*"(...) ក្នុងឋានៈជាមនុស្សដែលតែងតែមានសតិសម្បជញ្ញៈ តើឪពុកណាមួយ តើម្តាយណាមួយ ជីដូនណាមួយ ជីតាណាមួយ ដែលមិនស្រឡាញ់ចៅ មិនស្រឡាញ់របស់ខ្លួន ជាពិសេសនៅពេលកូនចៅឈឺម្តងៗ គ្រាន់តែឈឺក្នុងលក្ខណៈឈឺដែលមានពេទ្យហ្នឹមើលក៏*

*ភ័យព្រួយ ចុះទម្រាំបើបាត់បង់កូនដោយមិនដឹងមូលហេតុអី គេប្រមូលយកទៅសម្លាប់ យកទៅកម្ទេចទាំងកណ្ដាលរាត្រីយ៉ាងនេះ។ តើៗកម្សួលនៃការសោកស្ដាយហ្នឹងយ៉ាងប៉ុនណា? នៅតែនឹកឃើញកូនថា តើវិធីដែលគេសម្លាប់កូនហ្នឹង ហើយនិងក្មួយតូចៗហ្នឹង តើដោយវិធីណានៅពេលនោះ ? តើយ៉ាងម៉េចទៅ ? អារម្មណ៍ហ្នឹងវានៅវិលវល់នៅតែក្នុងខ្លួន នៅតែវិលវល់ នៅតែស្ដាយស្រណោះ ទោះបីខ្ញុំកូនច្រើនក៏ដោយ ខ្ញុំបាទកូនច្រើនក៏ដោយ នៅតែនឹកស្ដាយស្រណោះកូនដែលបាត់ទៅនៅតែស្ដាយស្រណោះៗ ហើយធ្វើឱ្យអារម្មណ៍យើងអត់ល្អសោះ វិលវល់ (...)។*”[159]

ពួកគាត់បានបង្ហាញពីតម្រូវការក្នុងការទទួលបាននូវសេចក្ដីសម្រេចមួយរបស់តុលាការ៖

*“បាទ ការសំណាងហ្នឹងសុំឱ្យ ដូចអស់លោកដឹងស្រាប់ហើយដូចថា សំណាងនោះគឺដូចរូបខ្ញុំរំសាយការឈឺចាប់ សំណាងនោះគឺសុំឱ្យថា ឱ្យមកជាសាលារៀន ផ្លូវថ្នល់ ហើយសុំធ្វើជានេះមួយផង ធ្វើជាតាមមន្ទីរវត្ត -- កន្លែងតាមវត្តអារ៉ាមធ្វើជាចេតិយមួយសម្រាប់តាំង ធ្វើជាគោរពវិញ្ញាណក្ខន្ធរបស់ខ្មែរកម្ពុជាក្រោមដែលបានចែកឋានទៅនោះ ដែលអត់ដឹងរឿងអីសោះ។ សូម្បីតែកូននៅកន្ទេល ពរនឹងដៃ ហ្នឹង ក៏យកទៅបោកគល់ឈើដែរហ្នឹង ហើយគ្នាដឹងអី។ ហើយសាច់ឈាមជំរថាកម្ពុជាក្រោមហ្នឹង ហើយយកទៅបោកគល់ឈើ លេងទៅសម្លាប់ឪពុកម្ដាយ។ ទុកអាហ្នឹង អាហ្នឹងហើយសងសឹក។ បើខ្ញុំបាទយល់ឃើញ។*”[160]

## ១៣. ព្យសនកម្មពិពណ៌នាដោយប្រជាជនកម្ពុជាដែលទៅនៅបរទេស

៦៥. ប្រជាជនកម្ពុជា ដែលបានជ្រើសរើសដោយការបង្ខំចិត្តតិច ឬច្រើន ក្នុងការវិលត្រលប់មករស់នៅប្រទេសកម្ពុជាវិញ បានគូសបញ្ជាក់ពីផលលំបាកក្នុងការសម្របខ្លួន ការលំបាកផ្នែកសម្ភារៈ និងការលំបាកបណ្ដាលមកពីភាពខុសគ្នានៃវប្បធម៌។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប បានរៀបរាប់ពីស្ថានភាពទាំងអស់នោះថា៖

*“តើអ្នកស្រីអាចពន្យល់ប្រាប់តុលាការបានទេ នៅពេលដែលអ្នកស្រីទៅដល់ប្រទេសបារាំង នៅខែតុលា ឆ្នាំ៧៩ នោះដែលទៅដល់នោះជាមួយនឹងកូនរបស់អ្នកស្រី កូនប្រុសម្នាក់ ហើយកូនស្រីម្នាក់ ហើយនិងបងស្រីរបស់អ្នកស្រី? ឆ្លើយ៖ ខ្ញុំមានជីវិតបី ខ្ញុំ -- អ៊ីចឹងខ្ញុំមានមុនហ្នឹង គឺថាជីវិតខ្ញុំល្អ ឱកាសល្អណាស់ ហើយបន្ទាប់មកទៀត -- ហើយកាលដែលខ្ញុំនៅក្មេងនោះ គឺថាខ្ញុំ -- កាលខ្ញុំនៅបារាំងនោះគឺថា ជាការតស៊ូដើម្បីឱ្យរស់ឡើងវិញ គឺថាកាលនោះមានអារម្មណ៍ថាខ្លួនឯងឯកា ត្រូវតែតស៊ូ កាលណោះហើយត្រូវតែខំរៀន យក*

*បណ្ឌិតបរ ខំរៀនពេលល្ងាចដើម្បីទទួលបានសញ្ញាបត្រ ហើយមានរកការងារបានធ្វើ។ ហើយអ៊ីចឹងគឺថា ធ្វើឲ្យយើងអស់កម្លាំងចិត្តណាស់ គឺថាវាអស់ឫសគល់ជាដើមកំណើតជាខ្មែរ។ ខ្ញុំចេះបារាំងដែរ ខ្ញុំដឹងវប្បធម៌បារាំងដែរ ក៏ប៉ុន្តែខ្ញុំអង្គាល់ណោះ ចូលទៅប្រទេសបារាំងស្ថិតនៅក្នុងមជ្ឈដ្ឋានមួយ គឺថា វាការផ្លាស់ទីអីខុសគ្នា អាកាសធាតុអីក៏ខុសគ្នា ហើយខ្ញុំត្រូវចិញ្ចឹមកូន ហើយនិងបងខ្ញុំ។ អ៊ីចឹងហើយ ពេលខ្លះហ្នឹង ខ្ញុំនោះធ្លាក់ក្នុងជំងឺខូចចិត្ត ហើយចូលដេកពេទ្យផង។"*[161]

ពួកគាត់បានលើកឡើងផងដែរពីបញ្ហាដែលប៉ះពាល់ដល់កូនៗរបស់ពួកគាត់ បើទោះបីជាពួកគេមិនបានឆ្លងកាត់របបខ្មែរក្រហម និងកើតនៅបរទេសក៏ដោយ។

**ខ. ផលវិបាកនៃឧក្រិដ្ឋកម្មរៀបរាប់ដោយអ្នកជំនាញ**

៦៦. ការកត់សម្គាល់ និងការវិភាគ ធ្វើឡើងដោយអ្នកជំនាញ វេជ្ជបណ្ឌិត និងអ្នកស្រាវជ្រាវនានា បានលើកឡើងវិញនូវព្យសនកម្មរៀបរាប់ដោយជនរងគ្រោះ ដោយបានផ្តល់នូវការពន្យល់តាមបែបវិទ្យាសាស្ត្រ។

៦៧. លោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ដែលបានធ្វើការជាប់ជាប្រចាំជាមួយជនរងគ្រោះសម័យខ្មែរក្រហម ចាប់តាំងពីឆ្នាំ ២០០៥ មក ត្រូវបានស្តាប់ចម្លើយក្នុងនាមជាសាក្សី កាលពីថ្ងៃទី ៥ និងថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣។ ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម លោកវេជ្ជបណ្ឌិត បានគូសបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃផលវិបាកនៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តមកលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ។ លោកវេជ្ជបណ្ឌិត បាននិយាយអំពីជនរងគ្រោះដែលលោកបានពិនិត្យថា៖
"*អ្នកខ្លះអាចមានជាជំងឺដែលភាសាអង់គ្លេសថា ប៉ូស្ត្រ៍ម៉ាទិកស្ត្រេស ឌីហ្សតឌ័រ ឬក៏ ភី.ធី.អេស.ឌី ហ្នឹងអាចមានជាជំងឺបាក់ស្បាត អាចមានជំងឺធ្លាក់ទឹកចិត្ត អាចមានជំងឺថប់អារម្មណ៍ ហើយអ្នកខ្លះទៀតអាចមានជំងឺសង្ស័យ ជំងឺផារ៉ាណយ (Paranoïa)"*[162]។ លោកបានបន្ថែមទៀតថា៖ *ហើយចំណុចសំខាន់ទីពីរ គឺការជៀសវាង។ គាត់គេចជៀសវាង គឺគាត់ចង់និយាយអំពីរឿងរ៉ាវដែលកើតឡើងទេ គាត់មិនចង់ទៅជួបកន្លែងដែលគាត់ធ្លាប់រងនូវការធ្វើបាប ធ្វើទារុណកម្មនោះទេ ឬក៏គាត់មិនចង់ពិភាក្សាអំពីស្ថានភាព ដែលទាក់ទងធ្វើឲ្យគាត់នឹកឃើញឡើងវិញនូវរឿងរ៉ាវដែលគាត់ធ្លាប់ជួបប្រទះហ្នឹងទេ។*[163]

៦៨. បន្ទាប់មក លោកវេជ្ជបណ្ឌិត បានលើកឡើងពីរោគសញ្ញាជាក់លាក់នៃការបាក់ស្បាត ដែលត្រូវបានបកប្រែថា “*រោគបាក់ស្បាត*” ហើយដែលជារោគសញ្ញាជាក់លាក់ កើតមានចំពោះជនរងគ្រោះសម័យខ្មែរក្រហម៖

*“លោក ឈឹម សុធារ៉ា៖ ឆ្លើយ៖ ពាក្យថា “បាក់ស្បាត” នេះយើងបកប្រែទៅជាភាសាអង់គ្លេស ខ្ញុំសូមបកប្រែ ព្រូកខិន ខៅរេជ (broken courage) បានន័យថា សេចក្ដីក្លាហានរបស់គាត់ហ្នឹងត្រូវបានបាក់។ នៅក្នុងវចនានុក្រមសម្ដេចសង្ឃ ជួន ណាត បាននិយាយថា បាក់ស្បាត ហ្នឹងគឺវាកើតមានមកពីពាក្យពីរ។ ពាក្យមួយថា “បាក់” ហើយនិងពាក្យ “ស្បាត”។ “បាក់” ហ្នឹងជាការបាត់បង់ ជាការបាក់បែក ហើយ “ស្បាត” ហ្នឹងគឺជារូបរាង ជាការបាក់បែកនូវរូបរាងដែលមិនអាចត្រឡប់មកភាពដើមវិញ។ ហើយសម្ដេចសង្ឃ ជួន ណាត ក៏បានធ្វើយោងទៅការប៉ះទង្គិចផ្លូវចិត្តដែលគាត់ត្រូវបានបាក់ ហើយនិងដូចថា អារម្មណ៍ផ្លូវចិត្តហ្នឹងត្រូវបានបាត់បង់ ហើយនិងខូចខាតហ្នឹង។ អ៊ីចឹង គឺថាអាហ្នឹងគឺជាអត្ថន័យជាទូទៅដែលខ្ញុំនិយាយទៅលើពាក្យ“បាក់ស្បាត” ប៉ុន្តែក្នុងផ្នែកចិត្តសាស្ត្រវិញពាក្យ “បាក់ស្បាត” ហ្នឹងគឺវាមានន័យជ្រៅជ្រះណាស់សម្រាប់រៀបរាប់អំពីទុក្ខលំបាក អំពីទារុណកម្ម អំពីការឈឺចាប់ផ្សេងៗដែលប្រជាជនកម្ពុជាយើងបានជួបប្រទះនៅក្នុងសម័យខ្មែរក្រហមហ្នឹង។”*[164]

៦៩. អាការៈរោគនេះ ត្រូវបានពន្យល់ផងដែរនៅក្នុងអត្ថបទសរសេរដោយលោកអ្នកជំនាញ និងត្រូវបានបង្ហាញនៅក្នុងសវនាការកាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣[165]។ ក្នុងអំឡុងពេលផ្ដល់សក្ខីកម្ម លោកវេជ្ជបណ្ឌិតបានលើកឡើងពីអារម្មណ៍នៃការបាត់បង់អត្តសញ្ញាណ អារម្មណ៍នៃការបាត់បង់សុវត្ថិភាពផ្ទាល់ខ្លួន បណ្ដាលមកពីការបោះបង់ចោលផ្ទះសម្បែង និងរបស់របរដែលមាននៅក្នុងនោះ[166]។ លោកក៏បានលើកឡើងជាបន្ថែម ពីផលវិបាកគួរឲ្យភ័យខ្លាចនៃភាពស្រេកឃ្លាន និងការភៀសខ្លួនទៅនៅបរទេស។ លោកក៏បានលើកឡើងពីអារម្មណ៍មួយចំនួន នោះគឺអារម្មណ៍គិតថាខ្លួនបានប្រព្រឹត្តកំហុស ដែលអាចកើតមានចំពោះអ្នកនៅរស់រានមានជីវិត។ តាមរយៈនេះ លោកបាន បញ្ជាក់អះអាងពីសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

៧០. នៅថ្ងៃទីពីរនៃការផ្ដល់សក្ខីកម្មរបស់ខ្លួន អ្នកជំនាញរូបនេះបានគូសបញ្ជាក់ពីភាពជាក់លាក់នៃព្យសនកម្មផ្លូវចិត្តដែលប៉ះពាល់ដល់ជនរងគ្រោះសម័យខ្មែរក្រហម ហើយលោកនៅតែសង្កត់ធ្ងន់លើទំហំនៃព្យសនកម្ម និងវិធីផ្សេងៗជាច្រើនក្នុងការបង្ហាញនូវព្យសនកម្មទាំងអស់នោះ ដែលក្នុងនោះមានដូចជា ការបាត់បង់ឫសគល់ ការបាត់បង់អត្តសញ្ញាណ ការបាត់បង់ទំនុកចិត្ត និង

ការបាត់បង់លក្ខណៈជាមនុស្ស[167]។ ជាថ្មីម្តងទៀត លោកវេជ្ជបណ្ឌិតបានអះអាងពីសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងពីខាងដើម។ បន្ទាប់មក លោកបានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការផ្តល់ការព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះនៃព្រឹត្តិការណ៍ទាំងនេះ។ នៅទីបញ្ចប់ពាក់ព័ន្ធនឹងការចូលរួមក្នុងការជំនុំជម្រះ លោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា បានគូសបញ្ជាក់ពីផលវិជ្ជមាននៃការចូលរួម ដោយផ្អែកលើកាសិក្សាមួយដែលត្រូវបានរៀបចំឡើងដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ លើក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង00១[168]។

៧១. ការសិក្សាមួយដែលបានធ្វើឡើងនៅប្រទេសកម្ពុជា[169] បានបង្ហាញឲ្យឃើញពីចំនួនជនរងគ្រោះយ៉ាងច្រើន ដែលនៅតែបន្តប៉ះពាល់ដោយអាការៈរោគមួយដែលមានឈ្មោះថា "ជំងឺកើតទុក្ខរយៈពេលយូរ" (*prolonged grief disorder* ឬ PGD) បន្ទាប់ពីរយៈពេលជាងសាមសិបឆ្នាំបានកន្លងផុតទៅ។

៧២. ការសិក្សាមួយដែលត្រូវបានធ្វើឡើងជាមួយជនរងគ្រោះដែលបានភៀសខ្លួនទៅសហរដ្ឋអាមេរិក បានបង្ហាញពីអត្រាខ្ពស់នៃរោគសញ្ញាជំងឺស្ត្រេសប៉ុស្តិ៍ត្រូម៉ាទិក ដែលកើតមានលើជនរងគ្រោះសម័យខ្មែរក្រហម (៦២ %) និងអត្រាខ្ពស់នៃជំងឺធ្លាក់ទឹកចិត្ត (៥១ %) បើប្រៀបធៀបទៅនឹងអត្រាចំនួនប្រជាជនអាមេរិកាំងជាទូទៅ[170]។ ការសិក្សាដដែលបានបង្ហាញឲ្យឃើញថា ជនរងគ្រោះសម័យខ្មែរក្រហមដែលរស់នៅសហរដ្ឋអាមេរិក មានកម្រិតសង្គមសេដ្ឋកិច្ច ការអប់រំ ស្ថានភាពមុខរបរ និងកម្រិតប្រាក់ចំណូលទាប។ ៧២ % នៃពួកគេ បានបញ្ជាក់ថាបានសុំជំនួយពីរដ្ឋាភិបាល[171]។

## គ. សេចក្តីសន្និដ្ឋានលើផលវិបាកនៃឧក្រិដ្ឋកម្ម

៧៣. អត្ថិភាពនៃព្យសនកម្មផ្សេងៗគ្នា មានដូចជា ព្យសនកម្មសម្ភារៈ ផ្លូវកាយ និងផ្លូវចិត្ត សម្រាប់ជនរងគ្រោះ និងតម្រូវការក្នុងការជួលជុលការខូចខាតទាំងអស់នោះ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់។ ព្យសនកម្មទាំងអស់នោះត្រូវបានលើកឡើង និងលាតត្រដាងថាជាផលវិបាកផ្ទាល់នៃអំពើឧក្រិដ្ឋដែលត្រូវបានជំនុំជម្រះនាពេលបច្ចុប្បន្ន។

៧៤. ទំនាក់ទំនងជាមួយសំណងដែលទាមទារ គឺពិតជាមានមិនអាចប្រកែកបាន។

ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានសម្តែងពីបំណងរបស់ខ្លួន មិនចង់ឲ្យព្រឹត្តិការណ៍ដ៏ជូរចត់ដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម ត្រូវបានគេបំភ្លេចឡើយ។ ពួកគាត់ចង់បានឲ្យមានជាពេលវេលា និងទីកន្លែងជាក់លាក់ ដើម្បីរំឭក និងឧទ្ទិសដល់អ្នកស្លាប់។ ពួកគាត់បានស្នើសុំឲ្យព្រឹត្តការណ៍ទាំងអស់នោះ គួរតែត្រូវបានរំឭកដោយថ្ងៃណាមួយជាក់លាក់ក្នុងប្រតិទិន និងនៅតាមកន្លែងស្តូបផ្សេងៗគ្នា។ ពេលវេលា និងទីកន្លែងនៃការរំឭក មិនមែនត្រូវបានរៀបចំឡើងសម្រាប់តែដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ពេលវេលា និងទីកន្លែងទាំងនោះ ចូលរួមក្នុងការចងចាំរួម ដែលជាករណីកិច្ចដ៏សំខាន់មួយចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

៧៥. ដើមបណ្តឹងរដ្ឋប្បវេណី ក៏មានបំណងទទួលបានផងដែរនូវវិធានការស្តារនីតិសម្បទា ដែលអាចអនុញ្ញាតឲ្យពួកគាត់អាចកាត់បន្ថយតាមដែលអាចធ្វើទៅបាន នូវផលវិបាកផ្លូវចិត្តដែលពួកគាត់បានទទួលរង។ ដូច្នេះហើយ បានជាពេលនេះ ពួកគាត់បានស្នើសុំឲ្យមានការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯងតាមរយៈការនិយាយ។ វាពិតជាមានសារៈប្រយោជន៍ក្នុងការកត់សម្គាល់ថា វិធានការទាំងអស់នេះមិនមែនសម្រាប់តែបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែវាអាចអនុញ្ញាតឲ្យមានការពិចារណារួមមួយ តាមរយៈសកម្មភាព មានដូចជា សក្ខីកម្ម ឬ ការផ្លាស់ប្តូរផ្សេងៗ។

៧៦. ជាចុងក្រោយ វានៅមានករណីយកិច្ចក្នុងការអប់រំ និងការចងក្រងឯកសារ។ សំណងសមូហភាព និងផ្លូវចិត្ត ក៏ជាចម្លើយតបមួយចំពោះការចង់បាននេះដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងចង់រៀបចំឲ្យមានការតាំងពិព័រណ៍ និងការចងក្រងឯកសារជាលាយលក្ខអក្សរ។ ពួកគាត់ក៏ចង់ឲ្យចាត់ទុកការបង្រៀនពីព្រឹត្តិការណ៍ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាជាផ្នែកមួយនៃប្រវត្តិសាស្ត្រប្រជាជនកម្ពុជា ដូចដែលមានបង្រៀននៅតាមសាលា។ ប្រភេទសំណងបែបនេះ គឺជាការគោរពដល់ជនរងគ្រោះផង និងក៏ជាមធ្យោបាយក្នុងការលើកតម្កើងការចងចាំរួមផងដែរ។

## IV. **សំណងដែលស្នើសុំ៖ ការឆ្លើយតបនឹងព្យសនកម្មដែលទទួលរង**

## **ក. គម្រោង៖ ការឆ្លើយតបសមស្របទៅនឹងព្យសនកម្មដែលទទួលរង**

៧៧. គម្រោងដូចខាងក្រោមនេះ គឺជាគម្រោងដែលឆ្លើយតបទៅនឹងប្យសនកម្មដែលទទួលរង និងដែលនឹងត្រូវធ្វើអធិប្បាយ។

៧៨. គម្រោងសំណងដូចខាងក្រោមនេះស្ថិតនៅក្នុងប្រភេទនៃសំណងដែលស្នើ ដោយដើមបណ្តឹងរដ្ឋប្បវេណី ឆ្លងការពិគ្រោះយោបល់រវាង មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាង

ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមានការសហការផងដែរជាមួយ អង្គភាពគាំពារជនរងគ្រោះ និងអង្គការអន្តរការីពាក់ព័ន្ធ។

៧៩. គម្រោងសំណងទាំងនេះស្ថិតនៅក្នុងប្រភេទ ចំនួន បី ដូចធ្លាប់បានលើកជូននៅក្នុងសេចក្តីបញ្ជាក់បឋម នៅថ្ងៃទី ២៩ មិថុនា ២០១១ និងនៅថ្ងៃទី ១៩ តុលា ២០១១។ ហើយក៏មានគម្រោងចំនួនពីរ គឺ ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រម និងការចុះឈ្មោះដើមបណ្តឹងរដ្ឋបវេណីនៅក្នុងគេហទៅព័ររបស់អ.វ.ត.ក ដែលត្រូវបានលើកនៅក្នុងសេចក្តីបញ្ជាក់បឋម ត្រូវបានបញ្ចូលក្នុងគម្រោងគម្រោងអទិភាព នាពេលនេះ។

៨០. សម្រាប់គម្រោងនិមួយៗ នឹងត្រូវពិនិត្យជាបន្តបន្ទាប់នូវ ការពិព័ត៌នា ដែលរួមបញ្ចូលទាំងបុគ្គល និងអង្គការទទួលបន្ទុកអនុវត្ត គោលដៅដែលឆ្លើយតបនឹងព្យសនកម្មដែលទទួលរង និងអ្នកទទួលផលប្រយោជន៍ ការអនុវត្តដែលរួមមានរយៈពេល ថវិកា និងសេចក្តីអនុញ្ញាតដែលចាំបាច់ និងភាពដែលអាចធ្វើបានរហូតដល់ពេលដាក់ពាក្យសុំទទួលស្គាល់សំណងទាំងនេះ។

## ជំពូក១. ការរំឭក និងការគោរពវិញ្ញាណក្ខ័ន្ធ

៨១. សំណងនេះមានគោលដៅគោរពវិញ្ញាណក្ខ័ន្ធដល់អ្នកដែលបានស្លាប់ និងជនរងគ្រោះ។ ហើយជាឱកាសមួយដើម្បីឱ្យ អ្នកដែលបាននៅរស់រានមានជីវិត ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាមនុស្សជំនាន់ក្រោយបានពិចារណា អំពីអ្វីដែលបានកើតឡើង និងប្រារព្ធពិធីនានាតាមជំនឿ និងសាសនារបស់ខ្លួន។ ជំពូកនៃសំណងនេះបានច្របាច់បញ្ចូលនូវគម្រោងដែលមាន *ទិវានៃការចងចាំ* (គម្រោងទី១) *ការសាងសង់ចេតីយ ស្តូប ឬបូជនីយដ្ឋានសាធារណៈ* (គម្រោងទី២) *ការសាងសង់បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ* (គម្រោងទី៣) និង*ការកសាងស្តូបនៅបារាំងសម្រាប់ជនជាតិខ្មែរដែលរស់នៅទីនោះ(គម្រោងទី៤)*

### <u>គម្រោងទី១: ទិវាជាតិនៃការចងចាំ</u>

### ក- ការពិពណ៌នាអំពីគម្រោងសំណង

៨២. ដើមបណ្តឹងរដ្ឋប្បវេណីចង់ស្វែងរកការបង្កើតឱ្យមានថ្ងៃចងចាំជាផ្លូវការដែលជាថ្ងៃសម្រាកមួយផ្សេងពីថ្ងៃសម្រាកដែលមានបច្ចុប្បន្ន។ វាជាថ្ងៃណាមួយក្នុងចំណោម ថ្ងៃ ១៧ មេសា ឬថ្ងៃ២០ ឧសភា ឬថ្ងៃ៣០ មិនា។ ថ្ងៃទាំងអស់នេះ ត្រូវបានស្នើឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីបានពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន។

៨៣. ទិវានេះនឹងអាចប្រើប្រាស់ជាសេរីទូទាំងប្រទេស ថាជាការទទួលស្គាល់ជាផ្លូវការ និងអចិន្ត្រៃយ៍នូវឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិក្នុងរបបខ្មែរក្រហម។ គេរៀបចំនូវពីធីបុណ្យនានា សន្និសិទ ល្ខោន ឬព្រិត្តិការនានាដែលបាក់ព័ន្ធនឹងការរំលឹកនេះ។

## ខ- គោលដៅ និងអ្នកទទួលប្រយោជន៍

៨៤. ការកំណត់យកថ្ងៃនេះក្នុងគោលដៅបង្កើតជាទិវាមួយសម្រាប់ជាការស្តារកិត្តិយសដល់ជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអ្នកដែលបានស្លាប់ និងអ្នកដែលនៅរស់ រំលឹកនូវការឈឺចាប់ បុគ្គលដែលជាទីស្រលាញ់របស់ខ្លួន និងលើកតម្កើងការចងចាំនូវឧក្រិដ្ឋកម្មប្រព្រិត្តក្នុងអំឡុងពេលរបបខ្មែរក្រហម ជួយឱ្យមានការសះជានូវការឈឺចាប់ផ្លូវចិត្ត និងស្តារកិត្តិយសរបស់ជនរងគ្រោះ។ វាក៏ជាថ្ងៃដែលមានតួនាទីសំខាន់ក្នុងការអប់រំ និងតប់ស្កាត់មិនឱ្យអំពើបែបនេះកើតឡើងសារជាថ្មីម្តងទៀតក្នុងប្រទេសកម្ពុជា។

៨៥. ចំពោះអ្នកទទួលប្រយោជន៍ គម្រោងដែលមានសារៈសំខាន់ជានិមិត្តរូបនេះនឹងបានជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាប្រជាជនកម្ពុជា អាចជួបជុំគ្នា និងរៀបចំពិធីបុណ្យនានា។

## ខ- ការអនុវត្តគម្រោង

៨៦. គម្រោងនេះអាច អនុវត្តទៅបាន គឺត្រូវការសេចក្តីសម្រេចពីរាជរដ្ឋាភិបាលក្នុងការកំណត់យកថ្ងៃមួយ សម្រាប់ជាទិវានៃការចងចាំនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើសុំទៅរដ្ឋាភិបាលដើម្បីកំណត់ជាគោលការណ៍យកថ្ងៃមួយ ក្នុងចំណោមថ្ងៃជាច្រើន ផ្សេងទៀត ដើម្បីធ្វើជា *ទិវានៃការចងចាំ*[172] ហើយសុំឱ្យបង្កើតអនុក្រឹត្យ មួយស្តីពីការបង្កើត *ទិវានៃការចងចាំ*នេះ។

៨៧. ក្នុងលិខិតដែលឆ្លើយតបនឹងមេធាវីនាំមុខ រាជរដ្ឋាភិបាលបានឯកភាពផ្តល់ការអនុញ្ញាតជាគោលការណ៍តាមការស្នើសុំ[173] និងបានកំណត់យក ថ្ងៃទី ***២០ ខែឧសភា*** ជា ***ទិវាជាតិនៃការចងចាំ*** នៅក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ហើយ រដ្ឋាភិបាលនឹងចេញអនុក្រឹត្យនាពេលខាងមុខស្តីពីការបង្កើតទិវានេះ ព្រមទាំងអាចចេញ សារាចរណែនាំ ឬសេចក្តីជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធនឹងការអនុវត្តគម្រោង។

៨៨. ដោយយោងតាមការបញ្ជាក់របស់អង្គជំនុំជម្រះថា[174] ការអនុវត្តសំណងទាំងឡាយអាចនឹងចាប់ផ្តើម មុនការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១។ ដូច្នេះ មានន័យថាការ អនុវត្តសំណងមួយនេះ អាចអនុវត្តទៅបានគ្រប់ពេលទាំងអស់។

៨៩. គម្រោងនេះមិនត្រូវការឲ្យមានចំណាយថវិកាទេ។ ប៉ុន្តែជាការសោកស្ដាយដែលមិនមានលទ្ធភាពទទួលបានថវិកាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលចង់ប្រារព្ធពិធី ឬធ្វើសកម្មភាពនានាក្នុងអំឡុងពេលនៃទិវានេះ។

**គ- ភាពអាចធ្វើបាន**

៩០. ដោយមានការព្រមព្រៀងជាគោលការណ៍ពីរាជរដ្ឋាភិបាល គម្រោងនេះអាចអនុវត្តបានទាំងស្រុង។

**<u>គម្រោងទី២: គម្រោងសាងសង់ស្តូបសាធារណៈ</u>**

**ក- ការពិពណ៌នាអំពីគម្រោងសំណង**

៩១. គម្រោងនេះត្រូវបានស្នើសុំស្ទើតែគ្រប់ក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ហើយដែលគម្រោងនេះ គឺជាការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ នៃ អ.វ.ត.ក។ ការសាងសង់ស្តូបសម្រាប់រំឭកជាសាធារណៈនេះគឺបង្កើតឡើងសម្រាប់តម្កល់ឆ្អឹងធាតុរបស់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាច់ញាតិផ្សេងៗទៀត ជនដែលរស់ និងសាធារណៈជន ដើម្បីមានឱកាសអុចធូប ធ្វើបុណ្យឧទ្ទិស ដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតទៅនៅក្នុងរបបខ្មែរក្រហមក្នុងលក្ខណៈ មួយដែលយូរអង្វែង និងជាសមូហភាព។

៩២. ទីតាំងនៃការកសាងស្តូបសម្រាប់ការរំឭកជាសាធារណៈនឹងត្រូវជ្រើសរើសដោយសហគមន៍មូលដ្ឋាន និងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដែលមានបំណងធានាថាទីកន្លែងនេះអាចឲ្យគេទៅដល់បាន អាចរក្សាបាន និងសាងសង់ដោយផ្អែកតាមធនធាន និងសមត្ថភាពដែលអាចធ្វើទៅកើត។ ជាដំណាក់កាលដំបូង សហគមន៍ពិចារណាក្នុងការជ្រើសរើសទីកន្លែងដែលត្រូវសាងសង់ បន្ទាប់មកជាដំណាក់កាលសាងសង់ ព្រមទាំងមានសកម្មភាពចូលរួមនានារបស់សហគមន៍រួមទាំងអ្នកដែលជាជនរងគ្រោះ និងអ្នកដែលមិនមែនជាជនរងគ្រោះ។ បូជនីយដ្ឋានទាំងនេះនឹងរួមមានផ្នែកអប់រំផងដែរ ដែលធ្វើឲ្យសាធារណជនមានការយល់ដឹង និងបទពិសោធន៍ច្រើនពីរបបខ្មែរក្រហម។

៩៣. អង្គការចំនួនពីរដែល ទទួលក្នុងការអនុវត្តគម្រោងនេះ គឺក្ដីករុណា និងយុវសន្តិភាព ដែលធ្លាប់បានធ្វើកិច្ចការពាក់ព័ន្ធនឹងការចងចាំ ការអប់រំ និងការងារសហគមន៍[175]។ អង្គការទាំងនេះ នឹងសន្សាក្នុងការអនុវត្តគម្រោងនេះ[176]។

## ខ- គោលដៅ និងអ្នកទទួលប្រយោជន៍៖

៩៤. គម្រោងសំណងនេះមានគោលដៅទី១ ស្តារកិត្តិយស សេចក្តីថ្លៃថ្នូរ ប៉ះប៉ូវការឈឺចាប់ ផ្លូវចិត្ត និងផ្នែកសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រំឭកដល់អ្នកដែលបានបាត់បង់ជីវិត លើកកម្ពស់ការយល់ដឹង និងការស្វែងយល់រួមគ្នាពីប្រវត្តិសាស្ត្រខ្មែរក្រហម។ គម្រោងនេះសំដៅផងដែរក្នុងផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋានអំពីអង្គហេតុនៅក្នុងសំណុំរឿង ០០២/០១ (ការជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ)។ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអនុញ្ញាតឱ្យដើមបណ្តឹង រដ្ឋប្បវេណីមានឱកាសក្នុងការនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួន ក៏ដូចជាបទពិសោធន៍ដ៏ជូរចត់ក្នុងរបបខ្មែរក្រហម។ គម្រោងនេះសំដៅឱ្យមានការសាមគ្គីក្នុងសហគមន៍ និងលប់បំបាត់ការបែងចែកដែលបណ្តាលពីរបបខ្មែរក្រហម ក្នុងគោលដៅផ្សះផ្សាសង្គម និងទប់ស្កាត់អំពើឃោរឃៅនេះ កុំឱ្យកើតមានឡើងជាថ្មីទៀត។ ដោយសុំឱ្យមាន ការចូលរួមពី បុគ្គល និងសហគមន៍ ក្នុងការរៀបចំ ក៏ដូចជាការចូលរួមរបស់សមាជិកសង្គមផ្សេងទៀត គម្រោងនេះ នឹងមានលទ្ធភាពកាន់តែច្រើនក្នុងការសម្រេចបាននូវគោលដៅរបស់ខ្លួន។ ការសម្រេចនូវគម្រោងនេះ នឹងនាំមកនូវការទទួលស្គាល់ជាអចិន្ត្រៃយ៍ និងផ្លូវការដល់ព្យសនកម្មដែលបានទទួលរង។ វានឹងក្លាយជាទីគោរពបូជា និងបង្កើតសន្តិភាព។

៩៥. គម្រោងនេះនឹងផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ប្រជាជនមូលដ្ឋាន ព្រមទាំងមនុស្សជំនាន់ក្រោយនូវឱកាសជួបជុំគ្នា និងស្វែងយល់តាមរយៈការរាយរ៉ាប់របស់ជនរងគ្រោះនូវអ្វីដែលបានកើតឡើង។ សកម្មភាពនេះនឹងជួយឱ្យឈានទៅអនាគតដោយមានគំនិតគតិបណ្ឌិត។

៩៦. គម្រោងទាំងនេះនឹងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ផ្តល់ផលប្រយោជន៍ផងដែរដល់សាធារណៈជនទូទៅ។

## គ- ការអនុវត្តគម្រោង

៩៧. គម្រោងនេះ ត្រូវបានប្រគល់ជូនអង្គការមិនមែនរដ្ឋាភិបាលពីរដើម្បីអនុវត្តគឺ ***អង្គការយុវសន្តិភាព*** និង ***អង្គការក្តីករុណា***[77] ដែលមានបទពិសោធន៍ ច្រើននៅក្នុងការបង្កើតបូជនីយដ្ឋានដែលមាននិរន្តភាពតាមរយៈ ដំណើរការពិគ្រោះយោបល់ជាមួយ សហគមន៍ និងដើរតួនាទីជាដៃគូអនុវត្តសម្រាប់គម្រោង ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីរៀបចំអនុវត្តគម្រោងសំណងមួយនេះ។

៩៨. **ចំពោះតម្រូវការឯកសារចាំបាច់បន្ថែមសម្រាប់គម្រោង** សម្រាប់គម្រោងសំណង និងវិធានការទាក់ទង នឹងការអនុវត្តគម្រោងទាំងនេះ យើងបានស្នើទៅ រាជរដ្ឋាភិបាលដើម្បីចេញលិខិតដើម្បីបង្គាប់ដល់ ស្ថាប័នពាក់ព័ន្ធក្រោមឱវាទនានា ដើម្បីសម្របសម្រួលអនុវត្តគម្រោងនេះ។ សម្រាប់គម្រោងសំណង និងវិធានការទាំងនេះ ក្នុងករណីដែលចាំបាច់ រាជរដ្ឋាភិបាលនឹង ចេញជាអនុក្រឹត្យ សារាចរណែនាំ ឬសេចក្តីជូន ដំណឹងដល់ស្ថាប័នពាក់ព័ន្ធនានា យោងតាមកម្មវត្ថុ នីមួយៗ ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ និងអាជ្ញាធរដែនដី ខណ្ឌ-ស្រុក រាជធានី-ខេត្ត ក្រុង[178]។ លើសពីនេះទៅទៀត អង្គការយុវសន្តិភាព និងក្តីករុណា មានបទពិសោធន៍ក្នុងការអនុវត្តកម្រោងបែបនេះ និងបំពេញបែបបទដែលចាំបាច់បន្ថែមនៅពេលដែលទីតាំងជាក់លាក់ត្រូវបានជ្រើសរើស លើកលែងតែមានការបដិសេធក្នុងការអនុញ្ញាតឲ្យសាងសង់ក្នុងទីតាំងមួយជាក់លាក់។

៩៩. គម្រោងនេះត្រូវបានរៀបចំសម្រាប់អនុវត្តក្នុងរយៈពេល ៣៦ ខែ។

១០០. ចំពោះបញ្ហាថវិកា រហូតដល់ពេលនេះពុំទាន់មានទទួលថវិកាសម្រាប់គម្រោងនេះនៅឡើយទេ។

**គ- ភាពអាចធ្វើបាន៖**

១០១. ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដល់អង្គជំនុំជម្រះកុំឲ្យច្រាចោលគម្រោងទាំងនេះ ដោយផ្តល់លទ្ធភាពដល់ក្នុងការស្វែងរកថវិកា ក្នុងពេលចៅក្រមកំពុងពិភាក្សា។ ក្នុងករណីដែលមានថវិកា ដើមបណ្តឹងរដ្ឋប្បវេណីនឹងបញ្ជាក់ថាតើគម្រោងនេះនឹងអាចអនុវត្តបានកម្រិតណា។ ដើមបណ្តឹងស្នើសុំឲ្យទទួលស្គាល់ថាជាគម្រោងសំណង។

**<u>គម្រោងទី៣៖ ការសាងសង់បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ</u>**

**ក- ការពិពណ៌នាអំពីគម្រោង**

១០២. គម្រោងសិល្បៈ “ជូនចំពោះអ្នកដែលបានបាត់បង់ជីវិត” គឺជាគំនិតដែល ផ្តួចផ្តើមដោយសិល្បៈករស្ងួនរូបខ្មែរ-បារាំងមួយរូបឈ្មោះ **សោភា**[179] ជាសិស្សៈករមួយរូបដែលត្រូវបានចាត់ចំណាត់ ថ្នាក់ថានៅក្នុងចំណោមសិល្បៈករចំនួន ១០១ ដែលប្រសើរបំផុតនៅប្រទេសបារាំងប្រចាំឆ្នាំ២០០២-២០១២។ គម្រោងនេះមានគោលដៅរំលឹកដល់ព្រឹត្តការណ៍ជាក់លាក់ដែលកើតមាននៅពេល ១៧ មេសា ១៩៧៥ ដែលជាចំនុចចាប់ផ្តើមនៃវិនាសកម្មលើ ប្រជាជនកម្ពុជា។ ការចាប់ចេញដំណើពី

ភ្នំពេញ ដោយការបង្ខិតបង្ខំ និងដែលគ្រប់គ្រងដោយពួកខ្មែរក្រហម ដោយបង្កើតនូវអនាគតមួយ ដែលមិនប្រាកដប្រជា និងរងទុក្ខវេទនាបំផុត នៅទីបញ្ចប់។

១០៣. ការជ្រើសរើសយកទីតាំងនៅមុខទូតបារាំងជាទីកន្លែងសម្រាប់តម្កល់រូបចម្លាក់ទាំងនេះ ដោយសារទីកន្លែងនេះ ជាចំនុចមួយនៃទីក្រុងភ្នំពេញ ដែលជាផ្លូវច្រកចេញនៃប្រជាជនជាច្រើន ដែលត្រូវបានជម្លៀសជាចំណុចនៅមុខស្ថានទូតបារាំង ដែលជាទីដែលមនុស្សរាប់ពាន់នាក់បានមកជ្រកខ្លួននៅទីនោះ រួចចេញពីទីក្រុងភ្នំពេញ ក្រោយគេបង្អស់។ លើសពីនេះ វាងាយស្រួលសម្រាប់ប្រជាពលរដ្ឋដែលចាប់អារម្មណ៍នឹងរូបចម្លាក់ មកស្វែងយល់ ឬអនុញ្ញាតឲ្យអ្នកដែលចង់រំឭក ឬឧទ្ទិសដល់អ្នកដែលបានស្លាប់ទៅ។

១០៤. ទាំងនេះគឺជាបណ្តុំនៃរូបចម្លាក់[180]ដែលជាកម្មវត្ថុនៃគម្រោងមានលក្ខណៈជាសិល្បៈ ដែលតំណាងឲ្យការចាកចេញនៃប្រជាជនខ្មែរពីភ្នំពេញ និងទីក្រុងទាំងអស់នៅក្រុងប្រទេស។

១០៥. សិល្បករូបនេះនឹងអនុវត្តគម្រោង[181]នេះ ដោយមានការគាំទ្រដោយសមាគមន៍មួយ និងសហគ្រាសនានា[182]។

**ខ- គោលដៅ និងអ្នកទទួលប្រយោជន៍**

១០៦. គម្រោងនេះជាការឧទ្ទិសដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។ វាជាកន្លែងគោរពបូជា និងទស្សនា។ វារំលឹកអំពីព្រឹត្តការណ៍នានាដែលបានកើតឡើង។

១០៧. គម្រោងនេះ នឹងត្រូវសម្រេចឡើងដោយសិល្បៈករមួយរូបដែល ពេលនោះជាកុមារ ដែលបានឃើញពីស្ថានទូតបារាំងនូវ ការជម្លៀសពីទីក្រុង ដែលនេះនឹងផ្តល់តំលៃជានិមិត្តរូប ដ៏គួរឲ្យកត់សំគាល់។

១០៨. ដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះនៃការជម្លៀស និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលមានសាច់ញាតិត្រូវបានជម្លៀស នៅពេលខ្មែរក្រហមចូល និងគ្រប់គ្រងភ្នំពេញ នឹងទទួលបាននូវទីកន្លែងមួយ និងរូបចម្លាក់ដែល គេប្រោះសម្រាប់គោរពបូជា និងធ្វើពិធីនានាតាមប្រពៃណី សាសនា និងជំនឿរបស់ខ្លួន។

១០៩. ដោយសារទីតាំង និងលក្ខណៈសិល្បៈរបស់វា គម្រោងនេះនឹងផ្តល់ជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ព្រមទាំងសាធារណៈជនទូទៅ ទាំងខ្មែរ និងបរទេស។

**គ- ការអនុវត្តគម្រោង**

១១០. គម្រោងនេះ មានការចូលរួមអនុវត្តពីសហគ្រាសជាច្រើន និងអន្តរាគមន៍អំពី លោក សោភា ផ្ទាល់ ដែលមានរយៈប្រហែល ១ឆ្នាំ។

១១១. ថវិការទាំងមូលនាពេលនេះមានចំនួន ៥៧.៧០០ អឺរ៉ូ[183]។ គម្រោងនេះ បានទទួលថវិកាពីប្រទេសបារាំងចំនួន ៥០.០០០ អឺរ៉ូ និងពីបុគ្គលឯកជន និងសមាគមន៍ដែលអនុវត្តគម្រោងនេះចំនួន ៧.៧០០អឺរ៉ូ ។ លិខិតបញ្ជាក់ថវិកាត្រូវបានផ្តល់ដោយ ស្ថានទូតនៃប្រទេសបារាំង[184] និងម្ចាស់ជំនួយផ្សេងទៀត[185]។

១១២. សេចក្តីអនុញ្ញាតពីសាលាក្រុងភ្នំពេញត្រូវមានជាចាំបាច់។ ទីតាំងដែលជាកម្មវត្ថុនៃស្តូបរូបចម្លាក់ គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលស្ថិតក្នុងការអនុញ្ញាតដោយសាលារាជធានីភ្នំពេញ ។ ទូតបារាំងបានទាក់ទងជាមួយសាលារាជធានីភ្នំពេញ និងបានទទួលលិខិតអនុញ្ញាតឲ្យសាងសង់ស្តូបនេះ នៅក្នុងសួនច្បារ។

**គ- ភាពអាចធ្វើបាន៖**

១១៣. គម្រោងនេះអាចចាប់ផ្តើមអនុវត្តបាននៅគ្រប់ពេល។

***<u>គម្រោងទី ៤ ៖ ការកសាងស្តូបរំលឹកដល់ជនរងគ្រោះរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរនៅបារាំង</u>***

## ក- ការពិពណ៌នាពីគម្រោង

១១៤. ជនចំណាកស្រុកខ្មែរដែលនៅក្រៅប្រទេសមួយភាគដែលនៅបារាំង រៀបចំពិធីបុណ្យនានានៅ វត្តវាំងសែន ក្នុងឧទ្យានវាំងសែន ស្ថិតនៅខណ្ឌទី១២ នៃរដ្ឋធានី ប៉ារីស។ នៅទីនោះ ស្តូបតូចមួយអាចត្រូវកសាងឡើងសម្រាប់ឧទ្ទិសដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។ គេធានាថា មនុស្សអាចទៅទីនោះគ្រប់ពេលបាន ដើម្បីធ្វើការឧទ្ទិសដោយសេរី និងគ្រប់ពេល។

១១៥. សមាគមន៍ចំនួនបីចូលរួមក្នុងការអនុវត្ត៖ សមាគមជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម(VGKR), សមាគមន៍រំលឹកដល់ជនរងគ្រោះនៃអំពើប្រល័យពូជន៍សាសន៍នៃរបបខ្មែរក្រហម (MVGKR), សម្ព័ន្ធអន្តរជាតិនៃសិទ្ធិមនុស្ស (FIDH)[186]។

**ខ- គោលដៅ និងអ្នកទទួលផលប្រយោជន៍**

១១៦. ការកសាងស្តូបនេះអនុញ្ញាតឲ្យខ្មែរដែលនៅបារាំង ទទួលបាននូវទីសម្រាប់ឧទ្ទិស នៅទីកន្លែងដែលពួកគាត់បានជ្រើសរើស ថានឹងរស់នៅជាអចិន្ត្រៃយ៍ បន្ទាប់ពីត្រូវបានបង្ខំឲ្យចាក់ចេញដោយរបបខ្មែរក្រហម និងផលវិបាករបស់វា និងអាចរំលឹកដល់អ្នកដែលបានស្លាប់ទៅក្រោមរបបនេះ។ ពិធីសម្ពោធមួយនឹងរៀបចំឡើង។ បន្ទាប់មកទីកន្លែងនេះ នឹងក្លាយជា ទីកន្លែងជួបជុំរបស់ខ្មែរសម្រាប់ធ្វើបុណ្យ និងរំលឹកវិញ្ញាណក្ខន្ធប្រចាំឆ្នាំ។

១១៧. ស្តូបបែបនេះ រឹតតែសំខាន់ទៅទៀតដោយសារ ប្រជាជនខ្មែរជាច្រើន មិនអាចស្វែងរកឆ្អឹងសាច់ញាតិខ្លួនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម។

១១៨. ទីសក្ការនេះនឹងផ្តល់លទ្ធភាពផងដែរ ក្នុងការឧទ្ទិសដល់អ្នកដែលបានបាត់ខ្លួន។ ស្តូបនេះនឹងអនុញ្ញាតឲ្យរំលឹក ជាអចិន្ត្រៃយ៍ និងសមូហភាព អនុស្សាវរីយ៍នៃជនរងគ្រោះ និងការចាប់អារម្មណ៍នៃមនុស្សជំនាន់ក្រោយ និងសាធារណជន។

១១៩. គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ជា បឋមដល់ជនរងគ្រោះនៃរបបខ្មែរក្រហម។ វាផ្តល់ផលប្រយោជន៍ផងដែរដល់ ក្មេងជំនាន់ក្រោយ និងសាធារណៈជន។

## គ- ការអនុវត្ត៖

១២០. គម្រោងនេះអាចត្រូវបានអនុវត្តក្នុងរយៈពេល ១ ឆ្នាំចាប់ពីពេលនេះតទៅ។ ពេលនៃកកើតគម្រោង រួមទាំងការអនុញ្ញាត សាងសង់ ដែលពេលនេះ កំពុងត្រូវបានធ្វើ នៅសាលាក្រុង ប៉ារីស ដែលពេលនេះបានទទួល ការឯកភាព ជាគោលការណ៍រួចហើយ[187]។

១២១. ការស្វែងរកថវិកា បានចាប់ផ្តើម ផងដែរ ក្នុងការស្វែងរកពីសំណាក់ សាលាក្រុងប៉ារីស មូលនិធិបារាំង និងស្ថានទូតមួយចំនួន[188]។

## ឃ- ភាពអាចធ្វើបាន៖

១២២. នៅក្នុងលិខិតដែលលើកឡើងខាងលើ សម្ព័ន្ធអន្តរជាតិនៃសិទ្ធិមនុស្ស (FIDH) បានចាប់ផ្តើមដំណើការស្នើសុំ និងបានសន្យាជាគោលការណ៍ក្នុងការអនុវត្តគម្រោងនេះ។ មេធាវីនាំមុខ ស្នើសុំដល់អង្គជំនុំជម្រះ អនុញ្ញាតថាព័ត៌មានពាក់ព័ន្ធនឹងការផ្តល់ថវិកា ឬ សេចក្តីអនុញ្ញាត ត្រូវបានផ្តល់អំឡុងពេល ចៅក្រមពិភាក្សា ដើម្បីឲ្យគម្រោងនេះ ត្រូវបានទទួលស្គាល់ ជាប្រយោជន៍ នៃជនរងគ្រោះ។

## ជំពូកទី ២ ការស្តារនីតិសម្បទា

១២៣. ក្នុងជំពូកនេះមានគម្រោងពីរគឺ វិធីព្យាបាលតាមរបៀបចងក្រងសក្ខីកម្ម និង ក្រុមជួយខ្លួនឯង ដែលគម្រោងទាំងពីរនេះនឹងត្រូវអនុវត្តដោយ អង្គការចិត្តសង្គមអន្តរវប្បធម៌ (អង្គការធីភីអូ)។

**<u>គម្រោងទី ៥ "វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម"</u>**

### ក- ការពិពណ៌នាអំពីគម្រោងសំណង

១២៤. សំណងនេះត្រូវបានស្នើសុំជាច្រើន ដោយដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងរបស់ពួកគេដើម្បីឱ្យមានការព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ពួកគេ ដែលទទួលរងពីការប្រព្រឹត្តដោយអំពើឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយអ្នកជំនាញផ្នែកផ្លូវចិត្ត ។

១២៥. គម្រោងសំណង "វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម" គឺធ្វើឡើងដោយការនិយាយរាយរាប់ពីរឿងរ៉ាវដែលកើតឡើងចំពោះខ្លួន សមាជិកគ្រួសារ សាច់ញាតិពីការឈឺចាប់ផ្លូវចិត្តដែលទទួលរងពីអំពើឧក្រិដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាសាធារណៈដោយមានវត្តមានរបស់អ្នកជំនាញផ្នែកផ្លូវចិត្ត និងបុគ្គលមួយចំនួនចូលរួមផងដែរ។

១២៦. ក្នុងការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអញ្ជើញមកនិយាយពីបទពិសោធន៍ដ៏តក់ស្លុតរបស់ពួកគេ។ ជាមួយនឹងការជួយពីសំណាក់អ្នកជំនាញផ្លូវចិត្ត ពួកគាត់នឹងរំឭកនូវការចងចាំដ៏ឈឺចាប់របស់ខ្លួន និងបង្កើតវាឱ្យទៅជាឯកសារជាលាយលក្ខណ៍អក្សរមួយហៅថា *សក្ខីកម្ម*។ ក្នុងដំណាក់កាលបន្ទាប់ *សក្ខីកម្ម* ទាំងនេះនឹងត្រូវបានអានឮៗ ក្នុងអំឡុងពេលពិធីបុណ្យជាសាធារណៈទូទាំងប្រទេស ជិតទីកន្លែងរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ពិធីបុណ្យទាំងនេះ នឹងអាចរាប់បញ្ចូលទាំងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម សមាជិកគ្រួសារ សមាជិកក្នុងសហគមន៍ អ្នកដឹកនាំសាសនា អ្នកនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល។ បន្ទាប់ពីពិធីបុណ្យ សក្ខីកម្មនឹងប្រគល់ជូនឱ្យទៅ ដើមបណ្តឹងរដ្ឋប្បវេណី។

១២៧. អ្នកជំនាញផ្នែកផ្លូវចិត្តចំនួន ៦នាក់ ដែលរាប់បញ្ចូលទាំងអ្នកសម្របសម្រួល គម្រោង នឹងត្រូវបានជ្រើសរើសសម្រាប់ធ្វើការ។ អ្នកទាំងនោះ នឹងទទួលការខុសត្រូវសម្រាប់ផ្តល់ប្រឹក្សាយោបល់ទាក់ទងនឹងការព្យាបាលផ្លូវចិត្តតាមបែបសក្ខីកម្ម។ ពួកគេទាំងអស់គ្នា នឹងត្រូវបានធ្វើការបណ្តុះ

បណ្តាលអំពីវិធីសាស្ត្រនៃ ការព្យាបាលផ្លូវចិត្តតាមបែបសក្ខីកម្មក្នុងរយៈពេល៥ថ្ងៃ សម្រាប់ ២ សប្តាហ៍។

១២៨. ការអនុវត្តគម្រោងនេះនឹងធ្វើឡើងដោយ ធីភីអូ ដែលបានបង្កើតឡើងនៅភ្នំពេញ តាំងពី ១៩៩៥ និងដែលមានបេសកកម្មធ្វើការងារផ្លូវចិត្តជាមួយប្រជាជនខ្មែរ។ ធីភីអូ បានបង្កើតឱ្យមានកម្មវិធីជាក់លាក់មួយសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម និងបានគាំពារអ្នកទាំងនេះ នៅ អវតក។ អង្គារនេះបានបំពេញ ការងាររបស់ខ្លួនប្រកបដោយជោគជ័យ។[189] អង្គការនេះ ក៏បានសន្យាថានឹងអនុវត្តគម្រោងនេះ ផងដែរ។

១២៩. អង្គការ ធី.ភី.អូ នឹងធ្វើការកំណត់ អំពីតំបន់ដែលដើមបណ្តឹង រដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។ ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានអញ្ជើញមកការិយាល័យកណ្តាលរបស់អង្គការ ធី.ភី.អូ នៅទីក្រុងភ្នំពេញ ដើម្បីចូលរួម ដំណើរការព្យាបាលផ្លូវចិត្តក្នុងរយៈពេល ៤ ទៅ ៥ថ្ងៃ ដែលនឹងប្រារព្ធធ្វើក្នុងពិធីបុណ្យលក្ខណៈ សាសនាជាសាធារណៈនៅក្នុងវត្តអារាម ឬវិហារ ដែលបានជ្រើសរើស ។ អ្នកចូលរួមក្នុងការ ព្យាបាលផ្លូវចិត្តតាមបែបសក្ខីកម្ម អាចស្នើសុំសេវាប្រឹក្សាយោបល់អំពីផ្លូវចិត្តតាមទូរស័ព្ទក្នុងរយៈ ពេលនៃគម្រោងបានក្នុងម៉ោងធ្វើការ។ ក្រៅពីនេះ អង្គការនឹងបោះពុម្ពសៀវភៅ/ក្រដាសផ្សព្វផ្សាយ ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងគម្រោងនេះ។

**ខ- គោលបំណង និងអ្នកទទួលផលប្រយោជន៍**

១៣០. គម្រោងសំណងនេះ មានគោលដៅលើកកម្ពស់ការព្យាលបាល និងការបង្រួបបង្រួមជាតិតាមរយៈការផ្តល់សំណងសមូហភាព និងផ្លូវចិត្ត និងបង្កើតសេវាសុខភាពផ្លូវចិត្ត និងរូបកាយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងការឈឺចាប់ ឬក៏មានជម្ងឺដោយហេតុនៃឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម។

១៣១. គម្រោងនេះកម្មវត្ថុ ធ្វើឱ្យប្រសើរឡើងនៃសុខមាលភាពផ្លូវចិត្តរបស់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ជម្រុញឱ្យមានការរាយរាប់រឿងរ៉ាវពិតដែលកើតឡើង និងការចងចាំទាំងឡាយនៅក្នុងសហគមន៍ប្រជាជននៅតាមទីជនបទ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបាននាំទៅ ពន្យល់អំពីបទពិសោធន៍ដ៏តក់ស្លុតរបស់ខ្លួន។ បន្ទាប់មក គម្រោងនឹងផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្តារសេចក្តីថ្លៃថ្នូរ ការជឿជាក់លើខ្លួនឯង ថាមពល និងសមត្ថភាពរបស់ខ្លួន។ គម្រោងនេះអនុញ្ញាតឱ្យពួកគេស្វែងរកតុល្យភាពនៃអារម្មណ៍ និងដើម្បីគ្រប់គ្រងអតីតកាល និងការពិបាកផ្លូវចិត្តរបស់ពួកគេដែលមានរហូតដល់ពេលនេះ។

១៣២. គម្រោងនេះរាប់បញ្ចូលដើមបណ្ដឹងរដ្ឋប្បវេណីណាដែលមកពីក្រុមភាគតិច ជាពិសេសស្ត្រី។ ពួកគេទាំងនោះនឹងទទួលបានផលប្រយោជន៍ពីគម្រោងតាមរយៈការចូលរួម និងការចូលរួមដោយសកម្មក្នុងវគ្គនៃការព្យាបាលផ្លូវចិត្ត។

១៣៣. គម្រោងនេះនឹងផ្ដល់ជាភស្តុតាងជាច្រើនដែលទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្ស ដែលទទួលរងក្នុងអំឡុងពេលរបបខ្មែរក្រហម។

១៣៤. វាក៏រួមចំណែកការលើកកំពស់យុត្តិធម៌អន្តរកាល ផងដែរ។

១៣៥. លើសពីនេះ តាមរយៈគម្រោងនេះ នឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកជំនាញ ផ្នែកផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា និងសមត្ថភាពរបស់ពួកគេដើម្បីដោះស្រាយបញ្ហាជាក់លាក់របស់ ជនរងគ្រោះពីរបបខ្មែរក្រហម។

១៣៦. ដូច្នេះ គម្រោងនេះផ្ដល់ផលប្រយោជន៍ជាចម្បងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែក៏ផ្ដល់ផលប្រយោជន៍ដល់សហគមន៍ដែលនៅជុំវិញពួកគេ និងផ្ដល់ផលប្រយោជន៍ យ៉ាងទូលំទូលាយដល់ការអភិវឌ្ឍន៍សុខភាពផ្លូវចិត្តក្នុងប្រទេសកម្ពុជា។

**គ- ការអនុវត្តគម្រោង**

១៣៧. មានយុទ្ធសាស្ត្រគាំទ្រសុខភាពផ្លូវចិត្តដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការអនុវត្តគម្រោងនេះសូម្បីតែនៅក្នុងសហគមន៍ពួកគេដើម្បីជំនួសគ្លីនិកសុខភាពផ្លូវចិត្តឯកជន។

១៣៨. តាមរយៈគម្រោងនេះ នឹងផ្ដល់ការបណ្ដុះបណ្ដាលអ្នកជំនាញផ្នែកផ្លូវចិត្តចំនួន ១២ សហគមន៍ដើម្បីបំពាក់បំប៉នពួកគេឱ្យមានជំនាញដើម្បីជួយគាំទ្រដល់ជនរងគ្រោះពីសម័យខ្មែរក្រហម ជាពិសេសដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ លើស ពីនេះទៅទៀតគម្រោងនេះផ្ដល់ជូនសេវាផ្លូវចិត្តមួយបែបដែលនឹងផ្ដោតទៅលើការផ្ដល់ជូនសុខភាព ផ្លូវចិត្តដល់អ្នកព្យាបាលតាមបែបធ្វើសក្ខីកម្ម និងវិធីសាស្ត្រផ្សេងៗទាក់ទងនឹងសុខភាពផ្លូវចិត្ត ដោយស្របតាមវប្បធម៌របស់គេនៅតាមទីជនបទ។ ម្យ៉ាងវិញទៀត ដើម្បីពង្រីកបន្ថែមនូវសេវាផ្សេងៗ គម្រោងនេះនឹងផ្ដល់ជូនការផ្ដល់សេវាប្រឹក្សាសុខភាពតាមប្រព័ន្ធទូរស័ព្ទ និងសេវាថ្នាំពេទ្យជាបឋមដោយគ្លីនិកសុខភាពផ្លូវចិត្តរបស់អង្គការ ធី.ភី.អូ។

១៣៩. គម្រោងសំណងនេះ ត្រូវបានបង្កើតឡើងសម្រាប់រយៈពេល១៦ខែ ហើយវានឹងអនុវត្តភ្លាមតាមតែអាចធ្វើទៅបាន។

១៤០. ហិរញ្ញប្បទាន គម្រោងនេះត្រូវបានផ្ដល់មួយផ្នែក ដោយរដ្ឋាភិបាលអាល្លឺម៉ង់ ដែលមានក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធ អាល្លឺម៉ង់ (BMZ) បានយល់ព្រមផ្ដល់

ថវិកានូវចំនួនទឹកប្រាក់ ១៦២.៧៥៨ ដុល្លា ដែលថវិកានេះបានផ្តល់ជូនទៅអង្គភាពគាំពារជនរងគ្រោះតាមរយៈផ្នែករដ្ឋបាលនៃ អ.វ.ត.ក[190]។ ថវិកានេះនឹងប្រគល់ជូនបន្តទៅអង្គការ[191] ដែលអនុវត្តគម្រោងនេះ។ ថវិកានេះសម្រាប់គម្រោង *វិធីព្យាបាលតាមរបៀបចងក្រងសក្ខីកម្មផង* និង*ក្រុមជួយខ្លួនឯងផង*។

១៤១. *មូលនិធិ* « *Stiftung Kriegstrauma Therapie* » ផ្តល់ថវិកាចំនួន ២៧.៤៥៤ ដុល្លា សម្រាប់គម្រោងទាំងនេះ។

## ឃ-ភាពអាចធ្វើបាន

១៤២. គម្រោងនេះ កំពុងត្រូវបានចាប់ផ្តើមអនុវត្តក្នុងរយពេល១៦ខែ ចំពោះថវិកាដែលបានមកពី BMZ និងពីអង្គការ« *Stiftung Kriegstrauma Therapie* » ។ ទន្ទឹមនឹងនេះ មេធាវីនាំមុខសូមស្នើសុំឲ្យអង្គជំនុំជម្រះ ទទួលផងដែរនូវឯកសារបញ្ជាក់អំពីហិរញ្ញប្បទានជាយថាហេតុបន្ថែមសម្រាប់ពង្រីកលទ្ធភាពក្នុងការអនុវត្តគម្រោង ក្នុងអំឡុងបេលនៃការពិភាក្សារបស់ចៅក្រម។ មេធាវីនាំមុខស្នើសុំឲ្យអង្គជំនុំជម្រះទទួលថាគម្រោងនេះអាចត្រូវបានពង្រីក និងទទួលស្គាល់ជាសំណងបន្ទាប់ពីពេលដែលកំណត់ដោយអង្គជំនុំជម្រះ នៅពេលដែលទទួលបានថវិកាបន្ថែម។ ការស្នើសុំបែបនេះ គឺធ្វើក្នុងប្រយោជន៍ នៃដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលប្រយោជន៍ ពីសំណងច្រើន ដែលអាចធ្វើទៅបាន។

## <u>គម្រោងទី៦: ក្រុមជួយខ្លួនឯង</u>

### ក- ការពិព័ណ៌នាអំពីគម្រោង

១៤៣. គម្រោងនេះ មានលក្ខណៈដូចគ្នាទៅនឹង គម្រោងនៃការព្យាបាលផ្លូវចិត្តតាមរបៀបចងក្រង សក្ខីកម្ម។ ក្រុមជួយខ្លួនឯងគឺជាវិធីព្យាបាលមួយផ្សេងទៀតដែលអង្គការ ធី.ភី.អូ កំពុងតែបង្កើត ឡើង និងអនុវត្ត។

១៤៤. លិខិតសន្យាអនុវត្តគម្រោងរបស់ ធីភីអូ គឺសម្រាប់កម្រោងនេះ ផងដែរ។

១៤៥. ក្រុមជួយខ្លួនឯងគឺជាការប្រមូលផ្តុំដោយស្ម័គ្រចិត្តនៃអ្នកដែលមានបំណងជម្នះនូវការឈឺចាប់របស់ខ្លួន ស្វែងយល់ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួន តាមរយៈការផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក។

១៤៦. សកម្មភាពនៃគម្រោងក្រុមជួយខ្លួនឯងគឺនឹងអនុវត្តនៅតាមសហគមន៍មូលដ្ឋាន ៣លើក ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដែលបានជ្រើសរើស ជាស្រេច។ ដើមបណ្តឹងរដ្ឋប្បវេណីប្រហែល ១០នាក់ នឹងចូលរួមក្នុងក្រុមជួយខ្លួនឯងក្នុងមួយលើក ដែលពួកគេមកពីស្រុកជិតៗគ្នា។ វគ្គព្យាបាលបែបនេះ នឹងធ្វើមួយខែម្តង សម្រាប់រយៈពេល ទាំងអស់ ៩ខែ ។

## ខ. គោលបំណង និងអ្នកទទួលផលប្រយោជន៍៖

១៤៧. គម្រោងនេះអនុញ្ញាតឲ្យអ្នកចូលរួមបញ្ចេញនូវមនោសញ្ចេតនារបស់ខ្លួន ចែករំលែកនូវអារម្មណ៍របស់ខ្លួន និងគាំទ្រគ្នាទៅវិញទៅមកដោយទាញយកបទពិសោធន៍ពីគ្នាទៅវិញទៅមក។

១៤៨. វាអនុញ្ញាត ឲ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបាននូវការជឿជាក់លើខ្លួនឯកមកវិញ សមត្ថភាពក្នុងការធ្វើការសម្រេចចិត្ត និងកែលំអជីវិតក្នុងសង្គមរបស់ខ្លួននាពេលអនាគត។

១៤៩. គម្រោងនេះ គឺជាមធ្យោបាយក្នុងការបំបែកភាពឯកោ និងមនោសញ្ចេតនាបង្ខាំងខ្លួនឯង តាមរយៈការបង្កើតឲ្យមានទំនាក់ទំនងជាមួយអ្នកដ៏ទៃ។

១៥០. វានឹងនាំឲ្យយល់ពីមូលហេតុដែលនាំឲ្យមានការឈឺចាប់ និងវិប្បត្តិរបស់ជនរងគ្រោះ។

១៥១. ដូចនេះ គម្រោងនេះ មានគោលបំណងផ្តល់លទ្ធភាពឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំនៅក្នុងសំណុំរឿង ០០២ រៀបរាប់អំពីការឈឺចាប់របស់ខ្លួនក្នុង ពេលជួបប្រជុំគ្នា ហើយតាមរយៈការរៀបរាប់នេះ ពួកគាត់បានចាប់ផ្តើមដំណើរការព្យាបាល ការឈឺចាប់ដែលបានទទួលរង។ មធ្យោបាយនេះ នឹងនឹងអនុញ្ញាតឲ្យមានការធូរស្រាល ឬការបញ្ចប់ការឈឺចាប់ ដើម្បីចាប់ផ្តើមជីវិតថ្មី។

១៥២. គម្រោងនេះនឹងផ្តល់ជាប្រយោជន៍ផងដែរដល់សហគមន៍ របស់គាត់។ គ្រួសារ និងសហគមន៍នៃដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលប្រយោជន៍ពីគម្រោងនេះ តាមរយៈការចូលអន្តរាគមន៍ក្នុងវគ្គក្រុមជួយខ្លួនឯង។

## គ-ការអនុវត្តគម្រោង

១៥៣. គម្រោងក្រុមជួយខ្លួនឯងគឺបង្កើតឱ្យមានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅទីជនបទ។

១៥៤. អ្នកអនុវត្តគម្រោងសំណងនេះ គឺអង្គការចិត្តសង្គមអន្តរវប្បធម៌ (ធី.ភី.អូ) ។

១៥៥. រយៈពេលអនុវត្តសម្រាប់គម្រោងសំណងនេះគឺ ១៦ ខែ ។

១៥៦. ហិរញ្ញប្បទាន គម្រោងនេះត្រូវបានផ្តល់មួយផ្នែក ដោយរដ្ឋាភិបាលអាល្លឺម៉ង់ ដែលមានក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធ អាល្លឺម៉ង់ (BMZ) បាន យល់ព្រមផ្តល់ថវិកានូវចំនួនទឹកប្រាក់ ១៦២.៧៥៨ ដុល្លា ដែលថវិកានេះបានផ្តល់ជូនទៅអង្គភាព គាំពារជនរងគ្រោះតាមរយៈផ្នែករដ្ឋបាលនៃ អ.វ.ត.ក[192]។ ថវិកានេះនឹងប្រគល់ជូនបន្តទៅអង្គការ ដែលអនុវត្តគម្រោងនេះ។ ថវិកានេះសម្រាប់គម្រោង *វិធីព្យាបាលតាមរបៀបចងក្រងសក្ខីកម្មផង* និង *ក្រុមជួយខ្លួនឯងផង*។ គម្រោងទាំងនេះទទួលថវិកាផងដែរពី *មូលនិធិ* « *Stiftung Kriegstrauma Therapie* » [193]។

## គ- ភាពអាចធ្វើបាន

១៥៧. គម្រោងនេះ កំពុងត្រូវបានចាប់ផ្តើមអនុវត្តក្នុងរយពេល១៦ខែ ចំពោះថវិកាដែលបានមកពី BMZ និងពីអង្គការ« *Stiftung Kriegstrauma Therapie* » ។ ទន្ទឹមនឹងនេះ មេធាវីនាំមុខសូមស្នើសុំឱ្យអង្គជំនុំជម្រះ ទទួលផងដែរនូវឯកសារបញ្ជាក់អំពីហិរញ្ញប្បទានជាយថាហេតុបន្ថែម សម្រាប់ពង្រីកលទ្ធភាពក្នុងការអនុវត្តគម្រោង ក្នុងអំឡុងពេលនៃការពិភាក្សារបស់ចៅក្រម។ មេធាវីនាំមុខ ស្នើសុំឱ្យអង្គជំនុំជម្រះទទួលថា គម្រោងនេះអាចត្រូវបានពង្រីក និងទទួលស្គាល់ជាសំណង បន្ទាប់ពីពេលដែលកំណត់ដោយអង្គជំនុំជម្រះ នៅពេលដែលទទួលបានថវិកាបន្ថែម។ ការស្នើសុំបែបនេះ គឺធ្វើក្នុងប្រយោជន៍ នៃដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលប្រយោជន៍ ពីសំណងច្រើន ដែលអាចធ្វើទៅបាន។

# ជំពូកទី ៣ ការចងក្រងឯកសារ និងការអប់រំ

១៥៨. គម្រោងសំណងទាក់ទងទៅនឹងការចងក្រងឯកសារ និងការអប់រំ មានគោលដៅរក្សា និងជម្រុញឱ្យមានការយល់ដឹង អំពីប្រវត្តិសាស្ត្រនៅក្នុងសម័យខ្មែរក្រហម និងបទពិសោធន៍នីមួយៗរបស់ ជនរងគ្រោះ។

## <u>គម្រោងទី ៧: ការតាំងពិពរណ៍អចិន្ត្រៃយ៍</u>

១៥៩. គម្រោងសំណងនេះត្រូវបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណី០០២ ដែលនៅក្នុងនោះ មួយចំណែកធំបានរងគ្រោះនៃការជម្លៀសដោយបង្ខំ ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែ

មេសា ឆ្នាំ១៩៧៥ និងថ្ងៃបន្តបន្ទាប់។ ការជម្លៀសនេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងរឿងក្តី ០០២/០១ ។

**ក- ការរាយរាប់ពីគម្រោង៖**

១៦០. គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ គឺជាគម្រោងដែលនឹងអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបំពេញការងារយ៉ាងជិតស្និតជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅក្នុងក្របខណ្ឌនៃការថែរក្សា និងអភិវឌ្ឍន៍សារមន្ទីរ ចំនួន ២៤ ខេត្ត-ក្រុង នៅព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលនៃព្រះរាជាណា ចក្រកម្ពុជា ក្នុងការចូលរួមបង្កើតបណ្តាញថែរក្សា និងលើកតម្កើងវប្បធម៌។ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងចូលរួមក្នុងការរៀបចំឯកសារ និងការតាំងពិព័រណ៍អំពីកម្ពុជាប្រជាធិបតេយ្យ នៅគ្រប់ ខេត្ត-រាជធានី នៃព្រះរាជាណាចក្រកម្ពុជា។ គម្រោងសំណាងស្តីពីតាំងពិព័រណ៍អចិន្ត្រៃយ៍ ជាផ្នែកមួយនៃការអនុវត្តបេសកកម្មនេះ។

១៦១. **សកម្មភាព៖** គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍នឹងត្រូវធ្វើឡើងនៅសារមន្ទីរនៃខេត្តចំនួន៥ ដោយជាបឋមចាប់ផ្តើមពីខេត្តបាត់ដំបង និងបន្ទាយមានជ័យ បន្ទាប់មកនឹងមានការរៀបចំឲ្យមានរបៀបដូចគ្នា នៅខេត្តកំពង់ធំ តាកែវ និងស្វាយរៀង។ ការជ្រើសរើសអនុវត្តគម្រោងនៅក្នុងបណ្តាខេត្តទាំងនេះដោយសារដំណើរការ និងរចនាសម្ព័ន្ធនៃសារៈមន្ទីរដែលមានលក្ខណៈល្អច្រើន មានសម្ភារៈដែល សល់ពីរបបខ្មែរក្រហម ដូចជា ចប ពូថៅ.. ភាពពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំនុំរឿង ០០២/០១ ដោយមានជនរងគ្រោះដោយសារការជម្លៀសត្រូវបានបញ្ជូលទៅទីនោះជាច្រើន និងនៅក្នុងនោះក៏ មានដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ទោះជាខ្លឹមសារនៃការតាំងពិព័រណ៍អាចផ្តោតលើបញ្ហាផ្សេងៗ នៃប្រវត្តិសាស្ត្រខ្មែរក្រហម ប្រធានបទជាដំបូងនឹងផ្តោតជាពិសេសទៅលើការជម្លៀសដោយបង្ខំ ទី១ និងទី២ ព្រមទាំងអង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។ ខ្លឹមសារនឹងត្រូវរៀបចំ ដោយតម្រូវទៅតាមអង្គហេតុដែលជួបប្រទះ ដោយដើមបណ្តឹងរដ្ឋប្បវេណី និងប្រែប្រួលពីពេលមួយទៅ ពេលមួយដើម្បីធានាឲ្យមានភាពខុសប្លែក និងមានការចាប់អារម្មណ៍ពីទស្សនិកជន។

១៦២. គម្រោងនេះ មានគោលដៅអប់រំ ដោយបង្ហាញពីបទពិសោធន៍ដែលមាននៅក្នុងអតីតកាល និងមូលហេតុរបស់វា ជាពិសេសអ្វីដែលមានដោយដើមបណ្តឹងរដ្ឋប្បវេណី និងផ្សព្វផ្សាយដល់មនុស្សជំនាន់ក្រោយសម្រាប់ជាចំណេះដឹង និងចូលរួមការផ្សះផ្សា និងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀតចងក្រង ចែករំលែក និងយល់ដឹង ថែមទៀតអំពីរឿងរ៉ាវខ្មែរក្រហម បង្កើត

ឲ្យមានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រមួយ និងធ្វើឱ្យព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបាន មើលដោយសាធារណជនផ្សេងទៀតផងដែរ។

## ខ- គោលដៅ និងអ្នកទទួលប្រយោជន៍

១៦៣. គម្រោងនេះមានគោលដៅរក្សា និងលើកតម្កើងរឿងរ៉ាវ និងបទពិសោធន៍ដែលមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម ដោយថែរក្សានូវភស្តុតាងគ្រប់ប្រភេទ នៅក្នុងទីតាំងជាក់លាក់សម្រាប់គោលដៅនេះ។ ការថែរក្សាភស្តុតាងក្នុងរយៈពេលវែងនឹងចូលរួមក្នុងការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រនេះ។

១៦៤. គម្រោងនេះគឺជាការឧទ្ទិសដល់ជនរងគ្រោះ និងជាមធ្យោបាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការផ្តល់នូវបទពិសោធន៍ សម្រាប់មនុស្សជំនាន់ក្រោយ និងសាធារណៈជនជាតិ និងអន្តរជាតិ។

១៦៥. គម្រោងនេះមានគោលដៅអប់រំ។ តាមរយៈការផ្តល់ចំណេះដឹងដល់មនុស្សជំនាន់ក្រោយ វានឹងរួមវិភាគទានដល់ការផ្សះផ្សា និងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀតចែករំលែក និងយល់ដឹងស៊ីជម្រៅអំពីខ្មែរក្រហម។

១៦៦. យុវជនជំនាន់ក្រោយ អ្នកដឹកនាំនាពេលខាងមុខ នឹងមានលទ្ធភាពពិចារណាអំពីអតីតកាល ដើម្បីការសាងអនាគតកាលឲ្យកាន់តែប្រសើរ។

១៦៧. សាធារណជនជាទូទៅអាចពិចារណាលើប្រវត្តិសាស្ត្រនៃសម័យនោះ ដើម្បីពិនិត្យពីសារសំខាន់ និងផលវិបាករបស់វា និងចងចាំសម្រាប់ពេលអនាគត។

១៦៨. ដូចដែលបានរាយរ៉ាប់ គឺវានឹងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណៈជនទូទៅ និងជាពិសេស ដល់យុវជនជំនាន់ក្រោយ។

## គ- ការអនុវត្ត

១៦៩. គម្រោងនេះនឹងត្រូវ អនុវត្តក្នុងរយៈពេលចំនួន ១៦ ខែ គឺចាប់ពីខែ កញ្ញា ២០១៣ រហូត ដល់ខែធ្នូ ឆ្នាំ២០១៤ ដែលក្នុងនោះដំណាក់កាលដំបូងពីខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែមេសា ឆ្នាំ២០១៤ ជារយៈពេលរៀបចំសម្ភារៈ និងការតាំងពិព័រណ៍ និងការបើកដំណើរការ ជាក់ស្តែងនៃការតាំងពិព័រណ៍ គឺចាប់ពីខែឧសភា រហូតដល់ខែធ្នូ ឆ្នាំ២០១៤។

១៧០. ក្នុងក្របខ័ណ្ឌនៃគម្រោងនេះ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននឹងបានចូលរួមក្នុងការរៀបចំគម្រោងតាំងពិព័រណ៍ បានចូលរួមផ្តល់រឿងរ៉ាវរបស់ខ្លួនសម្រាប់ការចងក្រង និងចូលរួមចែករំលែកដោយផ្ទាល់ពីអ្វីដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម រួមទាំងដំណើរ ការកាត់ក្តីផងដែរ។

១៧១. ហិរញ្ញប្បទានគម្រោងនេះត្រូវបានផ្ដល់៨០.០០០ (ប្រាំបីម៉ឺន)អឺរ៉ូ ដោយរដ្ឋាភិបាលអាល្លឺម៉ង់, ដែលមានក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ (BMZ) បានយល់ព្រមផ្ដល់ថវិកានូវចំនួនទឹកប្រាក់ ១៦២.៧៥៨ ដុល្លា ហើយថវិកានេះនឹងត្រូវបានផ្ដល់ជូនទៅអង្គភាព គាំពារជនរងគ្រោះតាមរយៈផ្នែករដ្ឋបាលនៃ អ.វ.ត.ក[194]។ ថវិកានេះនឹងប្រគល់ជូនបន្តទៅអង្គការដែលអនុវត្តគម្រោងនេះ ។ ថវិកានេះសម្រាប់អនុវត្តគម្រោង ដែលស្ថិតនៅក្នុងខេត្តចំនួន ៥ ដូចមានបញ្ជាក់ខាងលើ។

១៧២. ការអនុញ្ញាតដែលចាំបាច់នានាត្រូវទទួលបានតាមរយៈ កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងមជ្ឈមណ្ឌលឯកសារកម្ពុជា។

## ឃ- ភាពអាចធ្វើបាន

១៧៣. គម្រោងនេះអាចត្រូវអនុវត្តបានទាំងមូល ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់នៅក្នុងអនុសារណៈថ្ងៃទី ៦ កញ្ញា ២០១៣[195]។ វាអាចត្រូវបានទទួលស្គាល់ជាសំណង។

## គម្រោងទី៨: ការតាំងពិព័រណ៍ចល័ត

## ក- ការពិព័ណ៌នាអំពីគម្រោង

១៧៤. ពិធីតាំងពិពរណ៍នេះ នឹងចងក្រងទុកជា ឯកសារនូវបទ ពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីការជម្លៀសដោយបង្ខំ និងព្យសនកម្ម ផ្សេងទៀតដែល ទទួលរងនៅក្រោមរបបខ្មែរក្រហម ហើយនឹងផ្សព្វផ្សាយរឿងរ៉ាវទាំងនេះឱ្យបានទូលាយដល់សាធារណជន។ ទីតាំងចំនួន ៦ ត្រូវបានជ្រើសរើសសម្រាប់ជាគោលដៅ នៃការអនុវត្តគម្រោងនេះ។

១៧៥. សកម្មភាពគម្រោងនឹងត្រូវបានបែងចែកជាពីរដំណាក់កាល គឺដំណាក់កាល នៃការផលិត និងដំណាក់កាលនៃការអនុវត្តគម្រោង។ ដំណាក់កាលទីមួយគឺ អង្គការក្ដីករុណា ជាអ្នកដែលទទួលខុសត្រូវលើផ្នែកផលិតសម្ភារៈទាក់ទងការតាំងពិព័រណ៍ ដោយមានការចូលរួម សហការជាមួយមន្ត្រីកម្មវិធីគម្រោងម្នាក់ដែលមកពីអង្គការយុវសន្តិភាពក្នុងការជួយ។ រីឯដំណាក់ កាលទីពីរ ការអនុវត្តគម្រោងគឺ អង្គការទាំងពីរដើរតួនាទីជាអ្នកអនុវត្តយ៉ាងពេញលេញ។

១៧៦. សកម្មភាពនៅក្នុងដំណាក់កាលទីមួយ គឺមាន ដូចជា រៀបចំរចនាអំពីគំនិតនៃការតាំងពិពរណ៍ (ប្រធានបទ ផ្នែកទាក់ទង និង សម្ភារៈចាំបាច់) ផលិតឯកសារវីដេអូ ផលិតការតាំងពិព័រណ៍តាម

បន្ទះក្តារ ផលិតសម្ភារៈទាក់ទងទៅនឹងការផ្តល់ ព័ត៌មាន ការអប់រំ និងការទំនាក់ទំនង រៀបចំរចនាកម្មវិធីគម្រោងចំនួន ២ថ្ងៃ សម្រាប់វេទិកា សាធារណៈ សិក្ខាសាលា ការសម្តែងល្ខោន តន្ត្រី បុណ្យទាន និងការបញ្ចាំងកុន និងការផលិត វីដេអូឯកសារស្តីពីការតាំងពិព័រណ៍។ ថវិកាដែល ប្រើប្រាស់សម្រាប់ការផលិតនៅក្នុងដំណាក់កាល ទីមួយគឺចំនួន ៤០% នៃចំនួនថវិកាសរុប។

១៧៧. សកម្មភាពក្នុងដំណាក់កាលទីពីរ គឺអង្គការទាំងពីរ គឺជាអ្នករៀបចំបង្កើតក្រុមការងារដោយឡែករៀង១ខ្លួនក្នុងការអនុវត្តគម្រោង ហើយបានបែងចែកការអនុវត្តនៅតាមតំបន់គោលដៅក្នុងម្នាក់ ៣ កន្លែងផ្សេងគ្នា។ អង្គការទាំងពីរនឹងអនុវត្តគម្រោងដោយ ប្រើប្រាស់ថវិកាពាក់កណ្តាលម្នាក់ដែលសល់ពីការប្រើប្រាស់ក្នុងដំណាក់កាលទីមួយ គឺ ៣០% ស្មើគ្នា។

១៧៨. ដើមបណ្តឹងរដ្ឋប្បវេណី នឹងទទួលបាននូវឯកសារ ដែលគាត់បានចូលរួមក្នុងការនិយាយសាច់រឿង និងការយល់ឃើញរបស់គាត់ ព្រមទាំងអាចចូលរួមក្នុងការងាររៀបចំកម្មវិធី និងសកម្មភាពអប់រំនានា[196]។

១៧៩. អង្គការយុវសន្តិភាព (YfP) និងអង្គការក្តីករុណា (KdK) គឺជាអង្គការពីរ ដែលក្នុងរយៈពេល ១០ ឆ្នាំកន្លងមក បានបង្កើត និងអនុវត្តគម្រោងជាច្រើន ដែលផ្តល់ថវិកាដោយ ម្ចាស់ជំនួយអន្តរជាតិ និងមានគោលដៅស្វែងរកការពិត និងការចងចាំជាសមូហភាព។ អង្គការទាំងពីនេះ ត្រូវបានទទួលស្គាល់ថាមានស្នារដៃ ការងារដែលសម្រេចបានជាមួយ សហគមន៍មូលដ្ឋាន ការប្រឹងប្រែងបំពេញការងារពាក់ព័ន្ធនឹងការដោះស្រាយយុត្តិធម៌អន្តរកាល និងជាមួយយុវជនជំនាន់ក្រោយ[197]។

១៨០. អង្គការទាំងពីនេះ សន្យាថានឹងអនុវត្តគម្រោងនេះ។ [198] ពួកគេមានជំនាញ និងធនធានគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងនេះ។

## ខ- គោលដៅ និងអ្នកទទួលប្រយោជន៍

១៨១. គម្រោងនេះបង្កើតឡើងក្នុងគោលបំណងទីមួយ ដើម្បីជម្រុញការទទួលស្គាល់ជា សាធារណៈនៃការរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងរបបខ្មែរក្រហម ពិសេសទាក់ទង ទៅនឹងការជម្លៀសដោយបង្ខំទីពីរ ដើម្បីជូនដំណឹងដល់សាធារណៈជនអំពីអតីតកាល នៃពួកខ្មែរ ក្រហម ពិសេសទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ ទីបី ដើម្បីពង្រឹងការចូលរួមរបស់ប្រជាជន កម្ពុជាក្នុងការឆ្លុះបញ្ចាំងពីអតីតកាលរបស់ពួកខ្មែរក្រហម និងមូលហេតុរបស់វា ដើម្បីកុំឲ្យអំពើរបែបនេះកើតជាថ្មី។

១៨២. គម្រោងនេះ ក៏មានគោលដៅផងដែរក្នុងការលើងតម្កើវប្បធម៌សន្តិភាព និងការផ្សះផ្សារជាតិក្នុងប្រទេស តាមរយៈការផ្ដល់សំណងផ្លូវចិត្ត និងសមូហភាព។

១៨៣. ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ដែលជាអ្នកទទួលផល ប្រយោជន៍ដំបូង។ ជាពិសេស គម្រោងនេះ នឹងដាក់បញ្ចូលដើមបណ្ដឹងរដ្ឋប្បវេណីណាដែលមិន ពាក់ព័ន្ធទៅនឹងសកម្មភាពផ្សព្វផ្សាយនៅឡើយ ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីជាស្ត្រី និងក្រុម ជនជាតិភាគតិច។ ដើមបណ្ដឹងរដ្ឋប្បវេណី នឹងទទួលបានការឧបត្ថម្ភផ្នែកភស្តុភារ ក្នុងអំឡុងពេល ការចូលរួមការតាំងពិព័រណ៍នេះ ហើយអាចចូលរួមក្នុងការរចនាការតាំងពិព័រណ៍ និងសកម្មភាព អប់រំផ្សេងៗ។ អ្នកដែលទទួលបានផលប្រយោជន៍បន្ទាប់គឺសាធារណជន។ ពួកគាត់អាចទទួល បានប្រយោជន៍ពីការតាំងពិព័រណ៍នេះ តាមរយៈការចូលរួមការតាំងពិព័រណ៍ ការចូលរួមគ្រប់ សកម្មភាពដែលនៅជុំវិញការតាំងពិព័រណ៍ ហើយនឹងព័ត៌មានផ្សេងៗ។

## គ- ការអនុវត្តគម្រោង

១៨៤. ដៃគូចម្បងក្នុងការអនុវត្តគម្រោងសំណងនេះ គឺអង្គការយុវសន្តិភាព (YfP) និងអង្គការក្ដីករុណា (KdK)។ ពួកគេមានបទពិសោធន៍ សមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការ អនុវត្តន៍គម្រោងបែបនេះ។ ពួកគេនឹងទទួលខុសត្រូវចំពោះបច្ចេកទេស ការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តគម្រោងខ្លួនឯង ប៉ុន្តែទាក់ទងទៅនឹងការឃ្លាំមើល និងវាយតម្លៃលើការអនុវត្តគម្រោង គឺជាតួនាទីរបស់អង្គភាពគាំពារជនរងគ្រោះដែលត្រូវបានផ្ដល់អាណត្តិដោយ អ.វ.ត.ក។ ម្យ៉ាងវិញទៀត អង្គការទាំងពីរ ក៏ធ្វើការសហការជាមួយដៃគូផ្សេងទៀតដូចជា សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ (VSS) អង្គការ TPO អង្គការ CDP អង្គការ ADHOC និងអង្គការ CHRAC។

១៨៥. ចំពោះថវិកា រដ្ឋាភិបាលអាល្លឺម៉ង់ដែលមាន ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់ សហប្រតិបត្តិការសេដ្ឋកិច្ច (BMZ) បានផ្ដល់ថវិកាដើម្បីគាំទ្រគម្រោងសំណងនេះ នូវចំនួនទឹកប្រាក់ ១00.000 អឺរ៉ូ[199] ដែលថវិកានេះបានផ្ដល់ជូនទៅអង្គភាពគាំពារជនរងគ្រោះតាមរយៈផ្នែករដ្ឋបាលនៃ អ.វ.ត.ក[200]។ ថវិកានេះ នឹងផ្ដល់ជូនបន្តទៅអង្គការដែលអនុវត្ត គម្រោងសំណងនេះទៅតាមការព្រមព្រៀង ។

១៨៦. គម្រោងនេះមានរយៈពេលកំណត់ពីដំបូង ទាំងអស់ចំនួន ២៤ខែ ប៉ុន្តែដោយយោងទៅលើ ថវិកាដែលបានផ្តល់ឱ្យដោយ BMZ គឺអាចអនុវត្តគម្រោងបានតែក្នុងរយៈពេលត្រឹមតែ ១៦ខែ ប៉ុណ្ណោះ។ គម្រោងនេះអាចអនុវត្តបានចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ដល់ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤។

**ឃ- ភាពអាចធ្វើបាន**

១៨៧. រហូតដល់ពេលនេះ គម្រោងអាចត្រូវអនុវត្តបានក្នុងរយៈពេល ១២ ខែ សម្រាប់ថវិកាដែលត្រូវបានធានា និងគម្រោងបច្ចុប្បន្នភាពដែលបានលើកឡើង[201]។ គម្រោងដើមគឺសម្រាប់រយៈពេល ២៤ ខែ។ ក្នុងករណីដែលទទួលបានថវិកាបន្ថែម គម្រោងអាច ត្រូវបានពង្រីកសកម្មភាព ដូចបានលើកក្នុងគម្រោងដើម។

១៨៨. មេធាវីនាំមុខ ស្នើសុំឱ្យអង្គជំនុំជម្រះទទួល ថាគម្រោងនេះអាចត្រូវបានពង្រីក និងទទួលស្គាល់ជាសំណង បន្ទាប់ពីពេលដែលកំណត់ដោយអង្គជំនុំជម្រះ នៅពេលដែលទទួលបានថវិកាបន្ថែម ដោយឱ្យគម្រោងនេះអាចត្រូវអានុវត្តបានលើសពីរយៈពេល ១៦ ខែ។ ការស្នើសុំបែបនេះ គឺធ្វើក្នុងប្រយោជន៍ នៃដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលប្រយោជន៍ ពីសំណងច្រើន ដែលអាចធ្វើទៅបាន។

<u>**គម្រោងទី៩: ការតាក់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ**</u>

**ក- ការពិពណ៌នាអំពីគម្រោង៖**

១៨៩. ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឱ្យទទួលស្គាល់ជាសំណងនូវជំពូកមួយជាក់លាក់ដែលនឹងត្រូវបញ្ចូលទៅក្នុងសៀវភៅបណ្តុះបណ្តាលគ្រូទទួលបន្ទុកបង្រៀនមុខវិជ្ជា ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រខ្មែរក្រហម ដែលអាស្រ័យទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនាពេលអនាគត។

១៩០. ជំពូកនេះនឹងត្រូវរៀបចំ និងចែកចាយដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ព និងចែកចាយ ព្រមទាំងដាក់ឱ្យអនុវត្ត សៀវភៅសម្រាប់គ្រូបណ្តុះបណ្តាល។ ជំពូកនេះនឹងត្រូបញ្ចូលទៅក្នុងសៀវភៅនេះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងដោយស្របទៅតាមសេចក្តីសម្រេចនេះ។ ជំពូកនេះ នឹងមានចំណងជើងថា *ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គហេតុវិនិច្ឆ័យក្នុងករណី ០០២/០១* និងចែកជា ០៤មេរៀន និងមាន ១៦ ទំព័រ។ មេរៀនទី១ និយាយអំពីគោលនយោបាយ គោលបំណង ព្រមទាំងដំណាក់កាល ផ្សេងៗ

នៃការជម្លៀស។ មេរៀនទី២ លើកឡើងពីការរាយរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី អំពីអ្វី ដែលគាត់បានជួបប្រទះក្នុងអំឡុងពេលជម្លៀស។ មេរៀនទី៣ លើកឡើងអំពីផលវិបាកនៃការជម្លៀសដោយបង្ខំទៅលើជនរងគ្រោះ។ ចំណែកឯមេរៀនទី៤ លើកឡើងជាពិសេសអំពីទួលពោធិ៍ជ្រៃ ដោយផ្តោតជាពិសេស លើស្ថានភាព និងការសម្លាប់រង្គាលនៅទីនោះ ព្រមទាំងបទ ពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១៩១. បន្ទាប់ពីបានបោះពុម្ពសៀវភៅនេះរួច មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងផ្តោតជាពិសេស អំពីជំពូកថ្មីនេះ ។

១៩២. មជ្ឈមណ្ឌលឯកសារកម្ពុជាបានសន្យានឹងទទួលបន្ទុកអនុវត្តគម្រោងនេះ។[202] ក្នុងការលើកឡើងពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានបង្ហាញចំពោះមុខអង្គជំនុំជម្រះ ជំពូកថ្មីនេះមិនត្រឹមតែលើកអំពីនីតិវិធី ដែលបានអនុវត្តក្នុងករណី ០០២/០១ ប៉ុណ្ណោះទេ វាថែមទាំងរួមបញ្ចូលសក្ខីកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

## ខ- គោលដៅ និងអ្នកទទួលផលប្រយោជន៍

១៩៣. គោលដៅនៃគម្រោងនេះ គឺសម្រួលដល់ការទទួលស្គាល់ជាផ្លូវការ ជាថ្នាក់ជាតិ និងអចិន្ត្រៃយ៍ នៃប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ វាជួយលើកតម្កើងការអប់រំសម្រាប់ទាំងអស់គ្នា អំពីរឿងហេតុនៃប្រវត្តិសាស្ត្រ។

១៩៤. ដោយមានគោលដៅអប់រំយុវជនជំនាន់ក្រោយ វានឹងជួយចៀសវាងមិនឱ្យឧក្រិដ្ឋកម្មកើតមានសាជាថ្មី។ កម្មវត្ថុនៃគម្រោងនេះ គឺបណ្តុះដល់មនុស្សជំនាន់ក្រោយនូវយុវជនកម្ពុជាជំនាន់ក្រោយ ឱ្យមានគំនិតពលរដ្ឋនិយម ប្រព្រឹត្តដោយចេះទទួលខុសត្រូវ និងដោយថ្លៃថ្នូរ។

១៩៥. ជាទីបញ្ចប់ គម្រោងនេះ នឹងគឺជាមធ្យោបាយ ក្នុងរក្សាកំណត់ត្រា នៅក្នុងប្រព័ន្ធអប់រំ អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម។

១៩៦. គម្រោងនេះ នឹងផ្តល់ប្រយោជទាំងអស់គ្នា ទាំងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ដោយសារវាជាការទទួលស្គាល់អ្វីដែលពួកគាត់បានឆ្លងកាត់ផ្ទាល់ និងវាជាការចងចាំពីពួកគាត់ ដោយសមូហភាព។ វានឹងផ្តល់ផលប្រយោជន៍ផងដែរដល់ប្រជាជនកម្ពុជា និងជាពិសេស ដល់មនុស្សជំនាន់ក្រោយ។ ជាទីបញ្ចប់ វានឹងជួយព្រង្រីកចំណេះដឹងរបស់គ្រូបណ្តុះបណ្តាល។

## គ- ការអនុវត្ត

១៩៧. គម្រោងនេះ នឹងត្រូវអនុវត្តបន្ទាប់ ពីមានសេចក្ដីសម្រេច លើអង្គហេតុនៃករណី ០០២/០១ បន្ទាប់មកវានឹងបំពេញ ការអប់រំអំពីប្រវត្តិសាស្ត្រ។ នៅក្នុងលិខិតសន្យារបស់ខ្លួន មជ្ឈមណ្ឌលឯកសាររបស់កម្ពុជាបានបញ្ជាក់ថា នឹងធានាពីថវិកានៃគម្រោងនេះ[203]។ បច្ចុប្បន្ននេះ ថវិកាចំនួន ៤០.០០០ ដុល្លា ត្រូវបានបម្រុងដោយវិទ្យាស្ថានស្លឹករិត ដែលក្លាយខ្លួនពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[204] សម្រាប់គម្រោងនេះ។

## ឃ- ភាពអាចធ្វើបាន

១៩៨. ដើម្បីឆ្លើយតបទៅនឹងអនុសារណៈរបស់អង្គជំនុំជម្រះថ្ងៃទី ០៦ កញ្ញា ២០១៣[205] ដែលបានបញ្ជាក់ថា សាលាដំបូងមិនអាចទទួលស្គាល់ជាផ្លូវការលើគម្រោងនេះទេ ដោយសារវាពាក់ព័ន្ធនឹងអង្គហេតុដែលមិនទាន់ត្រូវបានវិនិច្ឆ័យ។ មេធាវីនាំមុខ សូមបញ្ជាក់ថានឹងអនុវត្តតាមការណែនាំ សម្រាប់ស្ថានភាពជាក់ស្តែងនេះ មុនមានការវិនិច្ឆ័យនេះ។ ហេតុដូចនេះ គម្រោងនេះនឹងមិនត្រូវអនុវត្តមុនមានសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះ។ មេធាវីនាំមុខសូមគូស បញ្ជាក់ថា នៅពេលវិនិច្ឆ័យ និងក្នុងករណីដែលពិរុទ្ធភាពត្រូវបានរកឃើញ និងមានសាលក្រមផ្តន្ទាទោស អង្គជំនុំជម្រះនឹងអាចមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ទទួលស្គាល់គម្រោងនេះ ថាជាសំណង។ ដូច្នោះ មេធាវីនាំមុខសូមស្នើឲ្យអង្គជំនុំជម្រះទទួលស្គាល់ថាជាសំណងនៅពេលដែលសមស្រប។

## គម្រោងទី១០៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព

១៩៩. ដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើសុំឲ្យមានការទទួលស្គាល់ផងដែរនូវគម្រោងមជ្ឈមណ្ឌលសិក្សាសន្តិភាព ថាជាគម្រោងសំណងសម្រាប់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី។

## ក- ការពិពណ៌នាអំពីគម្រោង៖

២០០. គម្រោងនេះ នឹងត្រូវអនុវត្តនៅសម្រោងក្នុងខេត្តបាត់ដំបង។ គម្រោង នេះ មានគោលដៅ បង្កើតជាទីកន្លែងមួយសម្រាប់ តាមរយៈការចងក្រង ផ្សព្វផ្សាយ បណ្តុះ បណ្តាល ការពិភាក្សា និងអប់រំការឧទ្ទិស ការរំឭក។

២០១. ចំពោះការសាងសង់ទីតាំងដែលជាកម្មវត្ថុនៃការអនុវត្តគម្រោងនេះគឺជាអតីតកន្លែងសម្លាប់មនុស្សរួមមួយនៅជំនាន់កម្ពុជាប្រជាធិប្បតេយ្យ បច្ចុប្បន្នវាជាដីរបស់សហគមន៍។ គួរឲ្យកត់សំគាល់ថា

មុននឹងមានការអនុវត្តន៍គម្រោងនេះ មានការចាប់ផ្តើមអនុវត្តគម្រោងបែបនេះ តាំងពីឆ្នាំ ២០១២ នៅក្រាំងតាចាន់។ ដោយមានការឯកភាពពីសហគមន៍[206](លិខិតអនុញ្ញាតឲ្យអនុវត្តគម្រោង និង អនុញ្ញាតឲ្យសាងសង់លើទីតាំង) យើងអាចអនុវត្តគម្រោង និងការសាងសង់ នានានៅទីតាំងនេះ ដោយនៅក្នុងនោះមាន បន្ទប់ព័ត៌មាន បន្ទប់ពិភាក្សា និងបន្ទប់តាំងពិពត៌។

២០២. សកម្មភាពផ្សេងទៀតរបស់គម្រោង គឺការបណ្តុះបណ្តាលសមត្ថភាព និងអភិបាលកិច្ចល្អ(សន្និសីទ ចំនួន ៤ សម្រាប់សិក្ខកាមចំនួន៨០ រូប), វេទិការសាធារណៈមួយលើកសម្រាប់មនុស្ស ១០០ នាក់, បណ្តុំការងារហត្ថកម្ម, បង្កើត និងកែលម្អប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ, ការបោះជំរុំរបស់យុវជន, ការចងក្រងឯកសារអំពីទីកន្លែងសម្លាន់មនុស្ស ។ល។

២០៣. ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងការផ្តល់នូវអង្គហេតុដែលខ្លួនបានជួប ប្រទះពាក់ព័ន្ធនឹងការជម្លៀសក៏ដូចជាការធ្វើទុក្ខបុកម្នេញលើជនរងគ្រោះជាពិសេសពាក់ព័ន្ធនឹងខេត្ត បាត់ដំបង ខេត្តពោធិ៍សាត់ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យក្នុងក្រប ខ័ណ្ឌនៃការចងក្រងឯកសារ និងចូលរួមពន្យល់បង្ហាញជាក់ស្តែងអំពីអង្គហេតុដែលបានកើតឡើង និងដំណើរការនៃសាលាក្តីខ្មែរ ក្រហមផងដែរ[207]។

២០៤. គម្រោងនេះ នឹងអនុវត្តដោយអង្គការយុវសន្តិភាព ដែលជាអង្គការមួយដែលបានអនុវត្តគម្រោងបែប នេះជាមុន លើទីតាំងមួយចំនួន នៅព្រះរាជាណាចក្រកម្ពុជា និងក៏បានឯកភាពក្នុងការអនុវត្តន៍ គម្រោងជាក់លាក់នេះ តាមរយៈលិខិតរបស់ខ្លួនចុះថ្ងៃទី២២ខែសីហា ឆ្នាំ២០១៣[208] ។

## ខ- គោលដៅ និងអ្នកទទួលប្រយោជន៍

២០៥. គម្រោងនេះនឹងត្រូវអនុវត្តក្នុងគោលដៅអភិវឌ្ឍការពិចារណា និងបែបបទសម្រាប់ថែរក្សាដំណើរ ការនៃសន្តិភាព និងអភិបាលកិច្ចល្អ។ វាសំដៅជាដំបូងទៅលើយុវជនជំនាន់ក្រោយ និងអនុញ្ញាតឲ្យ មានការឆ្លើយឆ្លងរវាងជនរងគ្រោះ និងយុវជន។ សក្ខីកម្មនៃជនរងគ្រោះ នឹងជួយក្នុងការពិចារណា របស់យុវជន។ វាជួយឲ្យទប់ស្កាត់ការកើតមានសាជាថ្មីនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើ ហិង្សាធ្ងន់ធ្ងរ។

២០៦. គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីជាដំបូង ដោយវាពាក់ព័ន្ធនឹងអង្គ ហេតុរបស់ពួកគាត់ និងព្យសនកម្មដែលចេញពីអង្គហេតុទាំងនេះ។ លើសពីនេះ ក៏វាជួយអោយ ដើមបណ្តឹងរដ្ឋប្បវេណីគិតថាអ្វីៗត្រូវធ្វើដើម្បីកុំឲ្យមានអំពើបែបនេះកើតឡើង។ គម្រោងនេះនឹង ផ្តល់ប្រយោជន៍ផងដែរដល់ប្រជាជនខ្មែរ និងជាពិសេស មនុស្សជំនាន់ក្រោយ។

## គ- ការអនុវត្ត

២០៧. ការអនុវត្តន៍គម្រោងនេះ មានរយៈពេលពីរឆ្នាំ គឺចាប់ផ្តើមពី ខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែសីហា ឆ្នាំ២០១៥។

២០៨. គម្រោងនេះបានទទួលការឧបត្ថមពីអង្គការស្វីសសម្រាប់ការអភិវឌ្ឍន៍ ចំនួន ១១៩.៤៥៥,៦០ ដុល្លាអាមេរិក(សូមមើលលិខិត បញ្ជាក់ការផ្តល់ហិរញ្ញវត្ថុសម្រាប់ការអនុវត្តគម្រោងនេះ)។[209]

## ឃ- ភាពអាចធ្វើបាន

២០៩. សេចក្តីអនុញ្ញាតចាំបាច់ត្រូវបានទទួលគ្រប់គ្រាន់រួចហើយ[210]។

២១០. ថវិកាមានពេញលេញនាពេលនេះ និងគម្រោងនេះអាចត្រូវបានអនុវត្តបានគ្រប់ពេល។

២១១. វាមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការទទួលស្គាល់ដោយអង្គជំនុំជម្រះ។

## គម្រោងទី ១១៖ គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង០០២/០១

## ក- ការពិពណ៌នាពីគម្រោង

២១២. គម្រោងនេះសំដៅបោះពុម្ពកូនសៀវភៅដោយមានប្រើប្រាស់ពាក្យពេចន៍សាមញ្ញ និងងាយយល់ ព្រមទាំងមានគំនូរ និងរូបភាពជាច្រើន ដែលអាចឲ្យយល់បានដោយងាយអំពីដំណើរការនៃរឿងក្តីនៅចំពោះមុខ អវតក។

២១៣. គម្រោងនេះគឺសំដៅចំពោះប្រជាជនខ្មែរ ទោះជាមានកំរិតសិក្សាយ៉ាងណាក៏ដោយ[211]។

២១៤. វានឹងត្រូវអនុវត្តដោយអង្គការគណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សកម្ពុជា (CHRACH) ដែលសន្យាថានឹងអនុវត្ត កម្រោងនេះ[212]។ អង្គានេះគឺជាបណ្តុំនៃសមាគមន៍ចំនួន ២១ ដែលទទួលមូលនិធិពីម្ចាស់ជំនួយអន្តរជាតិ និងមានតួនាទីអភិវឌ្ឍន៍សិទ្ធិមនុស្ស លទ្ធិប្រជាធិប្បតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ដែលមានអត្ថិភាពតាំងពីឆ្នាំ ១៩៩៤។ អង្គការនេះមានសមត្ថភាពក្នុងការអនុវត្តគម្រោងនេះជាក់លាក់[213]។

## ខ- គោលដៅ និងអ្នកទទួលផលប្រយោជន៍

២១៥. សៀវភៅនេះមានគោលដៅអនុញ្ញាតឲ្យបុគ្គលម្នាក់ៗស្គាល់ពីព្រឹត្តិការណ៍នៃរបបកម្ពុជាប្រជាធិប្បតេយ្យដោយទទួលបាននូវសៀវភៅដែលសរសេរដោយសាមញ្ញ និងច្បាស់លាស់នេះ។ ស្គាល់និងយល់ប្រវត្តិសាស្ត្រគឺជាមូលដ្ឋានអប្បរមាដើម្បីពិចារណា និងប្រកាន់ឥរិយាបទប្រកបដោយការទទួលខុសត្រូវ។

២១៦. កូនសៀវភៅនេះក៏ជាការឧទ្ទិសផងដែរដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងនីតិវិធីតុលាការក្នុងនាមឲ្យជនរងគ្រោះទាំងឡាយ។

២១៧. វាជាការទទួលស្គាល់អង្គហេតុ និងព្យសនកម្មទទួលរង និងចូលរួមក្នុងការស្វែងរកការពិត។

២១៨. ដូច្នោះ គម្រោងនេះផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីផង និងប្រជាជនកម្ពុជានានាផង។

## គ- ការអនុវត្ត

២១៩. គម្រោងនេះ អាចត្រូវបានសម្រេចក្នុងអំឡុងពេល ១០ ខែ។

២២០. ថវិកាទទួលបានពីអង្គការសហប្រតិបត្តិការអាឡឺម៉ង់ (GIZ) ចំនួន ៥.000 ដុល្លាអាមេរិក ដែលគ្របដណ្តប់លើគម្រោងទាំងមូល។[214]

## ឃ- ភាពអាចធ្វើបាន

២២១. គម្រោងនេះអាចត្រូវបានអនុវត្តនាពេលនេះ និងវាឆ្លើយតបទៅនឹងលក្ខខ័ណ្ឌដែលតម្រូវដោយច្បាប់ និងអង្គជំនុំជម្រះ។

២២២. មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានបំណងផងដែរ ក្នុងការស្នើសុំពីតុលាការក្នុងការផ្តល់ជាលក្ខណៈសំណងផងដែរនូវការបោះពុម្ពសាលក្រមជាសាធារណៈ និងការចុះឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក។ គម្រោងទាំងនេះ ត្រូវបានទទួលស្គាល់ រួចហើយជាសំណង តាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណី 00១។ វាជាការតព្វកិច្ចរបស់ អវតក ផងដែរ និងវាមិនត្រូវការថវិកាពីខាងក្រៅឡើយ។

## <u>គម្រោងទី ១២៖ គម្រោង បោះពុម្ពនិងផ្សព្វផ្សាយសាលក្រម ទាំងមូល និងជាសង្ខេប</u>

២២៣. មេធាវីដើមបណ្តឹងសូមស្នើឲ្យមានការបោះពុម្ពសាលក្រមពេញលេញ និងសាលក្រមសង្ខេបនៃករណី ០០២/០១ ដោយ ផ្នែកសាធារណៈនៃ អ.វ.ត.ក[215]។ សាលក្រមដែលបោះពុម្ពហើយ នឹងត្រូវ ចែកចាយដល់ដើមបណ្តឹងរដ្ឋប្បវេណី សាធារណៈជន និងអ្នកវិជ្ជជីវៈច្បាប់។

២២៤. តាមរយៈការផ្សព្វផ្សាយ និងយល់ដឹងអំពី រឿងក្តីនេះ វានឹងជួយចូលរួមក្នុងដំណើរការផ្សះផ្សារជាតិ និងការទប់ស្កាត់មិនឲ្យមានឧក្រិដ្ឋកម្មសាហាវព្រៃផ្សៃកើតមាននាពេលខាងមុខ។

២២៥. តាមការបញ្ជាក់ពីការិយាល័យរដ្ឋបាល/ផ្នែកសាធារណៈនៃអវតក ថវិកាចំនួន ២.៥០០ ដុល្លា ត្រូវបានស្នើសម្រាប់ជាផ្នែកមួយនៃការអនុវត្តការបោះពុម្ពនេះ[216]។ ទោះជាយ៉ាងណាក៏ដោយ វាជាក់ច្បាស់ណាស់ថាទឹកប្រាក់នេះនឹងមិនគ្របដណ្តប់លើគម្រោងទាំងមូលឡើយ (ការចែកផ្សាយជូនដើមបណ្តឹងរដ្ឋប្បវេណីនូវសាលសក្រម និងសាលក្រមសង្ខេប)។ ពីមុន នៅក្នុងករណី០០១ ទឹកប្រាក់ច្រើនលើសលប់ពីនេះត្រូវបានត្រៀមសម្រាប់ការបោះពុម្ពសៀវភៅពីរបែបនេះ។[217]

២២៦. បន្ទាប់ពីមានការទទួលស្គាល់ពីអង្គជំនុំជម្រះ កិច្ចការទាំងនេះ អាចនឹងត្រូវធ្វើក្នុងរយៈពេល ៤ ខែ។

**<u>គម្រោងទី ១៣៖ គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អវតក</u>**

២២៧. វានឹងផ្តល់សារៈសំខាន់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយការផ្សាយនូវឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងគេហទំព័ររបស់ អវតក។ ការផ្សាយបែបនេះត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី នឹងរួមចំណែកក្នុងការលើកតំលៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

២២៨. ការផ្សាយនេះមានរួមបញ្ចូលនូវឈ្មោះ ជាភាសារខ្មែរ អក្សរឡាតាំង លេខដើមបណ្តឹងរដ្ឋប្បវេណីចេញដោយអង្គភាព គាំពារជនរងគ្រោះ និងធាតុចាំបាច់ក្នុងការស្វែងរកឈ្មោះ។ អង្គភាពគាំពារជនរងគ្រោះ និងផ្នែកសាធារណៈ នឹសហការគ្នាក្នុងការបំពេញការងារទាំងនេះ។

២២៩. ហើយបន្ទាប់ពីមាន សាលក្រមរបស់សាលាដំបូងវគ្គ គម្រោងនេះអាចត្រូវបានអនុវត្តក្នុងរយៈពេល០៣ ខែ។

## ខ. តាមរយៈលក្ខណៈសមូហភាព និងផ្លូវចិត្ត និងការផ្តល់ជំសមូហភាព សំណងឆ្លើយតបទៅនឹងព្យសនកម្មដែលទទួលរង

### ១. ការទទួលស្គាល់ជាផ្លូវការនៃការឈឺចាប់ និងការខូចខាតដែលបានទទួលរង គឺជាកត្តាបឋមចាំបាច់បំផុត

២៣០. ជាការពិតណាស់ ចំណុចបឋមនៃសំណង គឺការទទួលស្គាល់ដោយតុលាការនូវការឈឺចាប់របស់ជនរងគ្រោះ ដែលនៅទីនេះ ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។ អ្នកនិពន្ធ និងអ្នកស្រាវជ្រាវជាច្រើន

បានគូសបញ្ជាក់ពីសារៈសំខាន់នៃការទទួលស្គាល់នេះ ដែលត្រូវសម្តែងចេញមកនៅក្នុងខ្លឹមសារនៃសេចក្តីសម្រេច និងបញ្ជាក់ជូនជនរងគ្រោះពីមូលដ្ឋានត្រូវនៃពាក្យបណ្តឹងរបស់ពួកគេ ឬជូនចំពោះដើមបណ្តឹងរដ្ឋប្បវេណី អំពីមូលដ្ឋានត្រូវនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។ ការទទួលស្គាល់នេះត្រូវបានចាត់ទុកថាជាទម្រង់មួយនៃសំណងដោយតុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង និងបញ្ជាក់នៅក្នុងករណី០០១[218]។ ដំណើរការរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺពិតជាមានការលំបាកសម្រាប់ពួកគាត់ណាស់ ពីព្រោះ ពួកគាត់ត្រូវបានបង្ខំឲ្យរំឭកឡើងវិញពីអនុស្សាវរីយ៍ឈឺចាប់ និងឆ្លើយទៅនឹងសំណួរ ដែលពេលខ្លះ ភាពជឿជាក់បានរបស់ពួកគាត់អាចត្រូវបានចោទជាបញ្ហា។ ម្យ៉ាងវិញទៀត ដំណើរការនេះក៏មានភ្ជាប់នូវករណីយកិច្ចក្នុងការធ្វើជាតំណាងចំពោះជនរងគ្រោះផ្សេងទៀតផងដែរ ដែលពួកគាត់ត្រូវធ្វើសកម្មភាព និងបញ្ចេញមតិ តំណាងឲ្យជនរងគ្រោះដទៃទៀត។ ការដែលអង្គជំនុំជម្រះលើកឡើងពីការឈឺចាប់ និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ពួកគាត់រៀបរាប់អំពីអង្គហេតុ និងព្យសនកម្មនានា ទទួលស្គាល់អំពីអត្ថិភាព និងគូសបញ្ជាក់ពីទំហំនៃព្យសនកម្មទាំងអស់នោះថាជាផលវិបាកនៃឧក្រិដ្ឋកម្មដែលត្រូវជំនុំជម្រះ អាចចាត់ទុកជាប្រភេទមួយនៃសំណង។ វាជាការសំខាន់ណាស់ដែលដើមបណ្តឹងរដ្ឋប្បវេណីអាចរកឃើញនៅក្នុងសេចក្តីសម្រេច នូវទំនាក់ទំនងចាំបាច់រវាងឧក្រិដ្ឋកម្ម និងអ្វីដែលបានបញ្ជាក់អំពីដំណើរការរបស់វា ដូចជាព្យសនកម្មជាដើម។

## ២. ការឆ្លើយតបទៅនឹងព្យសនកម្មជាលក្ខណៈបុគ្គល

២៣១. ក្រៅពីសេចក្តីសម្រេចនេះ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ មានសិទ្ធិទទួលបានសំណងជាលក្ខណៈបុគ្គល បើទោះបីជាសំណងត្រូវតែជាសំណងសមូហភាព និងផ្លូវចិត្តក៏ដោយ។ ត្រង់ចំណុចនេះ បញ្ហាមិនមែនផ្តោតសំខាន់ក្នុងការផ្តល់ដល់ម្នាក់ៗនូវសំណងជាលក្ខណៈបុគ្គល និងថវិកា នោះទេ ប៉ុន្តែ គឺជាការផ្តល់ដល់ពួកគាត់នូវអារម្មណ៍មួយថា សំណងដែលត្រូវបានផ្តល់ជូន បានឆ្លើយតបជាលក្ខណៈបុគ្គល ដែលសំដៅដល់ព្យសនកម្មផ្ទាល់ខ្លួន។ រាល់ព្យសនកម្មទាំងអស់ គឺមានលក្ខណៈជាបុគ្គលដំបូងគេ ទោះបីជាមានភាពស្រដៀងគ្នាពាក់ព័ន្ធនឹងប្រភេទនៃព្យសនកម្មដែលបានទទួលរងក្តី។ នៅចំពោះមុខ អ.វ.ត.ក សំណងត្រូវជាសំណង “សមូហភាព និងផ្លូវចិត្ត” ដូច្នេះមានន័យថា សំណងជាលក្ខណៈបុគ្គល និងថវិកា ត្រូវបានដកចេញ។ ក្នុងន័យនេះ សំណងត្រូវតែអាចឆ្លើយតបទៅនឹងការតម្រូវមួយនេះ៖ ផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនូវអារម្មណ៍ថាសំណងសមូហភាព និងផ្លូវចិត្ត បានឆ្លើយតបទៅនឹងព្យសនកម្មផ្ទាល់ខ្លួនរបស់ពួកគាត់ម្នាក់ៗ។ ចំណុចមួយនេះ ក៏ត្រូវ

បានគូសបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលផងដែរ[219]។ គម្រោងទាំងឡាយដែលបានរៀបរាប់ខាងលើ ផ្តោតលើគោលដៅនេះ។

## ៣. ចម្លើយតបមួយដ៏សមស្របទៅនឹងបរិបទ

២៣២. ដើម្បីធ្វើឲ្យសំណងមានប្រសិទ្ធិភាព វាជាការចាំបាច់ក្នុងការពិចារណាលើបញ្ហាកំហិតនានា ដូចជាភាពយឺតយ៉ាវនៃការជំនុំជម្រះ ការមិនមានធនធានហិរញ្ញវត្ថុសម្រាប់ធានាការផ្តល់សំណងថវិកាជាលក្ខណៈបុគ្គល។ ក្រៅពីកត្តាទាំងអស់នេះ សំណងជាលក្ខណៈសមូហភាព និងផ្លូវចិត្ត ក៏មានន័យផងដែរ នៅក្នុងបរិបទនៃការជំនុំជម្រះនេះ។ រយៈពេល ៣០ ឆ្នាំ បានកន្លងផុតទៅ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បច្ចុប្បន្ននេះ វាពិតជាមានការលំបាកក្នុងការកំណត់អំពីចំនួន ឬវាយតម្លៃឲ្យបានច្បាស់លាស់ពីព្យសនកម្មជាលក្ខណៈបុគ្គលនីមួយៗ ទោះបីជាព្យសនកម្មនោះ ជាការខូចខាតផ្នែកផ្លូវកាយ សម្ភារៈ ឬផ្លូវចិត្តយ៉ាងណាក្តី។ ភស្តុតាងដែលអនុញ្ញាតឲ្យយើងកំណត់អំពីចំនួន និងធ្វើការវាយតម្លៃ ពិតជាពិបាក ឬក៏មិនអាចធ្វើទៅបានថែមទៀតផងក្នុងការប្រមូលរកភស្តុតាងទាំងអស់នោះ ខណៈដែលអត្ថិភាពនៃព្យសនកម្មពិតជាមានមិនអាចប្រកែកបាន។ ជនរងគ្រោះជាច្រើនបានលើកឡើងបន្ថែមអំពីការលំបាកក្នុងការកំណត់នូវចំនួនបែបនេះ។ បន្ថែមលើនេះទៀត មនុស្សជាច្រើននាក់ក្នុងចំណោមជនរងគ្រោះបានស្លាប់ចាប់តាំងពីពេលដែលឧក្រិដ្ឋកម្មនេះបានកើតឡើង។

២៣៣. ប្រឈមនឹងការលំបាកទាំងអស់នេះ សំណងសមូហភាព និងផ្លូវចិត្តដែលទាមទារ ពិតជាឆ្លើយតបបានយ៉ាងសមស្របទៅនឹងការខូចខាតដែលបានទទួលរង និងតម្រូវការដែលបានសម្តែងឡើង។ ដូច្នេះ សំណងប្រភេទនេះ អាចឆ្លើយតបជាបឋមទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗគ្នាជាច្រើន៖ លើសពប្រភេទការងារដែលត្រូវបានគេផ្តោតជាសំខាន់ មានដូចជា សាសនាដែលគេប្រតិបត្តិផ្សេងៗគ្នា អាយុ លើសពីភាពខុសគ្នារវាងប្រជាជនស៊ីវិល/ទាហាន /មន្ត្រីរាជការ និង សាសនិក លើសពីភាពខុសគ្នារវាងប្រជាជនថ្មី/ប្រជាជនចាស់ និងខ្មែរក្រហមដែលជាជនរងគ្រោះនៃការបោសសម្អាត គ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺជាអ្នកត្រូវទទួលបានសំណងដែលជាសិទ្ធិរបស់ពួកគាត់ត្រូវទទួលបាន ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

២៣៤. អង្គជំនុំជម្រះ ដែលបានបញ្ជាក់ថាគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង០០២ ត្រូវរក្សាទុកឋានៈរបស់ខ្លួនជាសមាជិកក្រុម ដោយមិនគិតដល់ការបំបែកនីតិ

វិធី ហើយដែលសំណងនឹងត្រូវផ្តល់ទៅដល់ក្រុម និងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់[220] ដូច្នេះ សំណងសមូហភាព និងផ្លូវចិត្តដែលបានទាមទារ ទំនងជាសមស្រប។

## ៤. ចម្លើយតបមួយសមស្របទៅនឹងបទដ្ឋានអន្តរជាតិ

២៣៥. ប្រភេទសំណងផ្សេងៗគ្នាជាច្រើន ត្រូវបានកំណត់ដោយច្បាប់អន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ បណ្តាលមកពីការរំលោភជាក់ស្តែងលើច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ[221]។ គម្រោងខាងលើ ដែលត្រូវបានចែកចេញជាបីប្រភេទ ដែលក្នុងនោះមាន ការគោរពវិញ្ញាណក្ខន្ធ ការស្តារនីតិសម្បទា និងការអប់រំ និងការចងក្រងឯកសារ ពិតជាសមស្របទៅនឹងលក្ខខណ្ឌតម្រូវដែលចែងដោយច្បាប់អន្តរជាតិ។

២៣៦. នៅចុងបញ្ចប់នៃសេចក្តីពន្យល់នេះ មេធាវីនាំមុខសូមគូសបញ្ជាក់ថា សំណងសមូហភាពដែលស្នើសុំ នឹងឆ្លើយតបយ៉ាងពិតប្រាកដទៅនឹងព្យសនកម្មជាលក្ខណៈបុគ្គលនានា ដែលជាលក្ខខណ្ឌចាំបាច់នៃសំណង ដូចដែលបានបញ្ជាក់ពីខាងដើម។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ នឹងអាចរកបាននៅក្នុងឱកាសទិវានៃការចងចាំ នៅតាមស្តូប នៅក្នុងការតាំងពិព័រណ៍ នៅក្នុងឯកសារ ឬក៏តាមវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង នូវចម្លើយជាក់លាក់មួយទៅនឹងការឈឺចាប់ និងព្យសនកម្មផ្ទាល់ខ្លួនរបស់ពួកគាត់ម្នាក់ៗ។ រាល់គម្រោងនីមួយៗដែលបង្ហាញជូន មិនមែនអនាមិក និងទូទៅនោះទេ ប៉ុន្តែគឺសំដៅផ្តល់ជូននូវចម្លើយជាក់លាក់ផ្ទាល់ ដើម្បីជួសជុលការខូចខាតដែលបានទទួលរង។ ភាពសមស្របនៃគម្រោងនីមួយៗ នឹងត្រូវបង្ហាញជូននៅពេលក្រោយ។

## V. សេចក្តីសន្និដ្ឋាន និងសំណើសុំ

២៣៧. សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានរួមគ្នារៀបចំការទាមទារសំណង ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដោយបានគោរពលក្ខខណ្ឌតម្រូវផ្លូវច្បាប់នានា ទោះជាលក្ខខណ្ឌទាំងនោះជាលក្ខខណ្ឌចេញពីច្បាប់ជាធរមានដែលអាចអនុវត្តជាទូទៅសម្រាប់ការទាមទារសំណង ឬក៏ជាលក្ខខណ្ឌជាក់លាក់ដែលចេញមកពីច្បាប់ជាធរមាននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ថាការទាមទារសំណងនេះ គឺជាធាតុផ្សំមួយដ៏ចាំបាច់ក្នុងរឿងក្តី ខណៈដែលរឿងក្តីនេះមានបញ្ចូលជនរងគ្រោះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

២៣៨. ដើមបណ្ដឹងរដ្ឋប្បវេណីសូមគូសបញ្ជាក់ថា ខ្លួនពិតជាមានការសោកស្ដាយដែលច្បាប់របស់ អ.វ.ត.ក មិនអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំក្នុងពេលតែមួយ នូវការផ្ដន្ទាទោសជនជាប់ចោទឲ្យទទួលរ៉ាប់រងលើសោហ៊ុយចំណាយសម្រាប់សំណងដែលត្រូវបានសម្រេច និងការទទួលបន្ទុកលើសំណងទាំងអស់នេះ ដែលក្នុងលក្ខណៈបន្ទាប់បន្សំត្រូវធ្លាក់ទៅលើគតិយជន។ វិធាន ២៣ ស្ទួនបួន ២)គ) តម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ពី *"[...] ទម្រង់នៃការអនុវត្តជាក់លាក់តែមួយលើសំណងនីមួយៗ (...) ដែលទាមទារ"*។ ដើមបណ្ដឹងរដ្ឋប្បវេណីចាត់ទុកថា ការផ្ដន្ទាទោសទណ្ឌិតតាមច្បាប់ព្រហ្មទណ្ឌ ឲ្យទទួលរ៉ាប់រងលើសំណង គឺជាគោលការណ៍ដ៏សំខាន់មួយនៃច្បាប់ព្រហ្មទណ្ឌ ដែលអ.វ.ត.ក គួរតែរក្សាទុកការអនុវត្ត ទោះបីជាជនជាប់ចោទជាជនក្រីក្រ និងមិនមានសមត្ថភាពក្នុងការទទួលខុសត្រូវចំពោះការផ្ដន្ទាទោសនេះប្រកបដោយប្រសិទ្ធិភាពក៏ដោយ។ នៅចំពោះមុខកាតព្វកិច្ចនេះ និងដើម្បីធានាឲ្យបាននូវសំណងដែលទាមទារឲ្យបានជាអតិបរមា ដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ថាខ្លួនទាមទារសុំឲ្យទទួលស្គាល់នូវគម្រោងជាក់លាក់មួយចំនួនថាជាសំណង (ទម្រង់នៃការអនុវត្ត ៣)ខ))។

២៣៩. មកទល់ពេលនេះ គម្រោងមួយចំនួនតូចដែលត្រូវបានរៀបរាប់ខាងលើ បានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនីមួយៗនៃវិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះត្រូវបានស្នើឲ្យទទួលស្គាល់លក្ខខណ្ឌទាំងអស់នោះ ថាជាសំណងសមរម្យដែលត្រូវផ្ដល់ជូនដើមបណ្ដឹងរដ្ឋប្បវេណី។

២៤០. ប៉ុន្តែ រហូតមកដល់ថ្ងៃនេះ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាមួយអង្គភាពគាំពារជនរងគ្រោះ និងបណ្ដាអង្គការមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងក្ដី ក៏ដើមបណ្ដឹងរដ្ឋប្បវេណីនៅតែមិនទាន់អាចរកបាននូវមូលនិធិចាំបាច់គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងឲ្យបានទាំងស្រុងដែរ។ ប៉ុន្តែក្នុងស្ថានភាពបែបនេះ ដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើឲ្យទទួលស្គាល់គម្រោងទាំងអស់នេះថាជាសំណង ឬបើមិនដូច្នោះទេ សូមឲ្យទទួលស្គាល់ស្មើនឹងកម្រិតនៃការអនុវត្តដែលទទួលបានថវិកា ឬជាកម្មវត្ថុនៃការសន្យាផ្ដល់មូលនិធិរហូតដល់ថ្ងៃពិភាក្សា ហើយអង្គការដែលទទួលបន្ទុកអនុវត្តគម្រោងត្រូវសម្រួបការងារអនុវត្តទៅនឹងថវិកាដែលមាន។

២៤១. ដោយគិតដល់បញ្ហាជាច្រើននៃកាតព្វកិច្ចតម្រូវឲ្យ"ធានានូវការផ្ដល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ"[222] សម្រាប់គម្រោងនីមួយៗ ដើមបណ្ដឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា បន្ទាប់ពីការដាក់សំណើសុំចុងក្រោយនេះ រហូតដល់ការចេញសេចក្ដីសម្រេចចុងក្រោយ ខ្លួននឹងប្រគល់ជូនអង្គជំនុំជម្រះ និងភាគីទាំងអស់ នូវរាល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងស្ថានភាពថវិការបស់គម្រោងនីមួយៗ ហើយ

នឹងព័ត៌មានដែលមកបំពេញស្ថានភាពនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យកត់សម្គាល់ពីដំណើរការនេះរបស់ខ្លួន ហើយរាល់ធាតុផ្សំទាំងឡាយដែលបានប្រគល់ជូន គួរតែត្រូវបានពិចារណានៅពេលចេញសេចក្តីសម្រេច។

២៤២. ប្រសិនបើមិនដូច្នោះទេ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ថា គម្រោងដែលត្រូវបានកម្រិតត្រឹមរយៈពេលណាមួយនាពេលបច្ចុប្បន្ន ដោយមូលហេតុបញ្ហាថវិកាមានកម្រិត អាចត្រូវបានចាត់ទុកជាសំណងមួយក្នុងរយៈពេលវែង នៅពេលដែលថវិកាបន្ថែមអាចអនុញ្ញាតឲ្យបន្តគម្រោងនោះតទៅទៀត។

២៤៣. នៅទីបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ថា អង្គជំនុំជម្រះបានបញ្ជាក់ថា ប្រសិនបើខ្លួនមិនអាចដាក់កាតព្វកិច្ចលើរាជរដ្ឋាភិបាលកម្ពុជា ឬលើស្ថាប័នដែលមិនមែនជាភាគីនៃរឿងក្តី "*អង្គជំនុំជម្រះអាចត្រឹមជួយជំរុញអាជ្ញាធរជាតិ ឬស្ថាប័នអន្តរជាតិ ឬអ្នកដែលអាចនឹងជួយផ្តល់ជំនួយបង្ហាញសាមគ្គីភាពជាមួយជនរងគ្រោះ តាមរយៈការផ្តល់ជំនួយគាំទ្រជាហិរញ្ញវត្ថុ ឬជំនួយតាមរូបភាពផ្សេងៗ ដែលជួយដល់ការស្តារឡើងវិញ ការធ្វើសមាហរណកម្ម និងការលើកស្ទួយភាពថ្លៃថ្នូររបស់មនុស្សជាតិឡើងវិញ*"[223]។ ដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះដាក់បញ្ចូលការជំរុញនេះទៅក្នុងសេចក្តីសម្រេចនាពេលខាងមុខ។

**ផ្អែកតាមសំអាងហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យអង្គជំនុំជម្រះមេត្តា៖**

– ទទួលស្គាល់ជាផ្លូវការនូវការខូចខាតដែលបានទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ថាជាផលវិបាកនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទនឹងត្រូវបានផ្តន្ទាទោស។
– ជាចម្បង បង្ខំឲ្យបុគ្គលដែលត្រូវប្រកាសថាមានពិរុទ្ធភាព ឲ្យជុសជុលសំណងដែលបានទទួលរង និង ក្នុងករណីដែលក្រីក្រ សម្រេចថាសំណងនឹងត្រូវអនុវត្ត និងផ្តល់ថវិកាដោយតតិយជន។
– ជាបន្ទាប់បន្សំ ទទួលតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឲ្យអនុវត្តបែបបទអនុវត្តនៃវិធាន២៣ស្ទួនបួន ៣)ខ)
– ទទួលស្គាល់គម្រោងនីមួយៗដែលបានរៀបរាប់ខាងលើថាជាសំណង ទោះបីជាស្ថានភាពថវិការបស់គម្រោងទាំងនោះយ៉ាងណាក៏ដោយ ឬយ៉ាងហោចណាស់ ទទួលស្គាល់គម្រោងទាំងនោះឲ្យស្មើនឹងទំហំថវិកានៃគម្រោងនោះ ដោយសុំឲ្យអង្គការទទួលបន្ទុកអនុវត្តគម្រោង សម្របការអនុវត្តទៅនឹងថវិកា ប្រសិនបើការងារនោះមិនទាន់បានអនុវត្ត។

– ពិចារណាលើរាល់ព័ត៌មានស្តីពីស្ថានភាពថវិការបស់គម្រោងទាំងឡាយដែលបានរៀបរាប់ខាងលើ ដែលដើមបណ្តឹងរដ្ឋប្បវេណីមានលទ្ធភាពផ្តល់ជូននៅពេលពិភាក្សារបស់ចៅក្រម។
– ទទួលនូវអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់ជូននៅពេលពិភាក្សារបស់ចៅក្រម លើព័ត៌មានទាំងអស់នោះ ដើម្បីឲ្យពួកគាត់អាចទទួលបានសំណងប្រកបដោយអត្ថន័យ។
– សម្រេចថា គម្រោងណាមួយដែលត្រូវបានកម្រិតត្រឹមរយៈពេលណាមួយរហូតមកទល់ពេលនេះ ដោយមូលហេតុបញ្ហាថវិកា ត្រូវតែបានចាត់ទុកថាជាសំណងមួយលើសពីរយៈពេលនេះ នៅពេលទទួលបានថវិកាបន្ថែម។
– ជំរុញអាជ្ញាធរជាតិ សហគមន៍អន្តរជាតិ និងម្ចាស់ជំនួយធំៗ ឲ្យបង្ហាញពីសាមគ្គីភាពរបស់ពួកគេក្នុងការសម្រេចឲ្យបាននូវវិធានការសំណងដែលនឹងត្រូវទទួលស្គាល់។

សូមរក្សាសិទ្ធិគ្រប់ប្រភេទ

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០៨ តុលា ២០១៣ | មេធាវី ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | មេធាវី Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | ភ្នំពេញ | |

[1] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/6.1 ទំព័រ ៧៨-៩៤ (តទៅនេះហៅថា "ប្រតិចារឹកសវនាការលើខ្លឹមសារបឋម ១")។

[2] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីកាលបរិច្ឆេទសវនាការបឋមក្នុងសំណុំរឿង០០២ ឯកសារ E86 ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១។

[3] ប្រតិចារឹកសវនាការលើខ្លឹមសារបឋម ១ ទំព័រ ៩០-៩៣ (រៀបរាប់ដោយលម្អិតអំពីគម្រោងជាបួនប្រភេទ ដែលក្នុងនោះមាន *ការរំឭក និងការចងចាំ* ១) ទិវានៃការចងចាំ ២) ចេតិយ និងស្តូប ៣) ការរក្សាទុកទីតាំងសម្លាប់មនុស្ស, *ការស្តារនីតិសម្បទា* ៤) សេវាថែទាំសុខភាពផ្លូវចិត្ត ៥) ក្រុមពិភាក្សា, *ការចងក្រងឯកសារ និង ការអប់រំ* ៦) ការអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ៧) មជ្ឈមណ្ឌលឯកសារ ៨) សារៈមន្ទីរនៅភ្នំពេញ ៩) បញ្ជីជនរងគ្រោះ និង*គម្រោងផ្សេងៗទៀត* ១០) គម្រោងផ្តល់សញ្ជាតិដល់ជនរងគ្រោះជនជាតិវៀតណាម ១១) គម្រោងអប់រំកុមារដែលកើតចេញពីការរៀបការដោយបង្ខំ ១២) ការបង្កើតមូលនិធិជួសជុលការខូចខាត និង ១៣) ការផ្សព្វផ្សាយសាលក្រម។

[4] ប្រតិចារឹកសវនាការលើខ្លឹមសារបឋម ១ ទំព័រ ៩៣-៩៤។

[5] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៨។

[6] ការជូនដំណឹងពីសំណើរបស់សហមេធាវីនាំមុខស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចនៅក្នុងដីកាបំបែកនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ ឯកសារ E124/4 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១, សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យពិចារណាឡើងវិញនូវខ្លឹមសារក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី លេខ E124 ឯកសារ E124/8 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ និង សំណើជាបន្ទាន់ស្តីពីវិសាលភាពនៃសវនាការដំបូង និងតម្រូវការចាំបាច់ឲ្យមានសេចក្តីសម្រេចមួយដែលមានសំអាងហេតុត្រឹមត្រូវចំពោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យមានការពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E124/10 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/11.1 ទំព័រ ១៣-១៥ (រៀបរាប់ពីការខិតខំប្រឹងប្រែងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការពិភាក្សាពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីមកលើសំណង ហើយដែលការប្រឹងប្រែងនេះត្រូវបានកាត់ដោយអង្គជំនុំជម្រះ) និង ខ្លឹមសារជាក់លាក់ជាបឋមស្តីពីសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំ នាពេលសវនាការថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០១១ ឯកសារ E125/2 ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ (តទៅនេះហៅថា " ខ្លឹមសារបឋមជាលាយល័ក្ខអក្សរ ២") (ផ្តល់នូវអត្ថបទទាំងស្រុងនៃខ្លឹមសារបឋមដែលរៀបចំដោយសហមេធាវីនាំមុខ និងដោយលើកឡើងពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីមកលើសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី)។

[7] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (៣) នៃវិធានផ្ទៃក្នុង ឯកសារ E125 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១។

[8] យោងដូចខាងលើ ទំព័រ ២-៣។

[9] យោងដូចខាងលើ ទំព័រ ៣។

[10] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/11.1 ទំព័រ ៣-៥៩ (តទៅនេះ ហៅថា "ប្រតិចារឹកសវនាការលើខ្លឹមសារបឋម ២") និងខ្លឹមសារបឋមជាលាយល័ក្ខអក្សរ ២។ គម្រោងសរុបទាំងអស់ចំនួន១៦ ចែកចេញជាបួនប្រភេទដូចគ្នាក្នុងខ្លឹមសារបឋម ១ ត្រូវបានបង្ហាញ៖ *ការរំឭក និងការចងចាំ* ១) គម្រោងតស៊ូមតិទាមទារបង្កើតឱ្យមានទិវានៃការរំឭកថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ២) គម្រោងសាងសង់ចេតិយ និងស្តូបគោរពវិញ្ញាណក្ខន្ធ ៣) ពិធីបុណ្យខុទ្ទិស ៤) គម្រោងរក្សាទុកទីតាំងឧក្រិដ្ឋកម្ម, *ការស្តារនីតិសម្បទា* ៥) គម្រោងបង្កើត សេវាថែទាំសុខភាពផ្លូវចិត្ត និងផ្លូវកាយ ៦) គម្រោងគាំទ្រដល់ក្រុមជួយខ្លួនឯង, *ការចងក្រងឯកសារ និង ការអប់រំ* ៧) ការអភិរក្ស និងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់មនុស្សជំនាន់ក្រោយ ៨) មជ្ឈមណ្ឌលឯកសារ បណ្ណសារ បណ្ណាល័យ សារៈមន្ទីរ ៩) បញ្ជីជនរងគ្រោះ ១០) ការផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ១១) មជ្ឈមណ្ឌលវប្បធម៌ឯកសារ ១២) មជ្ឈមណ្ឌលអភិរក្សវប្បធម៌ជនជាតិចាម និង *គម្រោងផ្សេងៗទៀត* ១៣) មូលនិធិជួសជុលការខូចខាត ១៤) យន្តការតាមដានសំណង ១៥) គម្រោងសម្រួលក្នុងការទទួលបានសញ្ជាតិខ្មែរ និង ១៦)គម្រោងកំណត់អំពីតម្រូវការ និងសំណើសុំឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កុមារដែលកើតចេញមកពីការរៀបការដោយបង្ខំ។

[11] ប្រតិចារឹកសវនាការលើខ្លឹមសារបឋម ២ ឯកសារ E1/11.1 ទំព័រ ៤៥-៤៦ និង ខ្លឹមសារបឋមជាលាយល័ក្ខអក្សរ ២ កថាខណ្ឌ ១០០។

[12] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីសេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (E20, E132, E135, E124/8, E124/9, E124/10, E136, E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E145 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤ (ដោយបានកត់សម្គាល់ថា "ថ្វីបើដូច្នេះ អង្គជំនុំជម្រះសូមជំរុញសហមេធាវីនាំមុខឱ្យយកចិត្តទុកដាក់លើសំណង ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ...")។

[13] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធិភាពនៃសវនាការ" ឯកសារ E218 កថាខណ្ឌ ១៩ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២។

[14] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន (៤)) ឯកសារ E218/7 ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២។

[15] ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូងអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន (៤)) (មានភ្ជាប់ឧបសម្ព័ន្ធសម្ងាត់) ឯកសារ E218/7/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៣០-៣៥ (តទៅនេះហៅថា "ការធ្វើបច្ចុប្បន្នភាពសំណង ១") (ដោយបានបង្ហាញនូវគម្រោងដូចតទៅ៖ *ការរំឭក និងការគោរពវិញ្ញាណក្ខន្ធ* (១) ទិវានៃការចងចាំ (២) គម្រោងស្តូបសាធារណៈ, *ការស្តារនីតិសម្បទា* (៣) ការព្យាបាលតាមការចងក្រងជាសក្ខីកម្ម (៤) ក្រុមជួយខ្លួនឯង, *ការចងក្រងឯកសារ និងការអប់រំ* (៥) គម្រោងតាំងពិព័រណ៍ចល័ត និងគម្រោងអប់រំ៖ ស្វែងយល់ពីប្រវត្តិសាស្ត្រ និងយុត្តិធម៌អន្តរកាល (៦) ការតាំងពិព័រណ៍អចិន្ត្រៃយ៍ និង (៧) សៀវភៅស្តីអំពីអង្គហេតុដែលត្រូវបានជំនុំជម្រះក្នុងសំណុំរឿង០០២ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី)។

[16] ការធ្វើបច្ចុប្បន្នភាពសំណង ១ កថាខណ្ឌ ៣៦។

[17] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៨។

[18] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា “ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងការចង្អុលបង្ហាញរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីគម្រោងអាទិភាពសម្រាប់ការអនុវត្តសំណង អនុលោមតាមវិធាន ៨0 ស្ទួន (៤) (E218/7/1)” ឯកសារ E218/7/2 ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៣ កថាខណ្ឌ ៤-៦។

[19] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E218/7/2) ទាក់ទងនឹងគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង00២/0១ និងមានឧបសម្ព័ន្ធសម្ងាត់ ឯកសារ E218/7/3 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ (តទៅនេះហៅថា “ការធ្វើបច្ចុប្បន្នភាពសំណង ២”) (ដោយបានបង្ហាញនូវគម្រោងដូចជា *ការរំឭក និងការគោរពវិញ្ញាណក្ខន្ធ* ១) ទិវាជាតិនៃការចងចាំ ២) គម្រោងស្តូបសាធារណៈ ៣) បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ “ជូនចំពោះជនដែលបានបាត់បង់ជីវិត”, *ការស្តារនីតិសម្បទា* ៤) វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម ៥) ក្រុមជួយខ្លួនឯង, *ការចងក្រងឯកសារ និងការអប់រំ* ៦) ការតាំងពិព័ណ៌អចិន្ត្រៃយ៍ដោយផ្តោតសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម ៧) ការតាំងពិព័ណ៌ចល័តស្តីពីរបបខ្មែរក្រហម និងផ្តោតជាពិសេសលើឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះក្នុងសំណុំរឿង00២/0១ ៨) ជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ)។

[20] ការធ្វើបច្ចុប្បន្នភាពសំណង ២ កថាខណ្ឌ ១២។

[21] សេចក្តីសម្រេច ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E 218/7/4។

[22] សេចក្តីសម្រេច ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E 218/7/5។

[23] *រឿងក្តីរោងចក្រ Chorzow (រដ្ឋាភិបាលអាល្លឺម៉ង់ តទល់នឹង រដ្ឋាភិបាលប៉ូឡូញ)* សាលដីកា (បណ្តឹងទាមទារសំណង) (អង្គសេចក្តី) តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩២៨, CPU S"rie A, N¢ 17 (“សាលដីកា *Chorzow*”) កថាខណ្ឌ ៧៣។

[24] *រឿងក្តីម៉ាទីនី (អ៊ីតាលី តទល់នឹង វេណេហ្ស៊ុយឡា)* ១៩៣0 ២ ៩៧៧ RSA, ១00២។

[25] សាលក្រមក្នុងសំណុំរឿង00១ ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២0១0 កថាខណ្ឌ ៦៦២ (ដែលក្នុងនោះ “អង្គជំនុំជម្រះទទួលស្គាល់គោលការណ៍ ដែលបញ្ជាក់អំពីសិទ្ធិរបស់ជនរងគ្រោះនៃការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ធិសញ្ញាអន្តរជាតិមួយចំនួន និងលិខិតុបករណ៍ផ្សេងៗទៀត សេចក្តីប្រកាសរបស់ស្ថាប័នអង្គការសហប្រជាជាតិ និងសេចក្តីសម្រេចរបស់តុលាការប្រចាំតំបន់នានា”)។

[26] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២00៧ មាត្រា ២ មាត្រា ១៣ (មាត្រា ១៣ ចែងថា “បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស។ ដើម្បីទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ៖ ជាផលវិបាកផ្ទាល់នៃបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន”) (តទៅនេះហៅថា “ក្រម កម្ពុជា”) និង ក្រមនីតិវិធីព្រហ្មទណ្ឌនៃសាធារណរដ្ឋបារាំង () មាត្រា ២, ៧0៦-៣ ដល់ ៧0៦-១៥ (តទៅនេះហៅថា “ក្រមបារាំង”)។

[27] គោលការណ៍គ្រឹះរបស់អង្គការសហប្រជាជាតិស្តីពីសំណង មាត្រា ១១។

[28] គោលការណ៍គ្រឹះរបស់អង្គការសហប្រជាជាតិស្តីពីសំណង មាត្រា ១៥-២៣។ *សូមមើលផងដែរ* សេចក្តីប្រកាសស្តីពីគោលការណ៍គ្រឹះនៃយុត្តិធម៌ជនរងគ្រោះដោយសារអំពើឧក្រិដ្ឋកម្ម និងជនរងគ្រោះដោយការរំលោភអំណាច សេចក្តីសម្រេចលេខ ៤0/៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៤0 ឯកសារអង្គការសហប្រជាជាតិ A/RES/40/34 (២៩ វិច្ឆិកា ១៩៨៥) (ដោយបានបញ្ជាក់ពីសិទ្ធិក្នុងការទទួលបានមកវិញ (មាត្រា ៨ ដល់មាត្រា ១១) ការទទួលបានការជួសជុល (មាត្រា ១២ ដល់ មាត្រា ១៣) និងការស្តារនីតិសម្បទា (មាត្រា ១៤ ដល់ មាត្រា ១៧))។

[29] លក្ខន្តិកៈក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០២ មាត្រា ៧៥, អនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ មាត្រា ៦៣, អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៥៣ មាត្រា ៤១។

[30] សាលដីកាក្នុងសំណុំរឿង០០១ ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៥២។

[31] វិធាននីតិវិធី និងភ័ស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (២០ តុលា ២០១១) មាត្រា ១០៦, វិធាននីតិវិធី និងភ័ស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (១ តុលា ២០០៩) មាត្រា ១០៦, វិធាននីតិវិធី និងភ័ស្តុតាង នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (៣១ ឧសភា ២០១២) មាត្រា ១០៥។

[32] វិធាន ២៣ (១)(ខ) និង (៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨) ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ (តទៅនេះហៅថា "វិធានផ្ទៃក្នុង") និងវិធាន ៨០ ស្ទួន(៤) (បានកត់សម្គាល់ថា សហមេធាវីនាំមុខត្រូវធ្វើ "បណ្តឹងទាមទារចុងក្រោយ"សម្រាប់សំណងដើមបណ្តឹងរដ្ឋប្បវេណី)។

[33] វិធាន ២៣ ស្ទួនបួន(២) នៃវិធានផ្ទៃក្នុង។

[34] សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយល័ក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ ឯកសារ E159 ទំព័រ ២ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩។

[35] វិធាន ២៣ ស្ទួនបួន(១)(ក)-(ខ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សាលក្រមក្នុងសំណុំរឿង០០១ ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៦៦៥ (ដោយបានតម្រូវថា "បុរេល័ក្ខខ័ណ្ឌចំពោះការផ្តល់សំណង គឺត្រូវបញ្ជាក់យ៉ាងច្បាស់អំពីប្រភេទនៃសំណងដែលជនរងគ្រោះចង់បាន ទំនាក់ទំនងរវាងប្រភេទនៃសំណង និងព្យសនកម្មដែលបង្កឡើងដោយពិរុទ្ធជនដែលជាអ្នកត្រូវផ្តល់សំណង និងចំនួននៃសំណងដែលពិរុទ្ធជនត្រូវសង។ ទាំងនេះគឺជាល័ក្ខខ័ណ្ឌដើម្បីធ្វើឱ្យការទាមទារសំណងនោះមានប្រសិទ្ធភាព")។

[36] វិធាន ២៣(៣) នៃវិធានផ្ទៃក្នុង (ចែងថា "ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវរួមបញ្ចូលក្រុមតែមួយ (...)"។ *សូមមើលផងដែរ* ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៨ (ដោយបានកត់សម្គាល់ថា "ផ្អែកលើបទដ្ឋានគតិយុត្តជាធរមាន ដើមបណ្តឹងរដ្ឋប្បវេណី មិនចូលរួមជាលក្ខណៈបុគ្គល ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្មជាក់លាក់ដែលខ្លួនបានទទួលរងឡើយ ផ្ទុយទៅវិញដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ រួមបញ្ចូលជាបណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ (...)"។

[37] វិធាន ២៣ ស្ទួន(៣) នៃវិធានផ្ទៃក្នុង ("រាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ [...] ត្រូវបង្កើតជាក្រុមរួមបញ្ចូលគ្នាតែមួយ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ [...]")។ *សូមមើលផងដែរ* សាលដីកាក្នុងសំណុំរឿង០០១ ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៩៩ (ដោយបានកត់សម្គាល់ថា "នៅពេលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានព្យសនកម្ម និងទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម្ចាស់បណ្តឹងសាទុក្ខ ដូច្នេះភាពអាចទទួលបានសំណងត្រូវបានភ័ស្តុតាងបង្ហាញ")។

[38] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៨។

[39] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥៨ (តទៅនេះ

ហៅថា "ដីកាទីពីរនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី") (ដោយបានប្រកាសថា "អង្គជំនុំជម្រះសាលាដំបូង ពុំបានជ្រើសរើសចំនួនដើមបណ្តឹងរដ្ឋប្បវេណីក្នុងកម្រិតជាក់លាក់ពីបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ ដើម្បីទទួលប្រយោជន៍ពីសំណងណាមួយដែលអង្គជំនុំជម្រះដំបូងបានប្រគល់ ឬអនុម័តនៅទីបំផុតនោះទេ")។ *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីសេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (E20, E132, E135, E124/8, E124/9, E124/10, E136, E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E145 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២ (ដោយធ្វើការបែងចែកពីភាពខុសគ្នារវាងសំណងដែលមានចែងក្នុងវិធាន ២៣ ស្ទួនបួន (៣)(ក) (សំណងដែលជាសោហ៊ុយរបស់ពិរុទ្ធជន) និងមាត្រា ២៣ ស្ទួនបួន (៣)(ខ) (សំណងដែលទទួលមូលនិធិពីខាងក្រៅ) ដោយបានបញ្ជាក់ថា សំណងដែលជាសោហ៊ុយរបស់ពិរុទ្ធជន អាច"ត្រឹមតែពិចារណាលើព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយសារការប្រព្រឹត្ត និងការចោទប្រកាន់ដែលជាមូលដ្ឋាននៃសំណុំរឿង០០២/០១" ហើយសំណងដែលទទួលមូលនិធិពីខាងក្រៅ អាចផ្តល់លទ្ធភាព "ក្នុងការបង្កើតគម្រោងណាមួយដែលផ្តល់សុពលភាពដល់សំណងដែលសហមេធាវីនាំមុខបានទាមទារ" និងដែល "អាចត្រូវបានអនុវត្តឱ្យស៊ីសង្វាក់ទៅនឹងការជំនុំជម្រះលើសំណុំរឿង០០២ ទាំងមូល")។ ថ្វីបើដូច្នេះ ពាក់ព័ន្ធនឹងសំណងដែលបានស្នើឡើងស្របតាមវិធាន ២៣ ស្ទួនបួន (៣)(ខ) អង្គជំនុំជម្រះសាលាដំបូងបាន"ជំរុញសហមេធាវីនាំមុខឱ្យយកចិត្តទុកដាក់លើសំណង ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ និងសំណងដែលអាចអនុវត្តបានក្នុងអំឡុងពេល ឬ ឆាប់ៗក្រោយពេលអង្គជំនុំជម្រះចេញសាលក្រមលើសំណុំរឿងនោះ។" ឯកសារ E145 ទំព័រ ៤។

[40] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីសេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (E20, E132, E135, E124/8, E124/9, E124/10, E136, E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E145 ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៣។

[41] វិធាន ២៣ ស្ទួនបួន (១) នៃវិធានផ្ទៃក្នុង។

[42] សាលដីកាក្នុងសំណុំរឿង០០១ ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៨៣, សាលក្រមក្នុងសំណុំរឿង០០១ ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កំណត់សម្គាល់ជើងទំព័រលេខ ១១៥៤។

[43] សាលដីកាក្នុងសំណុំរឿង០០១ ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៥៩ (ពិភាក្សាអំពីសញ្ញាណនៃសំណងសមូហភាព ដោយគូសបញ្ជាក់ពីភាពពាក់ព័ន្ធនៃសំណងនៅក្នុងបរិបទឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ)។

[44] សាលដីកាក្នុងសំណុំរឿង០០១ ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៥៨។

[45] វិធាន ២៣ ស្ទួនបួន (៣)(ក-ខ) នៃវិធានផ្ទៃក្នុង។

[46] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ស្តីពីការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (៣) នៃវិធានផ្ទៃក្នុង ឯកសារ E125 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ២។

[47] វិធាន ២៣ ស្ទួនបួន (២) នៃវិធានផ្ទៃក្នុង (តម្រូវឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ "ទម្រង់នៃការអនុវត្តជាក់លាក់តែមួយលើសំណងនីមួយៗ ដែលមានចែងក្នុងវិធាន ២៣ ស្ទួនបួន(៣)(ក) ឬ (ខ) ដែលទាមទារ" និង វិធាន ២៣ ស្ទួនបួន (៣)(ក)-(ខ) នៃវិធានផ្ទៃក្នុង (ដោយបញ្ជាក់ថា "សោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន" ឬ ទទួលស្គាល់ "នូវគម្រោងជាក់លាក់ដែលមានលក្ខណៈសមស្របឆ្លើយតបទៅនឹងសំណងដែលទាមទារ (...)"។

[48] *សូមមើល* សំណើលើកទី៣ របស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំបំពេញកិច្ចស៊ើបសួរ ទៅលើទ្រព្យសម្បត្តិទាំងអស់របស់ជនត្រូវចោទ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ឯកសារ D193 ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ (ស្នើសុំឱ្យស៊ើបអង្កេតលើទ្រព្យសម្បត្តិដែលជនជាប់ចោទមាននៅក្នុង និងក្រៅប្រទេសកម្ពុជា ហើយទ្រព្យសម្បត្តិដែលត្រូវបានរកឃើញ គួរតែត្រូវបានប្រើប្រាស់ធ្វើជាសំណង និងស្នើសុំឱ្យកំណត់ថាតើទ្រព្យសម្បត្តិ ទាំងឡាយដែលត្រូវបានផ្ទេរទៅឱ្យសាច់ញាតិផ្សេងៗ បានមកពីការបំពេញតួនាទីរបស់ជនជាប់ចោទនៅក្នុងជួរខ្មែរក្រហម ឬយ៉ាងណា) និង បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ឯកសារ D193/5/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១០ (មេធាវីដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា គោលការណ៍ច្បាប់ និងវិសាលភាពនៃការជួសជុលការខូចខាតនៃសំណងតាមផ្លូវតុលាការ នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ តាមរយៈការបង្កើតយន្តការសំណងមួយ ដែលអាចអនុញ្ញាតឱ្យតុលាការចេញសេចក្តីបង្គាប់ស្តីពីសំណងប្រឆាំងនឹងជនជាប់ចោទ និងអនុញ្ញាតឱ្យមានការផ្តល់ហិរញ្ញប្បទានពីខាងក្រៅ សំដៅសម្រួលដល់ការអនុវត្តក្នុងរយៈពេលមួយសមស្រប។ ត្រង់ចំណុចនេះ វិធានផ្ទៃក្នុងបានបង្កើតជាស្ថានភាពមិនអាចការពារបាន ដែលក្នុងនោះ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដកខ្លួនចេញពីក្រុម ស្របតាមគោលការណ៍នៃសំណង ដែលតម្រូវឱ្យភាគីអ្នកទទួលខុសត្រូវ (ពិរុទ្ធជន) ទទួលរ៉ាបរងសោហ៊ុយចំណាយសម្រាប់ការជួសជុលការខូចខាត ដែលតម្រូវឱ្យមានជាចាំបាច់នូវទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានប្រកាសពីពិរុទ្ធភាព និងភាគីអ្នកទាមទារសំណង ឬ ក៏ត្រូវទទួលយកថា សំណងត្រូវបាន "ទទួលស្គាល់" ប៉ុន្តែសំណងនោះមិនមែនត្រូវបានបង្គាប់ប្រឆាំងនឹងពិរុទ្ធជនឡើយ)។

[49] សំណើសុំធ្វើវិសោធនកម្មវិធាន ២៣ ស្ទួនបួន (៣) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ (ដែលសំណើនោះត្រូវបានបញ្ជូនទៅគណៈកម្មាធិការនីតិវិធី នៃអវតក នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២)។

